សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ប្រភេទនៃទោសក្នុងក្រមព្រហ្មទណ្ឌ

ស្រាវជ្រាវ ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

រៀបរៀងដោយ៖

និស្សិតឈ្មោះ: **លោក ផល់ តារម្យ**

**លោក ណាល់ ពិសិដ្ឋ**

ណែនាំដោយ

**លោកគ្រូ សៅ ស៊ីទុត្ថា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី **២៤**

ឆ្នាំចូលសិក្សា **២០២០**

ឆ្នាំសរសេរសារណា **២០២៤**

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ផល់ ភារម្យ** និងឈ្មោះ **ណាល់ ពិសិដ្ឋ** ជានិស្សិតឆ្នាំទី៤ ថ្នាក់បរិញ្ញាបត្រ នីតិសាស្រ្ត ជំនាន់ទី២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។

សូមថ្លែងអំណរគុណ និងសម្តែងនូវកតញ្ញូដឹងគុណយ៉ាងជ្រាលជ្រៅជូនចំពោះ៖

| | |
|---|---|
| លោកឪពុក **សុន សុផល** | លោកឪពុក **ប៉ាវ វិចិត្រ** |
| អ្នកម្តាយ **សុំ សំអាត** | អ្នកម្តាយ **នាក់ ចាន់ណា** |

ជាកិច្ចបឋមកូនៗ សូមគោរពលំឱនកាយក្រាបប្រណិប័តន៍ និងសម្តែងនូវកត្តញ្ញូកតវេទីតាធម៌ដ៏ខ្ពង់ខ្ពស់ ចំពោះមាតាបិតារបស់កូនៗដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា និងទូន្មានប្រៀនប្រដៅប្រកបដោយព្រហ្មវិហារធម៌ ព្រមទាំងបានលើកទឹកចិត្តផ្នែកស្មារតី និងគាំទ្រផ្នែកធនធាន ដែលជាហេតុធ្វើឱ្យកូនៗបានបន្តការសិក្សាគ្រប់ភូមិសិក្សារហូតមកដល់ឆ្នាំទី៤ នៃថ្នាក់បរិញ្ញាបត្រនេះដោយជោគជ័យ។ កូនៗសូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅ ចំពោះគុណនូបការៈយ៉ាងធំធេងបំផុតរបស់លោកអ្នកទាំងពីរ។ គុណនូបការៈរបស់លោកទាំងទ្វេ គឺពិតជាធំធេងណាស់ដែលធ្វើឱ្យកូនៗមិនអាចបំភ្លេចមិនបាន និងស្ថិតក្នុងចិត្តរបស់កូនៗជារៀងដរាបគ្មានថ្ងៃសូន្យឡើយ។

សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តមសាកលវិទ្យាធិការ ព្រមទាំងលោក-លោកស្រីសាស្រ្តាចារ្យគ្រប់ផ្នែកទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានខិតខំក្នុងការដឹកនាំគ្រប់គ្រង បង្ហាត់បង្រៀន និងសម្របសម្រួលដល់យើងខ្ញុំឱ្យទទួលបាននូវចំណេះដឹង បទពិសោធន៍យ៉ាងច្រើនអនេក ទាំងក្នុងវិស័យនីតិសាស្រ្ត និង វិស័យយុត្តិធម៌ ជាពិសេសទទួលបាននូវការតម្រង់ទិសចំណេះដឹងអំពីស្ថានភាពជាក់ស្តែងក្នុងសង្គមនាពេលបច្ចុប្បន្ន ដែលបានធ្វើឱ្យយើងខ្ញុំក្លាយជាយុវជន យុវតី និស្សិត និងពលរដ្ឋល្អនៅក្នុងសង្គម ដើម្បីជាសសរទ្រូងដ៏រឹងមាំមួយនៃសង្គម និងប្រទេសជាតិទាំងមូល។

សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក **សៅ ស៊ីវុត្ថា** ជាលោកគ្រូណែនាំ ដែលបានជួយបង្ហាត់បង្រៀន ផ្តល់ដំបូន្មាន និងបទពិសោធន៍ ល្អៗដល់យើងខ្ញុំក្នុងការរៀបចំឯកសារសារណាលើប្រធានបទ **"ប្រភេទទោសតាមក្រមព្រហ្មទណ្ឌ"** ដោយទទួលបាននូវលទ្ធផលប្រកបដោយផ្លែផ្កា ដោយលោកបានចំណាយនូវពេលវេលាដ៏មានតម្លៃ ដើម្បីជួយប្រឹក្សា និងផ្តល់នូវអនុសាសន៍ល្អៗ ក្នុងការតាក់តែងស្នាដៃសារណានេះឡើងឱ្យកាន់តែល្អ និងកាន់តែរលូន។

ជាចុងបញ្ចប់ កូនទាំងពីរសូមប្រសិទ្ធិពរជ័យ បួងសួងដល់វត្ថុស័ក្តសិទ្ធិទាំងអស់ដែលមាននៅក្នុងលោកនេះឱ្យជួយតាមថែរក្សាដល់មាតាបិតា ឯកឧត្តមសាកលវិទ្យាធិការ លោក-លោកស្រីសាស្រ្តាចារ្យ ទាំងអស់ឱ្យជួបប្រទះតែពុទ្ធិពរទាំងបួនប្រការពោលគឺៈ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ជាបឋមក្នុងនាមយើងខ្ញុំជានិស្សិតកំពុងសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច សូមគោរពលោកគ្រូអ្នកគ្រូ លោកសាស្រ្តាចារ្យទាំងអស់ ព្រមទាំងស្វាគមន៍ដល់មិត្តៗ អ្នកអាន សិស្ស និស្សិត គ្រប់ៗរូបជាទីរាប់អាន យើងខ្ញុំពិតជាមានក្តីសោមនស្ស រីករាយយ៉ាងក្រៃលែង ដែលមានឱកាសបានរៀបចំនូវសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ក្រោមប្រធានបទមួយស្តីអំពី **"ប្រភេទនៃទោសក្នុងក្រមព្រហ្មទណ្ឌ"** នេះឡើង ដែលមានគោលបំណងចង់ឲ្យអ្នកអានបានយល់ដឹងស៊ីជម្រៅ និងយល់កាន់តែច្បាស់ពីប្រភេទនៃទោសក្នុងក្រមព្រហ្មទណ្ឌដែលបាននឹងកំពុងអនុវត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជាយើងនាពេលបច្ចុប្បន្ននេះ។ នេះជាការកើតចេញពីសមិទ្ធផលនៃ ការខិតខំស្រាវជ្រាវ និងរៀបចំចងក្រងឡើង ដោយផ្អែកលើច្បាប់ និងបទដ្ឋានគតិយុត្តនានា ដើម្បីស្វែងយល់អំពីគោលការណ៍ និងចំណុចស្នូលនៃប្រធានបទមួយនេះផងដែរ។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកគ្រូ **សៅ ស៊ីខុន្ថា** ជាប្រធានការិយាល័យសិក្សានៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានជួយជំរុញទឹកចិត្ត និងបង្ហាត់បង្ហាញ ឆ្លៀតពេលវេលាក្នុងការណែនាំដល់រូបខ្ញុំទាំងពីររហូតអាចបញ្ចប់ការសរសេរសារណានេះ។ សម្រាប់ការស្រាវជ្រាវនេះ យើងខ្ញុំទាំងពីរនាក់បានចំណាយពេលវេលាយ៉ាងសស្រាក់សស្រាំក្នុងការស្វែងរកឯកសារដែលពាក់ព័ន្ធផ្សេងៗដែលមានស្រាប់នៅក្នុងបណ្ណាល័យ និងតាមគេហទំព័រផ្សេងៗ ដើម្បីយកមកចងក្រងបានជាសៀវភៅសារណាមួយនេះឡើង។ យើងខ្ញុំសង្ឃឹមថា សារណាមួយនេះនឹងអាចជាប្រយោជន៍ ក៏ដូចជាជំនួយបន្ថែមដល់ការសិក្សាស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយដែលមានបំណងក្នុងការសិក្សាស្វែងយល់នូវប្រធានបទនេះ។ ទោះជាយ៉ាងណាក៏ដោយ យើងខ្ញុំយល់ថា ការសរសេរ និងរៀបរៀងសរសេរសារណានេះ អាចនៅមានចំនុចខ្វះខាតទាំងពាក្យពេចន៍ និងខ្លឹមសារ មិនទាន់ពេញលេញនៅឡើយទេ ដូច្នេះហើយ យើងខ្ញុំសូមអភ័យទោសទុកជាមុននូវរាល់កំហុសខុសឆ្គងដែលកើតមានឡើងដោយអចេតនា។ យើងខ្ញុំស្វាគមន៍ទទួលមតិរិះគន់ជានិច្ចពីគ្រប់មជ្ឈដ្ឋាន ដើម្បីធ្វើជាទុនក្នុងការស្ថាបនាឲ្យសារណានេះកាន់តែមានអត្ថន័យត្រឹមត្រូវ និងកាន់តែប្រសើរថែមមួយកម្រិតទៀត។

ជាចុងក្រោយ យើងខ្ញុំសូមជូនពរដល់លោកគ្រូ ក៏ដូចជាមិត្តនិស្សិត អស់លោកអ្នកអាន អ្នកសិក្សាស្រាវជ្រាវពិសេសអ្នកដែលស្នេហាវិស័យច្បាប់ទាំងឡាយ ជួបតែសុខដុមរមនា និងជោគជ័យគ្រប់ភារកិច្ច។ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថាយុវជន យុវនារីខ្មែរគ្រប់រូបនឹងខិតខំបន្តសិក្សាស្រាវជ្រាវ ដើម្បីឲ្យក្លាយខ្លួនជាធនធានមនុស្សប្រកបដោយសក្តានុពលក្នុងការចូលរួមអភិវឌ្ឍន៍ប្រទេសជាតិ។

# មាតិកា

**ទំព័រទី**

**សេចក្តីផ្តើម** ............ ១

## ជំពូកទី១
## សញ្ញាណទូទៅនៃទោសព្រហ្មទណ្ឌ

**១.១. និយមន័យនៃទោស** ............ ៣

**១.២. មុខងារនៃទោសព្រហ្មទណ្ឌ** ............ ៤

១.២.១. មុខងារបង្ការទុកជាមុន ............ ៤

១.២.២. មុខងារបង្ក្រាបបទល្មើស ............ ៤

១.២.៣. មុខងារអប់រំ និងធ្វើសមាហរណកម្មចារីចូលទៅក្នុងសង្គមវិញ ............ ៥

**១.៣. ចរិតលក្ខណៈនៃទោស** ............ ៦

១.៣.១. គោលការណ៍នីត្យានុគោលភាពនៃទោស ............ ៦

១.៣.២. ចរិតលក្ខណៈសមភាពនៃទោស ............ ៦

១.៣.៣. គោលការណ៍ឯកត្តជននៃទោស ............ ៧

**១.៤. ទោស និងសញ្ញាណប្រហាក់ប្រហែល** ............ ៧

១.៤.១. ទណ្ឌកម្មដែលពុំមានលក្ខណៈជាទោស ............ ៨

១.៤.២. វិធានការសន្តិសុខ ............ ៩

## ជំពូកទី២
## ទោសដែលត្រូវអនុវត្តចំពោះរូបវន្តបុគ្គល

**២.១. មូលទោស** ............ ១១

២.១.១.និយមន័យនៃមូលទោស ............ ១១

២.១.២. ប្រភេទនៃមូលទោស ............ ១២

២.១.២.១. ទោសដាក់ពន្ធនាគារ ............ ១២

២.១.២.២. ទោសពិន័យជាប្រាក់ ១៣
២.១.៣.ការប្រកាសមូលទោសចំពោះរូបវន្តបុគ្គល ១៣
ក. បទឧក្រិដ្ឋ ១៤
ខ. បទមជ្ឈិម ១៤
គ. បទលហុ ១៤
២.១.៣.១. ការប្រកាសមូលទោសចំពោះរូបវន្តបុគ្គលជានីតិជន ១៥
២.១.៣.២. ការប្រកាសមូលទោសទៅលើរូបវន្តបុគ្គលជាអនីតិជន ១៧
ក. អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ ១៧
ខ.អនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ ១៨
**២.២. ទោសបន្ថែម** ១៩
២.២.១. និយមន័យនៃទោសបន្ថែម (អនុទោស) ១៩
២.២.២. ប្រភេទផ្សេងៗនៃទោសបន្ថែម ២០
២.២.៣. លក្ខខណ្ឌនៃការប្រកាសទោសបន្ថែម ៣៣
២.២.៤. ការប្រកាសទោសបន្ថែមចំពោះរូបវន្តបុគ្គល ៣៣
២.២.៤.១. ការប្រកាសទោសបន្ថែមចំពោះរូបវន្តបុគ្គលជានីតិជន ៣៤
២.២.៤.២. ការប្រកាសទោសបន្ថែមចំពោះរូបវន្តបុគ្គលជាអនីតិជន ៣៥
ក. អនីតិជនដែលមានអាយុក្រោម ១៤ឆ្នាំ ៣៥
ខ.អនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ ៣៦
**២.៣ ទោសជំនួស** ៣៦
២.៣.១. និយមន័យនៃទោសជំនួស ៣៦
២.៣.២. ប្រភេទនៃទោសជំនួស ៣៧
២.៣.២.១. ទោសការងារសហគមន៍ ៣៧
ក. និយមន័យនៃទោសការងារសហគមន៍ ៣៧

ខ. របបគតិយុត្តនៃការងារសហគមន៍ ........ ៣៧
គ. អ្នកមិនទទួលផលប្រយោជន៍នៃការងារសហគមន៍ ........ ៣៨
ឃ. គោលការណ៍ជួសជុលការខូចខាតដល់អ្នកដទៃ ........ ៣៨
២.៣.២.២. ទោសស្តីបន្ទោស ........ ៣៨
ក. និយមន័យនៃទោសស្តីបន្ទោស ........ ៣៩
ខ. របបគតិយុត្តនៃការស្តីបន្ទោស ........ ៣៩
២.៣.៣. ការប្រកាសទោសជំនួស ........ ៣៩
២.៣.៣.១. ការប្រកាសទោសការងារសហគមន៍ ........ ៤០
ក. លក្ខខណ្ឌនៃការប្រកាសទោសការងារសហគមន៍ ........ ៤០
ខ. ការប្រកាសទោសការងារសហគមន៍ ........ ៤០
គ. ការប្រកាសទោសការងារសហគមន៍ទៅលើរូបវន្តបុគ្គលជានីតិជន ........ ៤១
ឃ. ការប្រកាសទោសកាងារសហគមន៍ទៅលើរូបវន្តបុគ្គលជាអនីតិជន ........ ៤២
ឃ.១. អនីតិជនដែលមានអាយុក្រោម ១៦ ឆ្នាំ ........ ៤២
ឃ.២. អនីតិជនដែលមានអាយុយ៉ាងតិច ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ ........ ៤២
២.៣.៣.២ ការប្រកាសទោសស្តីបន្ទោស ........ ៤៣
ក. លក្ខខណ្ឌនៃការប្រកាសទោសស្តីបន្ទោស ........ ៤៣
ខ. ការប្រកាសទោសស្តីបន្ទោសចំពោះរូបវន្តបុគ្គលទាំងពីរប្រភេទ ........ ៤៣

**ជំពូកទី៣**

**ទោសដែលអនុវត្តសម្រាប់នីតិបុគ្គល**

**៣.១ មូលទោសក្នុងប្រភេទជាទោសពិន័យ** ........ ៤៥
**៣.២. ទោសបន្ថែមទាំង១៤ចំណុចកំណត់ដោយក្រមព្រហ្មទណ្ឌ** ........ ៤៦
**៣.៣. ការប្រកាសទោសព្រហ្មទណ្ឌ ចំពោះទោសនីមួយៗទៅលើនីតិបុគ្គល** ........ ៥១
៣.៣.១. នីតិបុគ្គលនៃនីតិសាធារណៈ ឬ នីតិបុគ្គលដែលជារដ្ឋ ........ ៥១

៣.៣.២. នីតិបុគ្គលដែលជានីតិឯកជន ឬ  នីតិបុគ្គលដែលមិនមែនជារដ្ឋ...................................... ៥២
៣.៣.៣. ទោសពិន័យជាប្រាក់ក្នុងឋានៈជាមូលទោស.............................................................. ៥៣
៣.៣.៤. ទោសបន្ថែមទាំង ១៤ ចំណុច ..................................................................................... ៥៣
**សេចក្តីសន្និដ្ឋាន**............................................................................................................. ៥៥
**អនុសាសន៍**.................................................................................................................... ៥៦
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

ក្រមព្រហ្មទណ្ឌ គឺជាបទបញ្ញត្តិសម្រាប់កំណត់អំពើទាំងឡាយណាដែលជាបទល្មើសដោយរួមទាំងធាតុផ្សំនៃបទល្មើសដែលបង្កគ្រោះថ្នាក់ដល់មនុស្ស សង្គម និងការដាក់ទណ្ឌកម្ម ឬ ផ្តន្ទាទោសចំពោះជនប្រព្រឹត្តបទល្មើស និងបណ្តាករណីដែលត្រូវអនុវត្តទៅលើជនដែលត្រូវទទួលទោស ។ ក្រមព្រហ្មទណ្ឌ ឬ យើងហៅសាមញ្ញថាច្បាប់ព្រហ្មទណ្ឌ គឺជាវិធានដែលបង្កើតឡើងក្នុងគោលបំណងដើម្បីការពារសង្គម រក្សាសណ្តាប់ធ្នាប់ និងរបៀបរៀបរយ តាមរយៈការដាក់ទោសទៅលើអ្នកដែលបានប្រព្រឹត្តល្មើស។ ចរិតនៃក្រមព្រហ្មទណ្ឌនេះមានលក្ខណៈកែលម្អផង និងបង្ខិតបង្ខំផង។ រាល់មាត្រានីមួយៗនៅក្នុងក្រមព្រហ្មទណ្ឌ សុទ្ធតែបានឲ្យនិយមន័យនៃអំពើល្មើសនានាដែលចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌ ដែលអំពើទាំងនោះបានធ្វើឲ្យប៉ះពាល់ដល់សណ្តាប់សន្តិសុខ និងរបៀបរៀបរយសង្គម ហើយព្រមទាំងបានកំណត់អំពីទោសផងដែរដែលក្នុងនោះមានអប្បបរមានៃទោស និងអតិបរមានៃទោស។ បទល្មើស និងទោសព្រហ្មទណ្ឌត្រូវបានកំណត់ពីគោលការណ៍គឺ គោលការណ៍នីត្យានុកូលភាពនៃបទល្មើស និងគោលការណ៍នីត្យានុកូលភាពនៃទោស តាមមាត្រា៣ នៃក្រមព្រហ្មទណ្ឌបានចែងថា មានតែអំពើដែលបង្កើតជាបទល្មើសនៅពេលដែលអំពើនោះមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន។ មានតែទោសដែលមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាននៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តប៉ុណ្ណោះ ទើបអាចត្រូវប្រកាសបាន។ គ្មានបទល្មើស គ្មានទោសបើគ្មានច្បាប់ចែង។ ក្រមព្រហ្មទណ្ឌការពារប្រយោជន៍ស្របច្បាប់របស់មនុស្ស និងប្រយោជន៍របស់សង្គម។ ក្រមព្រហ្មទណ្ឌបញ្ញត្តិ អំពីបទល្មើស និងការអនុវត្តទោសទៅលើជនដែលរំលោភបំពានលើប្រយោជន៍ខាងលើ។ ទណ្ឌកម្មត្រូវបានយកទៅអនុវត្តដោយពុំមានគោលបំណង បង្កឱ្យមានការឈឺចាប់លើរូបរាងកាយបុគ្គល ឬបន្ទាបបន្ថោកកេរ្តិ៍ឈ្មោះ ឬ កិត្តិយសជនល្មើសឡើយ សំខាន់បំផុតគឺមានគោលបំណងអប់រំជនល្មើសឱ្យប្រែក្លាយជាពលរដ្ឋ ជាសមាជិកល្អបរិសុទ្ធដែលធ្វើការមានប្រយោជន៍ដល់សង្គមជាតិ។ ក្រមព្រហ្មទណ្ឌ បានបញ្ញត្តិនូវស្ថានភាពសន្តោសប្រោសប្រណី ជាច្រើនដើម្បីផ្តល់ឱកាសឱ្យជនល្មើសបានកែប្រែខ្លួនឱ្យក្លាយជាមនុស្សល្អក្នុងសង្គម ។

ទោសព្រហ្មទណ្ឌ គឺសំដៅដល់ទណ្ឌកម្មដែលត្រូវបានប្រកាសដោយតុលាការ សម្រាប់អនុវត្តចំពោះបុគ្គលបានប្រព្រឹត្តបទល្មើសរួមមានដូចជា ចារី សហចារី អ្នកផ្តើមគំនិត អ្នកសមគំនិត ជាដើម ដែលជាតួអង្គដ៏សំខាន់ក្នុងការប្រព្រឹត្តបទល្មើស។ បទល្មើសជាទូទៅដើម្បីកំណត់ថាអំពើរបស់ខ្លួនប៉ុណ្ណោះ។ ទោសព្រហ្មទណ្ឌកំណត់ដោយក្រមព្រហ្មទណ្ឌចែកចេញជា ៣ប្រភេទគឺ មូលទោស ទោសបន្ថែម និងទោសជំនួស។ ទោសទាំងបីប្រភេទនេះ ត្រូវបានតុលាការយកទៅអនុវត្តចំពោះ រូបវន្តបុគ្គល និងនីតិបុគ្គលដែលជាប្រធាននៃបទល្មើស ឱ្យ

ស្របតាមគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ មានន័យថាបុគ្គលម្នាក់ៗទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនប៉ុណ្ណោះ។ ដើម្បីកំណត់ថាអំពើរបស់បុគ្គលណាម្នាក់បានប្រព្រឹត្ត ហើយបង្កើតបានជាបទល្មើសអ្វីមួយនោះ ជាទូទៅចាំបាច់ត្រូវមានធាតុផ្សំ ដែលធាតុផ្សំនៃបទល្មើសមាន ៣គឺ ធាតុនីត្យានុកូល ធាតុសត្យានុម័ត និងធាតុអត្តនោម័ត។ បើកាលណា ធាតុផ្សំទាំងបីនេះត្រូវបានបំពេញ សបញ្ជាក់ឱ្យឃើញថាសកម្មភាពរបស់បុគ្គលម្នាក់នោះ គឺបានបង្កើតជាបទល្មើស ច្បាប់បានបញ្ញត្តិថាអំពើខ្លះរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបង្កចលាចលដល់សង្គមគឺជាបទល្មើស។ បទល្មើសត្រូវបានចាត់ថ្នាក់ជា ៣គឺ បទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ ទៅតាមទម្ងន់នៃបទល្មើសនោះ។

តើប្រភេទនៃទោសក្នុងព្រហ្មទណ្ឌមានអត្ថន័យយ៉ាងណា? ហើយថាតើអ្វីទៅជាសញ្ញាណទូទៅនៃទោសព្រហ្មទណ្ឌ ព្រមទាំងបែបបទនៃការអនុវត្តទោសចំពោះរូបវន្តបុគ្គល និងការអនុវត្តទោសចំពោះនីតិបុគ្គលដូចម្តេច? ក្នុងទំហំនៃការសរសេរសារណានេះ ដើម្បីឱ្យមានភាពងាយស្រួល និងយល់ពីប្រធានបទខាងលើបានកាន់តែច្បាស់លាស់ យើងខ្ញុំនឹងធ្វើការបែងចែកសារណានេះចេញជា ៣ជំពូកដូចខាងក្រោម៖

**ជំពូកទី ១ ៖ សញ្ញាណទូទៅនៃទោសព្រហ្មទណ្ឌ**

**ជំពូកទី ២ ៖ ទោសអនុវត្តចំពោះរូបវន្តបុគ្គល**

**ជំពូកទី ៣ ៖ ទោសអនុវត្តចំពោះនីតិបុគ្គល**

# ជំពូកទី ១
# សញ្ញាណទូទៅនៃទោស
# ព្រហ្មទណ្ឌ

# ជំពូកទី ១
# សញ្ញាណទូទៅនៃទោសព្រហ្មទណ្ឌ

## ១.១. និយមន័យនៃទោស

ទោស គឺជាទណ្ឌកម្មព្រហ្មទណ្ឌដែលមានចែងនៅក្នុងច្បាប់ ហើយដែលចៅក្រមអាចយកទៅអនុវត្តលើចារី នៃបទល្មើសបាន។ ហើយទោស គឺជាទណ្ឌកម្មផ្តន្ទាដោយសង្គមតាមរយៈច្បាប់ទៅលើជន ដែលប្រព្រឹត្តល្មើស[1]។ ទណ្ឌកម្មកើតចេញពីពាក្យ ទណ្ឌ បូក កម្ម ។ កម្ម ប្រែថា អំពើ ។ ឯពាក្យ ទណ្ឌ ប្រែថា ការធ្វើទោស ដែលត្រូវផ្តន្ទា ដោយផ្ទាល់តាមដំណើររឿងនៃអំពើដែលបានប្រព្រឹត្តខុសនឹងបទប្បញ្ញត្តិនៃច្បាប់[2]។ ទោសត្រូវបានកំណត់ឡើង នៅក្នុងគោលដៅការពារផលប្រយោជន៍សាធារណៈដែលជាផលប្រយោជន៍របស់សង្គមទាំងមូល។ ទោស គឺជា ទណ្ឌកម្មដែលត្រូវផ្តន្ទាទៅលើរូបវន្តបុគ្គលឬនីតិបុគ្គល ដែលមានកំហុសប្រកបដោយទោស ។ ទោសនេះត្រូវអនុវត្ត ចំពោះតែបុគ្គលទាំងឡាយណាដែលតុលាការរកឃើញថា មានកំហុសព្រោះបានប្រព្រឹត្តខុសនឹងបទប្បញ្ញត្តិ ទាំងឡាយនៃក្រមព្រហ្មទណ្ឌជាធរមាន[3]។

តាមគោលការណ៍នៃនីតិព្រហ្មទណ្ឌ ទណ្ឌកម្ម ត្រូវបានគេចាត់ទុកជាវិធានការតែមួយគត់ និងជាលើកចុង ក្រោយបង្អស់របស់រដ្ឋដែលត្រូវសម្រេចផ្តន្ទាចំពោះជនទាំងឡាយណាដែលតុលាការរកឃើញថា ជាជនមាន កំហុសដែលគួរដល់ការដាក់ទោស។ ការដាក់ទោសនេះ ត្រូវសម្រេចដោយតុលាការព្រហ្មទណ្ឌដោយរាទៅតាម អង្គហេតុ និងអង្គច្បាប់ ព្រមទាំងទំហំសមត្ថភាពនៃការទទួលខុសត្រូវរបស់ជនប្រព្រឹត្តបទល្មើស ឬ បានចូលរួម ប្រព្រឹត្តបទល្មើស។ ជាគោលការណ៍ ការដាក់ទោសនិងការអនុវត្តទោសទៅបុគ្គលណាមួយអាចប្រព្រឹត្តទៅបាន លុះត្រាតែបុគ្គលនោះបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយប៉ះពាល់ដល់អំណាចនៃច្បាប់ដែលនៅជាធរមាន បញ្ញត្តិ ហើយត្រូវបានតុលាការមានសមត្ថកិច្ចសម្រេចរឿងហេតុនេះដល់អង្គសេចក្តីរួចហើយ ហើយទោសនេះ ត្រូវបានប្រកាសចូលជាស្ថាពរតាមអំណាចផ្លូវច្បាប់។ ហេតុនេះ ក្នុងករណីដែលតុលាការមិនទាន់បានប្រកាស ទោសជាស្ថាពរនៅឡើយទេ ជាគោលការណ៍ គ្មានបុគ្គលណាម្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូលត្រូវ បានគេចាត់ទុកជាជនជាប់ទោសបានឡើយ ហើយទណ្ឌកម្មក៏មិនអាចអនុវត្តបានដែរ វៀរលែងតែមានបទ ប្បញ្ញត្តិពិសេសដោយឡែកប៉ុណ្ណោះ។ តាមគោលការណ៍ច្បាប់ព្រហ្មទណ្ឌ ទណ្ឌកម្ម ជាវិធានដែលត្រូវសម្រេច ដោយអាជ្ញាធរតុលាការ ដើម្បីបង្ការ និងបង្ក្រាបបទល្មើស ព្រមទាំងកំណត់អំពីទំហំសមត្ថភាពនៃការទទួលខុស

1 លោកគ្រូ មីន សំអុល, នីតិព្រហ្មទណ្ឌទូទៅ, បោះពុម្ពឆ្នាំ២០២០, ៥០។

2 សម្រង់មេរៀនស្តីពីនីតិព្រហ្មទណ្ឌខ្មែរ ត្រង់ចំណុច "ទោសព្រហ្មទណ្ឌ" ឧទ្ទេសនាមដោយឯកឧត្តម សេង ស៊ីវុត្ថា អនុប្រធានសាលា ឧទ្ធរណ៍ សម្រាប់កម្មសិក្សាការីមន្ត្រីជាន់ខ្ពស់នៃសាលាភូមិន្ទរដ្ឋបាល ឆ្នាំសិក្សា២០១០-២០១១, ៥៩។

3 លោកគ្រូ មីន សំអុល, នីតិព្រហ្មទណ្ឌទូទៅ, បោះពុម្ពឆ្នាំ២០២០, ៥០។

ត្រូវដល់ជនប្រព្រឹត្តបទល្មើស ឬ ដែលបានចូលរួមប្រព្រឹត្តបទល្មើស។ ការដាក់ទោស ជាវិធានការតែមួយគត់របស់រដ្ឋដែលត្រូវប្រើប្រាស់ជាមធ្យោបាយចុងក្រោយ បង្អស់ ដើម្បីនិគ្រោះបទល្មើសឱ្យថយចុះជាសត្យានុម័ត ហើយជាយថាហេតុរដ្ឋក៏គ្មានលទ្ធភាពជ្រើសរើស មធ្យោបាយណាផ្សេងក្រៅពីការដាក់ទោសនេះដែរ តែការដាក់ទោសនេះមិនមែនមានន័យថា ជាការធ្វើទុក បុកម្នេញលើជនជាប់ទោសនោះឡើយ ហើយរដ្ឋក៏គ្មានគោលបំណងណាមួយធ្វើទុក្ខទោសជាទារុណកម្មដែលបណ្តាលឱ្យជនជាប់ទោសណាមួយមានការឈឺចាប់ខាងផ្លូវកាយ ឬ ផ្លូវចិត្តឡើយ ហើយសូម្បីការគំរាមកំហែង ការកៀបសង្កត់ ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬ ការប្រព្រឹត្តកម្មណាមួយដែលបណ្តាលឱ្យជននេះទទួលនូវស្ថានទម្ងន់នៃទោស ទោះដោយចំពោះ ឬ ដោយប្រយោលក្តី ក៏ត្រូវបានហាមឃាត់ដោយច្បាប់ដែរ។ ទណ្ឌកម្មព្រហ្មទណ្ឌដែលកំណត់ដោយច្បាប់ព្រហ្មទណ្ឌខ្មែរសម័យទំនើបនេះ មានគោលបំណងសំខាន់មួយចំនួនដូចជាៈ ទប់ស្កាត់ បង្ការនិងការបង្ក្រាបបទល្មើស កែលម្អចិត្តគំនិតជនប្រព្រឹត្តបទល្មើសឱ្យទទួលស្គាល់កំហុសរបស់ខ្លួន ហើយឈប់ប្រព្រឹត្តបទល្មើសជាថ្មីទៀត ផ្តល់យុត្តិធម៌ឱ្យជនរងគ្រោះ ស្តារនិងការពារសន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ[4]។

## ១.២. មុខងារនៃទោសព្រហ្មទណ្ឌ

មុខងារនៃទោសព្រហ្មទណ្ឌមានដូចតទៅៈ

### ១.២.១. មុខងារបង្ការទុកជាមុន

មុខងារទី១របស់ទោសព្រហ្មទណ្ឌ គឺមុខងារបង្ការទុកជាមុន វាមានគោលដៅបំផិតបំភ័យធ្វើឲ្យមានការខ្លាចរអា និងបង្ការ។ ទីមួយគឺឲ្យអ្នកដែលប្រព្រឹត្តបទល្មើសទទួលរងសមល្មមនឹងអំពើដែលខ្លួនប្រព្រឹត្ត ហើយខ្លាចរអាថ្ងៃក្រោយ ចៀសវាង ហើយមិនប្រព្រឹត្តបទល្មើសសាជាថ្មីម្តងទៀត ហើយមានអានុភាពមួយទៀត គឺអានុភាពបង្ការដល់សាធារណជន ដល់សមាជិកសង្គមទាំងមូល ជាពិសេសអ្នកដែលកំពុងស្ថិតនៅលើផ្លូវនៃការប្រព្រឹត្តបទល្មើស ធ្វើការបោះបង់ចោលនូវគម្រោងនៃការប្រព្រឹត្តបទល្មើសរបស់ខ្លួនដោយយល់ឃើញថា ទោសព្រហ្មទណ្ឌមានលក្ខណៈធ្ងន់ធ្ងរ ហើយបើគាត់ប្រព្រឹត្តបទល្មើសគាត់នឹងទទួលវាសនាដូចចារី ឬ អ្នកដែលទទួលរងទោសព្រហ្មទណ្ឌសព្វថ្ងៃដែរ។ នេះជាគោលដៅ ឬ មុខងារទីពីរនៃទោសព្រហ្មទណ្ឌ។

### ១.២.២. មុខងារបង្ក្រាបបទល្មើស

មុខងារបង្ក្រាបបទល្មើស សំដៅដល់ការដាក់ទណ្ឌកម្មលើអ្នកដែលប្រព្រឹត្តបទល្មើស ឬ ចារីដែលបានប្រព្រឹត្តនូវបទល្មើសឱ្យទទួលរងនូវការឈឺចាប់ ឬ ទទួលរងនូវផលវិបាកឱ្យខ្លាំងក្លាជាការឆ្លើយតបនឹងសកម្មភាពដែលរំខានដល់សង្គម ដែលបង្កដោយបទល្មើសរបស់ខ្លួន នេះជាមុខងារទី២នៃទោសព្រហ្មទណ្ឌ។

[4] សម្រង់មេរៀនស្តីពីនីតិព្រហ្មទណ្ឌខ្មែរ ត្រង់ចំណុច "ទោសព្រហ្មទណ្ឌ" ឧទ្ទេសនាមដោយឯកឧត្តម សេង ស៊ីវុត្ថា អនុប្រធានសាលាឧទ្ធរណ៍ សម្រាប់កម្មសិក្សាការីមន្ត្រីជាន់ខ្ពស់នៃសាលាភូមិន្ទរដ្ឋបាល ឆ្នាំសិក្សា២០១០-២០១១, ៥០។

### ១.២.៣. មុខងារអប់រំ និងធ្វើសមាហរណកម្មជាវិចូលទៅក្នុងសង្គមវិញ

ចំពោះមុខងារទី៣ គឺជាមុខងារសម័យថ្មី សម័យទំនើបនៃទោសព្រហ្មទណ្ឌគឺដែលមានមុខងារសំដៅធ្វើយ៉ាងណាសម្រួល អប់រំកែប្រែ សម្រួលបណ្ឌិត និងធ្វើយ៉ាងណាធានាឲ្យទណ្ឌិត អាចធ្វើសមាហរណកម្មទៅក្នុងសង្គមបាន។ នេះជាមុខងារសំខាន់ ព្រោះអ្នកប្រាជ្ញព្រហ្មទណ្ឌបានសិក្សាឃើញថា ទោសព្រហ្មទណ្ឌដែលមានគោលដៅដាក់ទណ្ឌកម្មតែមួយមុខនោះ គឺពុំមានផលប្រយោជន៍ចំពោះសង្គមខ្លាំងក្លានោះទេ ដូច្នេះហើយទើបគេពិនិត្យទៅដល់ការដែលធ្វើយ៉ាងដូចម្តេចដើម្បីឲ្យទណ្ឌិតដែលទទួលទោសនោះរួច អាចកែប្រែ អាចធ្វើសមាហរណកម្មទៅក្នុងសង្គមវិញ ទើបមានផលប្រយោជន៍ដល់សង្គម។ ហើយអ្នកប្រាជ្ញខាងនីតិព្រហ្មទណ្ឌបានសិក្សាអំពីការវាយតម្លៃ អំពីសុវត្ថិភាពសន្តិសុខសង្គម លើកត្តាសំខាន់មួយដែរគឺផ្អែកទៅលើឥរិយាបថ និងសកម្មភាពរបស់ទណ្ឌិតដែលអនុវត្តទោសរួច បើសិនជាទណ្ឌិតដែលអនុវត្តទោសរួចហើយអាចធ្វើសមារណកម្មក្នុងសង្គមវិញ កែប្រែទៅជាមនុស្សល្អបានមួយរយភាគរយមានន័យថាសង្គមនៅថ្ងៃអនាគតនឹងមានសន្តិសុខខ្ពស់ និងពុំមានអ្នកដែលប្រព្រឹត្តបទល្មើសទៀតនោះឡើយ។ ផ្ទុយទៅវិញ បើសិនជាទណ្ឌិតដែលចេញពីពន្ធនាគារហើយប្រព្រឹត្តបទល្មើស មានន័យថាវាប៉ះពាល់ខ្លាំងដល់សន្តិសុខសង្គម គឺមានន័យថាប្រព័ន្ធនៃការបង្ក្រាបរបស់រដ្ឋគឺពុំទាន់មានប្រសិទ្ធភាពខ្ពស់ ហើយវានឹងប៉ះពាល់ដល់ផ្លូវចិត្ត ចិត្តសាស្ត្រ ក៏ដូចជាសន្តិសុខសណ្តាប់ធ្នាប់សារណៈទាំងមូលដែលនេះជាកត្តាមួយសំខាន់ក្នុងក្នុងការវាយតម្លៃ អំពីសន្តិសុខសុវត្ថិភាពសង្គម ជាពិសេសពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើស។ ហេតុដូច្នេះហើយក្នុងក្របខ័ណ្ឌនៃការធានាសម្រួលទណ្ឌិត ការអប់រំកែប្រែទណ្ឌិត និងធានាសមាហរកម្មទណ្ឌិតទៅក្នុងសង្គមវិញ ក្រមព្រហ្មទណ្ឌបានប្រកាន់យកនិន្នាការនេះ គឺផ្តោតជាពិសេសទៅលើមុខងារទីបីនៃទោសព្រហ្មទណ្ឌ គឺការអប់រំកែសម្រួលទណ្ឌិតដើម្បីអាចធ្វើសមាហរណកម្មទៅក្នុងសង្គមវិញ ហើយបានកំណត់ជាគោលការណ៍ជាច្រើនដូចជា គោលការណ៍ឯកត្តកម្មនៃទោស និងយន្តការផ្សេងៗទៀតដើម្បីជ្រើសរើសទោសឱ្យសមស្របទៅនឹងបុគ្គលភាពនៃជនល្មើសហើយអាចកែសម្រួល និងធ្វើសមាហរណកម្មទណ្ឌិតទៅក្នុងសង្គមវិញ[5]។

[5] យោងប្រសាសន៍របស់ ឯកឧត្តម ផូវ សំភី នៅក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពី "ក្រមព្រហ្មទណ្ឌ" រៀបចំឡើងដោយក្រសួងយុត្តិធម៌សហការជាមួយក្រសួងព័ត៌មានតាមរយៈទូរទស្សន៍ជាតិកម្ពុជា។

## ១.៣. ចរិតលក្ខណៈនៃទោស

ទោសមានចរិតលក្ខណៈបីយ៉ាងសំខាន់ៗគឺៈ

### ១.៣.១. គោលការណ៍នីត្យានុគោលភាពនៃទោស

ចរិតលក្ខណៈនីត្យានុកូលនៃទោស មានតែទោសដែលមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាន នៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តប៉ុណ្ណោះ ទើបអាចត្រូវប្រកាសបាន[6]។ មានន័យថា គ្រប់ទោសទាំងអស់ត្រូវតែចែងយ៉ាងច្បាស់ដោយច្បាប់ ។ ផ្ទុយទៅវិញ ប្រសិនបើពុំមានច្បាប់ចែងទេ ទោសក៏ពុំអាចយកមកអនុវត្តបានដែរ។ នេះគឺជា អ្វីដែលគេតែងតែហៅថា «គោលការណ៍នីត្យានុកូលភាពនៃទោស»។

**ឧទាហរណ៍** : មាត្រា៧៨ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ១៩៨៩ កំណត់ថា ការមិនព្រមបង់អាហារកិច្ចចាត់ទុកជាបទល្មើសព្រហ្មទណ្ឌ ដែលនឹងត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។ ក៏ប៉ុន្តែ រហូតដល់មុនពេលដែលក្រមព្រហ្មទណ្ឌត្រូវអនុវត្តនៅ អំឡុងខែធ្នូ ឆ្នាំ ២០១០ ពុំមានបទបញ្ញត្តិច្បាប់ណាមួយដែលផ្តន្ទាទោសលើការមិនព្រមបង់អាហារកិច្ចតាមសេចក្តីសម្រេចរបស់តុលាការទេ។ ហេតុដូច្នេះហើយ ទើបបានជាតុលាការមិនអាចធ្វើការផ្តន្ទាទោសអំពើដែលមានចែងនៅមាត្រា ៧៨ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារឡើយ ដោយហេតុថាពុំមានច្បាប់ដែលបានកំណត់ពីទោសដែលត្រូវអនុវត្តទៅលើបទល្មើសនេះឡើយ[7]។

### ១.៣.២. ចរិតលក្ខណៈសមភាពនៃទោស

ចរិតលក្ខណៈសមភាពនៃទោស ជាការចែងពីទោសពុំត្រូវមានមូលដ្ឋានផ្អែកទៅលើលក្ខខណ្ឌសង្គមរួមមានដូចជា រូបសម្បត្តិ ភេទ ទ្រព្យសម្បត្តិ ។ល។ នៃបុគ្គលដែលត្រូវផ្តន្ទាទោសនោះទេ។ នេះជាការអនុវត្តនូវគោលការណ៍សមភាពរវាងពលរដ្ឋគ្រប់រូប[8]។ មានន័យថា ទោសដែលត្រូវផ្តន្ទាចំពោះជនល្មើស គឺស្មើៗគ្នាទាំងអស់ដោយគ្មានការរើសអើង ភេទ អាយុ សញ្ជាតិ ជនជាតិ អ្វីឡើយ ឱ្យតែបុគ្គលណាប្រព្រឹត្តល្មើស បុគ្គលនោះត្រូវរងទោសតែមួយដូចគ្នា។

**ឧទាហរណ៍** : មាត្រា១៩៩ នៃក្រមព្រហ្មទណ្ឌបានកំណត់ទោសដាក់ ពន្ធនាគារពី ១០ឆ្នាំ ទៅ ១៥ឆ្នាំ សម្រាប់ បទឃាតកម្ម ដោយមិនបានធ្វើការបញ្ជាក់ថា ទោសនេះត្រូវអនុវត្តតែទៅលើបុរស ឬ ស្ត្រី អ្នកមាន ឬ អ្នកក្រីក្រឡើយ។

---

[6] មាត្រា៣ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ២០០៩ ស្តីអំពី "គោលការណ៍នីត្យានុកូលភាពនៃទោស"។

[7] សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ, នីតិព្រហ្មទណ្ឌទូទៅ, កែសម្រួលដោយ ចាំង ស៊ីណាត,២០១២,២៩៤។

8 មាត្រា៣១ កថាខណ្ឌទី ២ វាក្យខណ្ឌទី ១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចែងថា : ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនានិន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ ។

### ១.៣.៣. គោលការណ៍ឯកត្តជននៃទោស

ចរិតលក្ខណៈឯកត្តជននៃទោស នាំមកនូវគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ។ តាមគោលការណ៍ខាងលើ ការទទួលខុសត្រូវព្រហ្មទណ្ឌ និងទោសទណ្ឌផ្សេងៗទៀតត្រូវតែផ្តន្ទាទៅលើជនណាដែលបានប្រព្រឹត្តបទល្មើសតែប៉ុណ្ណោះ បានន័យថា មានតែជនដែលបានចូលរួមដោយផ្ទាល់ក្នុងការប្រព្រឹត្តបទល្មើសនោះទេ ដែលត្រូវបានចាត់ទុកថាជា ជនល្មើស ហើយត្រូវតែទទួលទោស។ គោលការណ៍នេះបានហាមឃាត់ការទទួលខុសត្រូវជាក្រុម ដែលគេតែងតែអនុវត្តកាលពីសម័យមុន មានន័យថា បើជនណាម្នាក់បានប្រព្រឹត្តបទល្មើស សមាជិកក្រុមគ្រួសារទាំងមូលរបស់ជនល្មើសត្រូវតែទទួលទោសរួមគ្នាតែម្តង។ ម្យ៉ាងវិញទៀត គោលការណ៍ខាងលើក៏បានហាមឃាត់ការទទួលខុសត្រូវព្រហ្មទណ្ឌដោយសារអំពើរបស់អ្នកដទៃផងដែរ បានសេចក្តីថា ត្រូវហាមឃាត់ដាច់ខាតដល់ការដាក់ទណ្ឌកម្មជនណាម្នាក់ ដោយសារតែជនម្នាក់ផ្សេងទៀតបានប្រព្រឹត្តបទល្មើស ដោយពុំអាចឲ្យនរណាម្នាក់មកទទួលទោសជំនួសអ្នកប្រព្រឹត្តឡើយ អ្នកណាដែលប្រព្រឹត្តអ្នកនោះគឺជាអ្នកទទួលខុសត្រូវ (សក់អ្នកណាក្បាលអ្នកហ្នឹង)។

គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានទទួលស្គាល់យ៉ាងជាក់ច្បាស់ដោយមាត្រា២៤ នៃក្រមព្រហ្មទណ្ឌដែលបានចែងថា : បុគ្គលម្នាក់ៗទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនប៉ុណ្ណោះ[9]។

**ឧទាហរណ៍:** ឈ្មោះ (ក) បានសម្លាប់ឈ្មោះ (ខ) ដោយសារតែមានទំនាស់រឿងព្រំដីជាមួយនឹងក្រុមគ្រួសាររបស់ខ្លួន។ ក្នុងករណីនេះមានតែ ឈ្មោះ (ក) ទេដែលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ចំណែកឯឪពុកម្តាយរបស់ឈ្មោះ (ក) មិនបានដឹងពីរឿងនេះទេ ហើយក៏មិនបានចូលរួមក្នុងការប្រព្រឹត្តសកម្មភាពល្មើសច្បាប់នេះដែរ។ ហេតុនេះឪពុកម្តាយរបស់ឈ្មោះ (ក) មិនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌជាមួយនឹងឈ្មោះ (ក) ឡើយ គឺមានតែឈ្មោះ (ក) ម្នាក់ឯងប៉ុណ្ណោះ ដែលត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌ។

## ១.៤. ទោស និងសញ្ញាណប្រហាក់ប្រហែល

ទោសនិងសញ្ញាណដែលប្រហាក់ប្រហែលទោសគឺជាទណ្ឌកម្មដែលត្រូវបានប្រកាសដោយចៅក្រមព្រហ្មទណ្ឌ ដើម្បីផ្តន្ទាចំពោះបទល្មើសណាមួយ[10]។ ក្នុងន័យនេះ ទោស គឺខុសប្លែកពីទណ្ឌកម្មដទៃទៀតដែល ពុំមានលក្ខណៈជាទោស **(១.៤.១.)** និងខុសប្លែកពីវិធានការសន្តិសុខនានា **(១.៤.២)**។

9 មាត្រា២៤ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ២០០៩ ស្តីអំពី "គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ"។

10 សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ, នីតិព្រហ្មទណ្ឌទូទៅ, កែសម្រួលដោយ ចាំង ស៊ីណាត,២០១២,២៩៦។

### ១.៤.១. ទណ្ឌកម្មដែលពុំមានលក្ខណៈជាទោស

ការរំលោភបំពានលើកាតព្វកិច្ចណាមួយ អាចនាំឲ្យមានទណ្ឌកម្មច្រើនប្រភេទដូចជា ទណ្ឌកម្មរដ្ឋប្បវេណី ទណ្ឌកម្មរដ្ឋបាល និងទណ្ឌកម្មព្រហ្មទណ្ឌ ជាដើម។

ទណ្ឌកម្មរដ្ឋប្បវេណីពុំមែនជាទោសព្រហ្មទណ្ឌទេ[11] ពីព្រោះថាមានគោលដៅគ្រាន់តែជាការជួសជុលដល់ការខូចខាតដែលបានបង្កឡើងដល់ជនរងគ្រោះ ហើយដោយតម្រូវឲ្យចារីត្រូវតែសងការខូចខាតដែលជនរងគ្រោះបានទទួលរងជាដើម។

ម្យ៉ាងវិញទៀតក្នុងករណីខ្លះច្បាប់បានផ្តល់អំណាចក្នុងការដាក់ទណ្ឌកម្មផ្សេងៗ ទៅឲ្យអាជ្ញាធររដ្ឋបាលដោយគ្រាន់តែពិនិត្យមើលមួយភ្លែតទៅ គឺជាទណ្ឌកម្មដែលមានលក្ខណៈប្រហាក់ប្រហែលទៅនឹងទោសក្នុងរឿងព្រហ្មទណ្ឌដែរ ក៏ប៉ុន្តែតាមការពិតទៅពុំមែនជាទោសព្រហ្មទណ្ឌនោះទេ។

**ឧទាហរណ៍**: ទាក់ទងនឹងបទបញ្ញត្តិនៃមាត្រា៣៤ នៃច្បាប់ស្តីពី របបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ ដែលបានប្រកាសឲ្យប្រើនៅថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០២ ត្រង់កថាខណ្ឌទី ២ ចែងថា : ការពិន័យជាប្រាក់ត្រូវដាក់បង្ខំដោយនាយកនៃបេឡាជាតិរបបសន្តិសុខសង្គម ។ ការទារប្រាក់ពិន័យនេះស្ថិតក្រោមបទបញ្ញត្តិអាជ្ញាយុកាលនៃបណ្តឹងរដ្ឋប្បវេណីចំនួន ៥ ឆ្នាំ គិតពីកាលបរិច្ឆេទនៃការចេញលិខិតដាក់កំហិតរយៈពេល ១៥ ថ្ងៃមក ដោយមិនមានទាក់ទងនឹងបណ្តឹងសាធារណៈ ឬ បន្ទាប់ពីការកន្លងផុតនៃបណ្តឹងសាធារណៈទេ[12]។ ការដាក់ពិន័យខាងលើជាទណ្ឌកម្មមួយប្រភេទ តែពុំមែនជាទោសព្រហ្មទណ្ឌឡើយ ព្រោះថា ជាទូទៅទោសព្រហ្មទណ្ឌ ស្ថិតក្រោមសមត្ថកិច្ចរបស់តុលាការ។ ជាងនេះទៅទៀត ច្បាប់ខ្លះចែងអំពី ពិន័យអន្តរការណ៍។

ជាក់ស្តែង មាត្រា២១ កថាខណ្ឌទី ១ នៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់ គ្រងធនធានធម្មជាតិ ប្រកាសឲ្យប្រើនៅថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ កំណត់ថា : បុគ្គលណាមិនអនុញ្ញាត ឬ រារាំងមិនឲ្យមន្ត្រីអធិការកិច្ចចូលធ្វើការត្រួតពិនិត្យ ឬ ធ្វើអធិការកិច្ចលើទីតាំងដូចមានចែងក្នុងច្បាប់ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី ៥០០.០០០ រៀលដល់ ១.០០០.០០០ រៀល ។ ពិន័យអន្តរការណ៍មិនត្រូវបាន ចាត់ទុកជាទោសព្រហ្មទណ្ឌទេ ក៏ប៉ុន្តែគឺជាទណ្ឌកម្មដែលមានលក្ខណៈប្រហាក់ ប្រហែលនឹងទោសដែរ។

[11] ពេលខ្លះ គេប្រើពាក្យ ទោសរដ្ឋប្បវេណី ដែលសំដៅលើអំពើអនីត្យានុកូលដែលនាំឲ្យមានការទទួលខុសត្រូវរដ្ឋប្បវេណី។

[12] មាត្រា៤០ កថាខណ្ឌទី២ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិច្បាប់ស្តីពីការងារ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០២។

### ១.៤.២. វិធានការសន្តិសុខ

វិធានការសន្តិសុខក៏មានលក្ខណៈប្រហាក់ប្រហែលនឹងទោសដែរ ក៏ប៉ុន្តែមានលក្ខណៈខុសប្លែកពីទោសខ្លះៗ។ ច្បាប់ស្តីការត្រួតពិនិត្យគ្រឿងញៀនបានចែងពី វិធានការព្យាបាល។ មាត្រា ៦២ ថ្មី នៃច្បាប់កំណត់ថា : កាលបើជនញៀនគ្រឿងញៀនត្រូវផ្តន្ទាទោសដោយបទល្មើសណាមួយដែលមានចែងក្នុងមាត្រា ៣១ថ្មីដល់ ៤០ ថ្មី នៃច្បាប់នេះ តុលាការអាចចាត់បន្ថែមលើទោសនូវវិធានការ ព្យាបាលដែលមានចែងក្នុងផ្នែកទី ២ នៃជំពូកទី ២៤ ។

វិធានការព្យាបាល អាចត្រូវបានដាក់បង្ខំដោយព្រះរាជអាជ្ញា ឬ តុលាការ ឬ ក៏ដោយស្ម័គ្រចិត្តពីសំណាក់ជនដែលញៀនថ្នាំ។ សូមបញ្ជាក់ផងដែរថា មាត្រា៩៨ ថ្មី កថាខណ្ឌទី ១ និង ទី ២ បានចាត់ទុកជាបទល្មើសនូវ ការរក្សាទុក ទិញ ឬ ដាំដុះដោយចេតនាសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន ឬ ប្រើប្រាស់ផ្ទាល់ខ្លួននូវរុក្ខជាតិ ឬ សារធាតុដែលចាត់ទុកថាជាថ្នាំញៀន ឬ សារធាតុដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ។ ក៏ប៉ុន្តែ ប្រសិនបើជនប្រើប្រាស់គ្រឿងញៀនចូលខ្លួនដោយខ្លួនឯង ទៅទទួលការព្យាបាលមុនការចោទប្រកាន់ ព្រះរាជអាជ្ញាពុំអាចធ្វើការចោទប្រកាន់ឡើយ[13] ។ ម្យ៉ាងវិញទៀត តាមស្មារតីនៃមាត្រា៩១ ថ្មី នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ព្រះរាជអាជ្ញាអាចបង្គាប់ឲ្យជនដែលប្រើប្រាស់គ្រឿងញៀនចូលខ្លួនក្នុង រយៈពេល ៨ ថ្ងៃ ទៅក្នុងគ្រឹះស្ថានព្យាបាលណាមួយដែលបាន ចែងក្នុងមាត្រា៨៩ ថ្មី ដើម្បីទទួលការព្យាបាលសមស្របតាមសុខភាពរបស់ខ្លួន ។ ក្នុងករណី ដែលជននោះបានទទួលការព្យាបាលតាមបង្គាប់រហូតដល់ទីបញ្ចប់ ឬ បើជននោះបានបន្តការព្យាបាលដោយទៀងទាត់ តុលាការអាចប្រកាសថាមិនដាក់ទោស[14]។ ដូចគ្នានេះដែរ មាត្រា៩២ អនុញ្ញាតឲ្យតុលាការត្រឹមតែធ្វើការព្រមានប៉ុណ្ណោះ ប្រសិនបើជនប្រើប្រាស់គ្រឿងញៀនទទួលការព្យាបាលរហូតដល់ទីបញ្ចប់ តាមការបង្ខំដោយតុលាការ ពោលគឺតុលាការមិនផ្តន្ទាទោសដាក់ពន្ធនាគារ ឬ ផាកពិន័យឡើយ[15]។ លើសពីនេះទៅទៀត អ្នកញៀនជាតិពុលដែលប្រព្រឹត្តបទល្មើសមិនធ្ងន់ធ្ងរនឹងផ្តន្ទាទោសដាក់ពន្ធនាគារ ហើយមិនដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារដោយព្យួរទោស ឬ មិនព្យួរទោសក្នុងរយៈពេល ៣ ឆ្នាំកន្លងទៅទេ តុលាការអាចសម្រេច មិនដាក់ទោស ប៉ុន្តែត្រូវបង្ខំជននោះឲ្យទៅទទួលការព្យាបាល។

តាមការបកស្រាយលើបទបញ្ញត្តិនានានៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនបានឆ្លុះបញ្ចាំងឲ្យឃើញនូវវិធានការមួយដែលមានឈ្មោះថា វិធានការព្យាបាល ដែលច្បាប់ពុំបានចាត់ទុកថាជា ទោស ឡើយ ប៉ុន្តែ វិធាន

---

[13] មាត្រា៨៩ ថ្មី នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

[14] មាត្រា៩០ ថ្មី នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

[15] ការគេចវេះពីវិធានការព្យាបាលដែលមានចែងក្នុងមាត្រា៩១ ថ្មី មាត្រា៩៥ មាត្រា៩៦ និងមាត្រា៩៧ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ ថ្ងៃដល់ ១ខែ និង ផ្តន្ទាទោសពិន័យជាប្រាក់ពី ២៥.០០០ រៀល ដល់ ១០០.០០០ រៀល (មាត្រា៩៤ ថ្មី នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន)។

ការនេះអាចត្រូវប្រកាស ដោយចៅក្រម សម្រាប់ជនដែលបានប្រព្រឹត្តបទល្មើសណាមួយដែលច្បាប់កំណត់ដូចខាងលើ។ វិធានការព្យាបាលពុំមែនជាទោសទេ តែគឺជា វិធានការសន្តិសុខ។

មួយវិញទៀត តាមរយៈអនុក្រឹត្យលេខ ១៧ អនក្រចុះថ្ងៃទី១៩ ខែ មេសា ឆ្នាំ ១៩៩៤ មជ្ឈមណ្ឌលគ្រប់គ្រងយុវទោសករ ឬ មជ្ឈមណ្ឌលយុវនីតិសម្បទាត្រូវបានបង្កើតឡើង ហើយមានសមត្ថកិច្ចគ្រប់គ្រងក្មេងៗអាយុចាប់ពី ៧ឆ្នាំ ដល់អាយុ ១៧ឆ្នាំ ដែលប្រព្រឹត្តអំពើអបាយមុខ រួមមានចោរកម្ម ជាដើម។ ការដាក់ក្នុងមជ្ឈមណ្ឌលនេះ មានគោលបំណងអប់រំ កែប្រែអនីតិជនទាំងនោះឲ្យមានការរីកចម្រើនខាងជីវភាព ស្មារតី និងសម្ភារៈ ពោលគឺត្រូវប្រែក្លាយពីជនដែលគ្មានវិន័យ គ្មានសីលធម៌ ទៅជាពលរដ្ឋស្អាតស្អំប្រកបដោយវិន័យថ្លៃថ្នូរ[16]។ ទន្ទឹមនឹងនេះផងដែរ ការសម្រេចសេចក្តីឲ្យដាក់អនីតិជនឲ្យស្ថិតនៅក្រោមការអប់រំ កែប្រែនៅក្នុងមជ្ឈមណ្ឌលនេះ ពុំមែនជាការអនុវត្តទោសទេ។ ដូចដែលបានបកស្រាយខាងលើរួចហើយ វិធានការដែលត្រូវអនុវត្តចំពោះអនីតិជនក្រៅពីទោសគឺ មានច្រើនប្រភេទណាស់ ដែលវិធានការទាំងនោះមិនមែនជាទណ្ឌកម្មព្រហ្មទណ្ឌឡើយ។ ផ្ទុយទៅវិញ វិធានការទាំងអស់នោះគឺគ្រាន់តែជាវិធានការសន្តិសុខប៉ុណ្ណោះ។

[16] មាត្រា១ នៃអនុក្រឹត្យលេខ ១៧ អនក្រ ចុះថ្ងៃទី ១៩ ខែមេសា ឆ្នាំ១៩៩៤ ស្តីពីមជ្ឈមណ្ឌលគ្រប់គ្រងយុវទោសករ ឬមជ្ឈមណ្ឌលយុវនីតិសម្បទា។

# ជំពូកទី២

# ទោសដែលត្រូវអនុវត្ត

# ចំពោះរូបវន្តបុគ្គល

# ជំពូកទី២
# ទោសដែលត្រូវអនុវត្តចំពោះរូបវន្តបុគ្គល

## ២.១. មូលទោស

ទោសព្រហ្មទណ្ឌ មានច្រើនប្រភេទណាស់ ទោស គឺប្រែប្រួលទៅតាមបុគ្គលដែលប្រព្រឹត្តបទល្មើស។ នេះវាផ្សារភ្ជាប់ជាមួយនឹងប្រវត្តិខ្លះៗ ទាក់ទងជាមួយនឹងការវិវត្តនៃជនល្មើសនៅក្នុងសង្គមនៃឧក្រិដ្ឋកម្ម។ ពីដើមឡើយ អ្នកដែលអាចប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌបាន គឺមានតែរូបវន្តបុគ្គលប៉ុណ្ណោះ មានន័យថា រូបវន្តបុគ្គលនេះ គឺសំដៅទៅដល់បុគ្គលដែលមានរូប មានសាច់ មានឈាមគឺសំដៅទៅដល់មនុស្សគ្រប់រូបម្នាក់ៗហ្នឹងឯង[17]។ រីឯនីតិបុគ្គល នៅក្នុងសង្គមសម័យទំនើបនាពេលបច្ចុប្បន្ន ឬ នីតិបុគ្គលនៅក្នុងប្រទេសស៊ីវិលនេះគេបានចាត់ទុកថា គឺជាអង្គដ៏សែនសំខាន់ គឺជាប្រធាននៃបទល្មើសដ៏មានសក្តានុពល ឬយើងហៅបានទៀតថា ជាជនល្មើសដ៏មាន សក្តានុពលនៅក្នុងសង្គមសម័យទំនើបហើយ ជាពិសេសនៅក្នុងសង្គមសេដ្ឋកិច្ចនាពេលបច្ចុប្បន្ន។ គេយល់ឃើញថា បុគ្គលដែលបានចូលរួមក្នុងការប្រព្រឹត្តបទល្មើស មានទាំងរូបវន្តបុគ្គលមានទាំងនីតិបុគ្គលផង។ ដូចនេះដើម្បី តាមឱ្យទាន់សភាពការណ៍ ក្រមព្រហ្មទណ្ឌរបស់យើងបានចែងកំណត់អំពីអ្នកទទួលខុសត្រូវនោះ និងការផ្តន្ទាទោសទាំងរូបវន្តបុគ្គល និងនីតិបុគ្គលទៅតាមប្រភេទនៃទោសព្រហ្មទណ្ឌ។

រូបវន្តបុគ្គល គឺជាបុគ្គលម្នាក់ៗដែលមានជីវិតពិត ផ្ទុយពីនីតិបុគ្គល[18]។ រូបវន្តបុគ្គល គឺជាមនុស្សពិតតាមធម្មជាតិ ដែលផ្ទុយនឹងនីតិបុគ្គល[19]។ ឥឡូវយើងសូមចាប់ផ្តើមពីរូបវន្តបុគ្គលជាមុនសិន បើសិនជាយើងពិនិត្យនៅក្នុងក្រមព្រហ្មទណ្ឌ ទោសដែលអាចអនុវត្តចំពោះ រូបវន្តបុគ្គល គឺមាន មូលទោស ទោសបន្ថែម និង ទោស ជំនួស។

### ២.១.១. និយមន័យនៃមូលទោស

មូលទោស គឺទោសដាក់ពន្ធនាគារ និងទោសពិន័យពិន័យជាប្រាក់[20] ។មូលទោស គឺជាទោសមូលដ្ឋានដែលអាចយក ទៅប្រើប្រាស់សម្រាប់ការប្រកាសទោស ចំពោះទៅលើជនដែលជាប់ចោទ និងជនដែលបានធ្វើការប្រព្រឹត្តនូវបទល្មើស។ ន័យម្យ៉ាងទៀតមូលទោសគឺជាទោសទាំងឡាយណាដែលច្បាប់បានបញ្ញត្តិជាលក្ខណៈសារវន្តចំពោះ បទល្មើសនីមួយៗ។ ហើយមូលទោសនេះ មានការប្រែប្រួលទៅតាមប្រភេទនៃជនល្មើសជារូបវន្តបុគ្គល ឬ នីតិបុគ្គល[21]។ ដោយឡែក ចំពោះមូលទោស ក៏មានការកំណត់នៅក្នុងក្រមព្រហ្មទណ្ឌដែលបានចែងថា៖ មូលទោស រួមមាន ទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់។ ការពិន័យជាប្រាក់ត្រូវគិតជា

[17] សូមមើលសៀវភៅស្តីពី រូបវន្តបុគ្គល ឆ្នាំ២០១២ រៀបរៀងដោយលោកអនុបណ្ឌិតច្បាប់ កៅ សីហា។
[18] សទ្ទានុក្រមពាក្យច្បាប់ ផ្នែកក្រមព្រហ្មទណ្ឌ ទីស្តីការគណៈរដ្ឋមន្ត្រីឆ្នាំ ២០១១ លេខរៀងទី ១៩៩។
[19] សទ្ទានុក្រមពាក្យច្បាប់ ផ្នែករដ្ឋប្បវេណី ទីស្តីការគណៈរដ្ឋមន្ត្រីឆ្នាំ ២០០៧ លេខរៀងទី ១២៧។
[20] មាត្រា៤៣ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩។
[21] រៀបរៀងដោយ លោក លីន សិលា និយាយអំពីនិយមន័យនៃមូលទោស។

ប្រាក់រៀល។ ម្យ៉ាងវិញទៀតមូលទោស ជាទោសសំខាន់ចម្បងជាងគេដែលតុលាការ អាចធ្វើការប្រកាសទោសតែឯងដើម្បីផ្តន្ទាទោសចំពោះ បទល្មើសណាមួយ។

**២.១.២. ប្រភេទនៃមូលទោស**

ជាទូទៅមូលទោស គឺត្រូវបានបែងចែកជាពីរប្រភេទធំៗក្នុងនោះរួមមាន ទោសដាក់ពន្ធនាគារ និងទោស ពិន័យជាប្រាក់ ប៉ុន្តែសម្រាប់ទោសពិន័យជាប្រាក់ គឺគិតជាប្រាក់រៀល ដោយផ្អែកតាមក្រមព្រហ្មទណ្ឌបានបញ្ញត្តិទុក។

**២.១.២.១. ទោសដាក់ពន្ធនាគារ**

ទោសដាក់ពន្ធនាគារ គឺជាទោសដាក់គុក ឬ ជាទោសដែលបំបាត់សេរីភាពរបស់បុគ្គល ដែលបានប្រព្រឹត្តនូវបទល្មើស និងត្រូវបានផ្តន្ទាទោសដោយដាក់ទោសពន្ធនាគារ គឺមានន័យថា ទោសដាក់ពន្ធនាគារ ជនណា ម្នាក់ក្រោយពេលដែលសាលក្រមបានសម្រេចដាក់ពន្ធនាគាររួចហើយ គឺត្រូវយកជននោះ ទៅដាក់គុក ពីព្រោះថា ការអនុវត្តទោសគឺត្រូវធ្វើនៅពន្ធនាគារ។ នៅក្នុងក្រមព្រហ្មទណ្ឌថ្មីបានកំណត់អំពីរបៀបនៃការគណនាចំពោះការ ដាក់ពន្ធនាគារ ឬ ទោសគុកនេះផងដែរ។ ក្រមព្រហ្មទណ្ឌបានកំណត់ថា៖ ប្រសិនបើជាទោសដាក់ពន្ធនាគារ កំណត់ដោយរយៈពេល ០១ ថ្ងៃ ហេតុដូច្នេះច្បាប់បានកំណត់ថា ០១ថ្ងៃនេះ គឺមានរយៈពេល២៤ម៉ោង។ បើជនណាម្នាក់ត្រូវបានតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ ០១ខែ របៀបនៃការគណនា ០១ខែ ត្រូវគិត ៣០ ថ្ងៃ។ បើសិនជាជនម្នាក់ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារក្នុងរយៈពេល០១ឆ្នាំ របៀបក្នុងការគណនា ត្រូវគិត ១២ខែ[22]។

ទន្ទឹមនឹងនេះផងដែរ ចំពោះក្រមព្រហ្មទណ្ឌក៏បានកំណត់អំពីលក្ខខណ្ឌនៃការបញ្ចប់ទោស ដោយហេតុ ថា ជាគោលការណ៍ នៅពេលដែលតុលាការបានដាក់ពន្ធនាគារទៅលើជនណាម្នាក់ហើយ ជននោះ គឺត្រូវតែ ទទួលរងនូវទោសក្នុងពន្ធនាគារឲ្យបានគ្រប់ចំនួន គឺមានន័យថា បើជននោះត្រូវដាក់គុកមានចំនួន ០៣ ឆ្នាំ ដូច្នេះ ជននោះត្រូវតែទទួលរងទោសឲ្យបានគ្រប់ចំនួនឆ្នាំយ៉ាងពេញលេញ ដោយគិតទៅតាមរបៀបគណនា ដូចបាន រៀបរាប់ត្រូវចំណុចពីខាងដើមមកហើយ។ ចំពោះករណីពិសេសមួយទៀតនោះ ដោយផ្អែកទៅតាមក្រមព្រហ្ម ទណ្ឌបានធ្វើការកំណត់នៃការបញ្ចប់ទោសថា ជាគោលការណ៍ទណ្ឌិត ដែលទោសរបស់ខ្លួនត្រូវបានបញ្ចប់នៅ ថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬ ថ្ងៃឈប់សម្រាកផ្សេងទៀត ដែលច្បាប់ ឬ បទដ្ឋានគតិយុត្តបានកំណត់ ត្រូវតែដោះលែងឲ្យ មានសេរីភាពនៅមុនថ្ងៃឈប់សម្រាកនោះ[23]។ នៅត្រង់ចំណុចនេះ គឺមានន័យថា រាល់ទណ្ឌិតដែលបានបញ្ចប់ ទោសទៅតាមការកំណត់ ដោយការបញ្ចប់ទោសនោះ ស្រាប់តែចំថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬ មួយចំថ្ងៃឈប់សម្រាកជា ផ្លូវការណ៍ ដូច្នេះទណ្ឌិតនោះ ត្រូវបានដោះលែងនៅថ្ងៃសុក្រនោះតែម្តង។

[22] មាត្រា៤៩ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

[23] មាត្រា៥០ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

### ២.១.២.២. ទោសពិន័យជាប្រាក់

នៅក្នុងមូលទោសនេះផងដែរ មានទោសមួយទៀត ដែលគេឲ្យឈ្មោះថា គឺជាទោសពិន័យសម្រាប់អនុវត្តទៅលើរូបវន្តបុគ្គល។ ដោយយោងទៅតាមក្រមព្រហ្មទណ្ឌដែលបានចែងថា៖ ការពិន័យត្រូវគិតជាប្រាក់រៀលដែលតម្រូវឲ្យទណ្ឌិតបង់ចំនួនប្រាក់ទៅតាមការកំណត់របស់ច្បាប់[24]។ យោងទៅតាមក្រមព្រហ្មទណ្ឌគឺបានធ្វើការ បញ្ជាក់ថា៖ ប្រាក់ពិន័យដែលទទួលបាន ត្រូវបង់ចូលជាថវិការរដ្ឋ[25]។ ហើយចំពោះទឹកប្រាក់នេះ ត្រូវកំណត់ជាប្រាក់រៀល ប្រាក់រៀលដែលជាផលនៃការពិន័យត្រូវទុកជាប្រាក់ចំណូលសម្រាប់ថវិការជាតិ ដោយត្រូវយកទៅរក្សាទុកនៅក្នុងរតនាគារជាតិ។របៀបនៃការប្រមូលប្រាក់ពិន័យនោះក៏មានការចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ៖ ការប្រមូលប្រាក់ពិន័យនិងប្រាក់ពន្ធនៃនីតិវិធីត្រូវធ្វើដោយភ្នាក់ងាររតនាគារជាតិនៅក្រោមឱវាទរបស់អយ្យការ[26]។ ប្រាក់ពិន័យ និងប្រាក់ពន្ធនៃនីតិវិធីដែលបានប្រមូលបាននេះត្រូវបង់ចូលថវិការដ្ឋ។

នីតិវិធីក្នុងការទាញយកនូវប្រាក់ពិន័យនេះ គឺក្រោយពេលដែលសេចក្តីសម្រេច ចូលជាស្ថាពររួចហើយ។ បន្ទាប់មក នឹងជូនដំណឹងអំពីសេចក្តីសម្រេចស្ថាពរនេះទៅឲ្យរតនាគារជាតិ រតនាគារជាតិនឹងចេញលិខិតមួយដើម្បីឲ្យជននោះទៅបង់ប្រាក់ដោយស្ម័គ្រចិត្ត ហើយការអនុវត្តក្នុងការបង់ប្រាក់ពិន័យនេះ គឺត្រូវស្ថិតនៅក្រោមការឃ្លាំមើល ឬ ក្រោមឱវាទរបស់អង្គការអយ្យការ។

ប្រសិនបើថា ជននោះពុំបានធ្វើការបង់ប្រាក់ទៅតាមពិន័យ ឬ គេចវេសពីការបង់ប្រាក់ពិន័យនោះ ដូច្នេះព្រះរាជអាជ្ញានឹងចេញដីកាមួយកំណត់ឲ្យជននោះទៅបង់ប្រាក់ពិន័យនោះសាជាថ្មីម្តងទៀត ក៏ប៉ុន្តែ បើករណីជននោះនៅតែរឹងទទឹងមិនខ្វល់ខ្វាយ ឬ មួយមិនអនុវត្ត ព្រះរាជ្ញាអាចប្រើនីតិវិធីបង្ខំបាន ដើម្បីទារយកប្រាក់ពិន័យ។

### ២.១.៣. ការប្រកាសមូលទោសចំពោះរូបវ័ន្តបុគ្គល

ជាគោលការណ៍ នៅពេលដែលបានប្រព្រឹត្តអំពើល្មើសណាមួយហើយបុគ្គលនោះត្រូវទទួលខុសត្រូវព្រហ្មទណ្ឌដោយឆ្លងកាត់នីតិវិធីជាច្រើន រហូតឈានដល់ការអនុវត្តមូលទោសតាមរយៈការប្រកាសពីតុលាការ។

យោងទៅតាមក្រមព្រហ្មទណ្ឌឆ្នាំ២០០៩មាត្រា៤៦ ដល់មាត្រា៤៨ បានចែងអំពីចំណាត់ថ្នាក់នៃបទល្មើសបានបែងចែងជា ៣ប្រភេទ គឺបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ។ ដែលប្រភេទថ្នាក់នៃបទល្មើសនេះមាន លក្ខណៈសម្គាល់ខុសគ្នា ដោយវាប្រែប្រួលទៅតាមបទល្មើសរបស់បុគ្គលអ្នកប្រព្រឹត្ត។ បន្ទាប់ទៅនេះ យើងនឹងសិក្សាពីភាពខុសគ្នា រវាងបទល្មើសបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ ថាតើ បទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុមានការកំណត់សម្គាល់ដូចម្តេច?

---

[24] មាត្រា៤៣ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

[25] មាត្រា៥២ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

[26] មាត្រា៤៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៧។

**ក. បទឧក្រិដ្ឋ**

បទឧក្រិដ្ឋ គឺជាបទល្មើសដែលមានទណ្ឌកម្មធ្ងន់ធ្ងរបំផុត។ បទល្មើសនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារមានរយៈពេលលើសពី៥ (ប្រាំ)ឆ្នាំ និងក្រោម ឬ ស្មើនឹង៣០ (សាមសិប) ឆ្នាំ ឬ ដាក់ពន្ធនាគារអស់មួយជីវិត[27]។ បើតាមការកំណត់និយមន័យរបស់បទឧក្រិដ្ឋ ដោយយោងទៅតាមមាត្រា៤៦នៃក្រមព្រហ្មទណ្ឌបានចែងថា៖ បទល្មើសជាបទឧក្រិដ្ឋ នៅក្នុងករណីដែលអតិប្បរមានៃទោសដាក់ពន្ធនាគារគឺត្រូវៈ

- ជាទោសដាក់ពន្ធនាគារអស់មួយជីវិត។
- ជាទោសដាក់ពន្ធនាគារមានរយៈពេលលើសពី៥ (ប្រាំ) ឆ្នាំ និងក្រោម ឬ ស្មើនឹង៣០ (សាមសិប) ឆ្នាំ។ ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ[28]។

**ខ. បទមជ្ឈិម**

បទមជ្ឈិម គឺជាបទល្មើសដែលមានទណ្ឌកម្មជាមធ្យមនៃទោស ដែលត្រូវដាក់ពន្ធនាគារមានរយៈពេលលើសពី៦ (ប្រាំមួយ)ថ្ងៃ ដល់៥ (ប្រាំ)ឆ្នាំ។

បើតាមការកំណត់និយមន័យរបស់បទល្មើសមជ្ឈឹមក្នុងក្រមព្រហ្មទណ្ឌបានចែងថា៖ បទល្មើសមជ្ឈឹម នៅក្នុងករណី ដែលអតិបរមានៃទោសដាក់ពន្ធនាគារ ដែលត្រូវរងនោះ គឺមានយរៈពេលលើសពី៦ (ប្រាំមួយ)ថ្ងៃ និងក្រោម ឬ ស្មើនឹង៥ (ប្រាំ)ឆ្នាំ ហើយទោសដាក់ពន្ធនាគារនេះ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ[29]។

**គ. បទលហុ**

បទលហុ គឺជាបទល្មើសដែលមានទណ្ឌកម្មស្រាលជាងគេ។ បទល្មើសលហុនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារមានរយៈពេលក្រោម ឬ ស្មើនឹង៦ (ប្រាំមួយ)ថ្ងៃ ឬ ពិន័យជាប្រាក់ប៉ុណ្ណោះ។ បើតាមការកំណត់និយមន័យរបស់បទលហុ ដោយយោងទៅតាមមាត្រា៤៨នៃក្រមព្រហ្មទណ្ឌបានចែងថា៖ បទល្មើសលហុ នៅក្នុង ករណី៖

អតិបរមានៃទោសដាក់ពន្ធនាគារដែលត្រូវរងនោះ គឺត្រូវមានរយៈពេលក្រោម ឬ ស្មើនឹង៦ (ប្រាំមួយ)ថ្ងៃ។ ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ ។ បទល្មើសត្រូវផ្តន្ទាទោសត្រឹមតែពិន័យជាប្រាក់ប៉ុណ្ណោះ[30]។

ដូចនេះ បទល្មើសមួយចាត់ទុកថាជាបទលហុ លុះត្រាតែកម្រិតអតិបរមានៃទោសដាក់ពន្ធនាគារមានរយៈពេលស្មើ ឬ តិចជាង (ប្រាំមួយ) ថ្ងៃ ឬ ជាបទល្មើសដែលគ្មានទោសដាក់ពន្ធនាគារទេ គឺមានតែទោស

---

[27] សន្ធានុក្រមពាក្យច្បាប់ ផ្នែកក្រមព្រហ្មទណ្ឌនៃទីស្តីការគណៈរដ្ឋមន្ត្រីឆ្នាំ ២០១១ លេខរៀងទី១៨៣។

[28] មាត្រា៤៦ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

[29] មាត្រា៤៧ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

[30] មាត្រា៤៨ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

ពិន័យ ជាប្រាក់ប៉ុណ្ណោះ។ បើយោងទៅតាមក្រមព្រហ្មទណ្ឌថ្មីឆ្នាំ២០០៩ បានចែងអំពីប្រភេទនៃបទល្មើសលហុ ដែលមានចំនួន ១០បទល្មើសក្នុងនោះរួមមាន៖

មាត្រា២២៨ គឺជាបទហិង្សាស្រាល

មាត្រា២៩៧ ជាបទស្រវឹងជាក់ស្តែង

មាត្រា២៩៨ ជាបទហៅអ្នកដទៃនៅទីសាធារណៈ

មាត្រា៣០៥ ជាបទបរិហាកេរ្តិ៍ជាសាធារណ

មាត្រា៣០៧ ជាបទជេរប្រមាថជាសាធារណៈ

មាត្រា៤១៨ ជាបទធ្វើឱ្យមានការខូចខាតស្រាល

មាត្រា៤២០ ជាបទធ្វើឱ្យមានការខូចខាត បណ្ណ ប្រកាស ឬ សេចក្តីជូនដំណឹងជាផ្លូវការ

មាត្រា៥០២ ជាបទប្រមាថ

មាត្រា៥១៦ ជាបទប្រមាថចំពោះព្រះសង្ឃដូនជី និងតាជី

មាត្រា៦៥១ ជាបទដាក់ឱ្យធ្វើចរាចរណ៍ជាថ្មីនូវរូបិយវត្ថុ និងរូបិយបណ្ណក្លែង។

ការប្រកាសមូលទោស មុនដំបូងយើងនឹងពន្យល់អំពី រូបវន្តបុគ្គលជានីតិជនជាមុនសិន ( **២.១.៣.១** ) មុននឹងឈានចូលទៅធ្វើការពន្យល់អំពី រូបវន្តបុគ្គលជាអនីតិជននាពេលក្រោយ ( **២.១.៣.២** )។

### ២.១.៣.១. ការប្រកាសមូលទោសចំពោះរូបវ័ន្តបុគ្គលជានីតិជន

ជាគោលការណ៍ ការប្រកាសមូលទោស គឺត្រូវបានធ្វើឡើងនៅចំពោះ រូបវន្តបុគ្គល ដែលជានីតិជន និង អនីតិជន សុទ្ធតែទទួលបាននូវការប្រកាសមូលទោសដូចៗគ្នាទាំងអស់។ តុលាការប្រកាសទោសដោយផ្អែក ទៅ លើស្ថានទម្ងន់ និងកាលៈទេសៈនៃបទល្មើសទៅលើបុគ្គលិកលក្ខណៈនៃជនជាប់ចោទ ទៅលើសភាពផ្លូវចិត្ត ទៅ លើធនធាន និងបន្ទុកទៅលើមូលហេតុ ព្រមទាំងទៅលើកិរិយាមារយាទរបស់ជនល្មើស ក្រោយពេលប្រព្រឹត្ត បទ ល្មើសជាអាទិ៍ ចំពោះជនរងគ្រោះ។

នៅក្នុងក្រមព្រហ្មទណ្ឌបានចែងអំពីគោលការណ៍នីត្យានុកូលភាពនៃទោសថា៖ មានតែទោសដែលមាន ចែងក្នុងបញ្ញត្តិព្រហ្មទណ្ឌជាធរមាន នៅពេលដែលបទល្មើស ត្រូវបានប្រព្រឹត្តប៉ុណ្ណោះ ទើបអាចយកទៅប្រកាស បាន[31]។ ដូច្នេះហើយការប្រកាសទោសត្រូវបានធ្វើឡើងតាមករណីនីមួយៗដូចជា៖

- ចំពោះបទល្មើសដែលមានទោសដាក់ពន្ធនាគារ តុលាការអាចប្រកាស តែទោសដាក់ពន្ធនាគារតែ ប៉ុណ្ណោះ មិនអាចបន្ថែមទោសពិន័យជាប្រាក់បាននោះទេ។

[31] មាត្រា៣ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

- ចំពោះបទល្មើសដែលមានទោសពិន័យជាប្រាក់ តុលាការអាចប្រកាស តែទោសពិន័យជាប្រាក់ប៉ុណ្ណោះ មិនអាចបន្ថែមទោសដាក់ពន្ធនាគារបានទេ។
- ចំពោះបទល្មើសដែលមានទោសដាក់ពន្ធនាគារផង និងទោសពិន័យជាប្រាក់ផង តុលាការអាចប្រកាស ទោសដាក់ពន្ធនាគារ និងទោសពិន័យជាមួយគ្នា ឬ ទោសដាក់ពន្ធនាគារតែមួយមុខតែប៉ុណ្ណោះ ឬ ទោស ពិន័យជាប្រាក់ តែមួយមុខតែប៉ុណ្ណោះ ដោយយោងទៅតាមក្រមព្រហ្មទណ្ឌបានកំណត់[32]។

ការប្រកាសទោសសម្រាប់រូបវន្តបុគ្គលដែលជានីតិជន មានចែងយ៉ាងច្បាស់នៅក្នុងក្រមព្រហ្មទណ្ឌនៅក្នុងមូលទោស មានប្រភេទទោសចំនួន២ធំៗ គឺទោសដាក់ពន្ធនាគារ ឬ ទោសដាក់គុក និងទោសដែលពិន័យជាប្រាក់[33]។ ដោយឡែកសម្រាប់បទប្បញ្ញត្តិថ្មីនៃក្រមព្រហ្មទណ្ឌ ករណីខ្លះច្បាប់បានធ្វើការចែងកំណត់នៃការផ្តន្ទាទោសនូវបទល្មើសមួយ ដោយដាក់ពន្ធនាគារពីចំនួនប៉ុណ្ណោះទៅចំនួនត្រឹមប៉ុណ្ណោះ ហើយនឹងពិន័យជាប្រាក់ចាប់ពីចំនួនត្រឹមប៉ុណ្ណោះទៅដល់ចំនួនប៉ុណ្ណោះ។ ពុំមែនតែក្រមព្រហ្មទណ្ឌទេ នៅមានបទប្បញ្ញត្តិដទៃផ្សេងទៀតដែលបានចែងដូចគ្នា គឺភាគច្រើនមានការចែងអំពីទោសដាក់ពន្ធនាគាររួចហើយ ក៏បានចែងអំពីទោសពិន័យជាប្រាក់ថែមទៀតផង។ ប៉ុន្តែរាប់ចាប់តាំងអំពីក្រមព្រហ្មទណ្ឌនេះបានចូលធរមានមក និងយកមកអនុវត្តបានហើយនោះ ជាពិសេសគឺបទប្បញ្ញត្តិនៃគន្ថីះទី១ បានចែងអំពីគោលការណ៍ទូទៅមួយ ដែលគ្របដណ្តប់ទៅលើគ្រប់បទ ល្មើសព្រហ្មទណ្ឌ គ្រប់ទោសព្រហ្មទណ្ឌទាំងអស់ទាក់ទងជាមួយនឹងមូលទោសនេះ។ លើសពីនេះទៅទៀតនោះ គឺក្រមព្រហ្មទណ្ឌបានធ្វើការចែងអំពីរបបនៃការប្រកាសទោស ថាតើចៅក្រមអាចប្រកាសមូលទោសដោយរបៀប ដូចម្តេចទៅ? បើយោងទៅតាមក្រមព្រហ្មទណ្ឌបានចែង ស្តីពីរបបនៃការប្រកាសមូលទោសនោះ គឺបានចែង កំណត់ថា ប្រសិនបើបទល្មើសមួយមានចែងផ្តន្ទាទោសដាក់ពន្ធនាគារផង និងពិន័យជាប្រាក់ផង។

ដូច្នេះ ចៅក្រមគាត់មានសិទ្ធិអំណាចធ្វើការជ្រើសរើសក្នុងការកំណត់អំពីទោសមានដូចតទៅនេះ៖

**ចំណុចទី១៖** ចៅក្រមអាចប្រកាសទោសទាំងពីរចូលជាមួយគ្នាបាន គឺមានន័យថា ទាំងទោសដាក់ពន្ធនាគារផង និងទោសពិន័យជាប្រាក់ផង។

**ចំណុចទី២៖** ចៅក្រមអាចប្រកាសត្រឹមតែទោសដាក់គុកទេ បានសេចក្តីថា ចៅក្រមអត់ប្រកាសនូវទោសពិន័យជាប្រាក់ទេ។

**ចំណុចទី៣៖** ជម្រើសមួយទៀតនោះ គឺចៅក្រមអាចប្រកាសត្រឹមតែទោសពិន័យជាប្រាក់ ស្មើនឹងមិនប្រកាសនូវទោសជាប់គុកក៏បានដែ

[32] មាត្រា៩៧ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

[33] មាត្រា៩៨ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

ហើយនូវត្រង់ពាក្យថាឈ្នាប់ "និង"ពាក្យថា "និង"ចំណុចទីនេះ គឺមានចែងនៅគ្រប់បទប្បញ្ញត្តិនៃមាត្រាជាបន្តបន្ទាប់ ក្នុងក្រមព្រហ្មទណ្ឌ ក៏ដូចជាអត្ថបទច្បាប់ដទៃផ្សេងទៀត គឺថាលែងចងជាកាតព្វកិច្ចចំពោះចៅក្រមទៀតហើយ បានសេចក្តីថា ចៅក្រមមានសិទ្ធិអំណាចនៅក្នុងការជ្រើសរើសទៅតាមគោលការណ៍ឯកត្តកម្មនៃទោសនេះថា តើគួរប្រកាសទោសរបៀបយ៉ាងដូចម្តេចទៅ? ចៅក្រមអាចយកទោសទាំងពីរទៅបញ្ចូលគ្នាតែម្តង ដើម្បីផ្តន្ទាទោសក្នុងពេលតែមួយ ឬ មួយក៏សម្រេចជ្រើសរើសយកត្រឹមតែទោសគុក ឬ ក៏ទោសពិន័យជាប្រាក់យក មកអនុវត្ត។

យោងទៅតាមក្រមព្រហ្មទណ្ឌ ដែលចែងអំពីគោលការណ៍ឯកត្តកម្មនៃទោស ប៉ុន្តែគោលការណ៍នេះអាចអនុវត្តទៅបាននៅក្នុងលក្ខខណ្ឌ ដែលពុំមានបទប្បញ្ញត្តិពិសេស ដែលចែងផ្ទុយជាមួយបដិប្បញ្ញត្តិទៅនឹងគោលការណ៍នេះ គឺមានន័យថា មានអត្ថបទផ្សេងទៀតដែលចែងជាបដិប្បញ្ញត្តិថា កាលណាច្បាប់បានចែងផ្តន្ទាទោសដាក់គុកផង និងពិន័យជាប្រាក់ផងនោះ ចៅក្រមត្រូវតែប្រកាសទោសទាំងពីរព្រមគ្នាតែម្តង។ ដូចនេះ គឺអាចមានបទប្បញ្ញត្តិពិសេសចែងអំពីស្ថានភាពនេះ ច្បាស់លាស់មែន ដូច្នេះហើយ ចៅក្រមត្រូវតែអនុវត្តទៅតាមបទប្បញ្ញត្តិពិសេសនោះ[34]។ ប៉ុន្តែបើពុំដូច្នោះទេ ចៅក្រមត្រូវអនុវត្តនូវរបបរួមដូចមានចែងក្នុងមាត្រា៩៧នេះគឺសុទ្ធទាក់ទងនឹងការប្រកាសមូលទោស។

**២.១.៣.២. ការប្រកាសមូលទោសទៅលើរូបវ័ន្តបុគ្គលជាអនីតិជន**

សូមពន្យល់នូវពាក្យ អនីតិជន គឺជាជនដែលមិនទាន់គ្រប់អាយុតាមច្បាប់កំណត់ ឬ ជនដែលមានអាយុក្រោម ១៨ឆ្នាំ។ ម្យ៉ាងទៀត អនីតិជន គឺជាជនដែលច្បាប់មិនទាន់ឱ្យទទួលខុសត្រូវលើអំពើដែលខ្លួនបានប្រព្រឹត្ត ឬ ជនដែលច្បាប់មិនទាន់ទទួលខុសត្រូវលើអំពើរបស់ខ្លួនដោយមានកម្រិត។ សូមឆ្លៀតឱកាសនេះ ដើម្បីបញ្ជាក់ ជូនបន្តិចអំពី របបនៃការប្រកាសទោសចំពោះអនីតិជនដែលមានរបបគតិយុត្តពិសេស។ របបនេះ គឺជារបបដែល ចែងអំពីទោសទាំងស្រុងសម្រាប់អនីតិជនតែម្តង ដោយមានចែងចាប់ពីមាត្រា១៦០ តទៅ។ ការដែលចែងអំពី របបគតិយុត្តិពិសេសមួយសម្រាប់រូបវ័ន្តបុគ្គលជាអនីតិជនដាច់ដោយឡែកពីរូបវ័ន្តបុគ្គលជានីតិជន។

ជាទូទៅអនីតិជនគឺជាជនដែលមានអាយុក្រោម ១៨ឆ្នាំ។ ចំពោះអនីតិជនដែលមានអាយុក្រោម ១៨ឆ្នាំនេះយើងបែងចែងចេញជា ២ ប្រភេទតូចៗទៀតគឺ៖

**ក. អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ**

អនីតិជនប្រភេទនេះ មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ មានន័យថា តុលាការមិនអាចសម្រេចផ្តន្ទាទោសទៅលើអនីតិជនដែលមានអាយុក្រោម ១៤ឆ្នាំ ឡើយ សូម្បីតែការចោទប្រកាន់ទៅតាមក្រមនីតិវិធីព្រហ្មទណ្ឌ

[34] មាត្រា៩៦ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

ក៏គាត់មិនអាចចោទប្រកាន់ទៅលើអនីតិជន ដែលមានអាយុក្រោម ១៤ឆ្នាំ ផងដែរ ជាទូទៅចៅក្រមមិនចោទប្រកាន់ទេ។ ក៏ប៉ុន្តែ អាចមានករណីពិសេសខ្លះគាត់ចោទដែរពិសេសករណីដែលប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរនេះគឺករណីដែល ទាក់ទងទៅនឹងការទទួលខុសត្រូវរបស់អនីតិជនដូចពន្យល់ខាងក្រោម។

### ខ.អនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ

ចំពោះអនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ និងក្រោមអាយុ ១៨ឆ្នាំ ជាវិធានការច្បាប់ទុកលទ្ធភាពឱ្យចៅក្រមធ្វើការពិចារណាលើវិធានការ ពីរយ៉ាងគឺៈ

**ក.** កាលណាតុលាការសម្រេចមិនប្រកាសទោសព្រហ្មទណ្ឌចំពោះអនីតិជន តុលាការអាចប្រើប្រាស់នូវវិធានសំរាប់ប្រើប្រាស់ចំពោះអនីតិជនដូចដែលមានចែងក្នុងមាត្រា៣៩ នៃក្រមព្រហ្មទណ្ឌ។ ជាទូទៅ រាល់អនីតិជនអាយុពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ ដែលប្រព្រឹត្តបទល្មើសទាំងអស់ តុលាការអាចសម្រេចដាក់គាត់ក្នុង វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ ដែលមានដូចជា[35]ៈ

១- ការប្រគល់អនីតិជនទៅឪពុកម្តាយ អាណាព្យាបាល បុគ្គលិកដែលថែរក្សា អនីតិជននោះ ឬ បុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសក្តិសមនឹងទំនុកចិត្ត ។

២- ការប្រគល់អនីតិជនឱ្យទៅសេវាសាធារណៈ ដែលសម្រាប់ទទួលបន្ទុកអនីតិជន ។

៣- ការប្រគល់អនីតិជនឱ្យទៅអង្គការឯកជន ដែលមាននីតិសម្បទាក្នុងការទទួលអនីតិជន ។

៤- ការប្រគល់អនីតិជនឱ្យទៅមន្ទីរពេទ្យ ឬ ស្ថាប័នឯកទេស ។

៥- ការដាក់អនីតិជនឱ្យនៅក្រោមការការពាររបស់តុលាការ ។

ក្នុងករណីដាក់ឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការនោះ តុលាការនឹងចាត់តាំងបុគ្គលមួយរូបដែល ត្រូវទទួលភារៈធ្វើការតាមដានអនីតិជន។ បុគ្គលនេះផ្ញើរបាយការណ៍ស្តីពី កិរិយាមារយាទរបស់អនីតិជនឱ្យបាន ទៀងទាត់ដល់ព្រះរាជអាជ្ញា។ បុគ្គលនេះផ្តល់ព័ត៌មានដល់ព្រះរាជាអាជ្ញាអំពីព្រឹត្តិការណ៍ទាំងអស់ដែលអាចនាំឱ្យ មានការកែប្រែនូវវិធាននេះ[36]។

ខ. តុលាការអាចប្រកាសទោសព្រហ្មទណ្ឌបានលើអនីតិជន បើកាលណាកាលៈទេសៈនៃបទល្មើសនិងបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ។ ក៏ប៉ុន្តែ ទាក់ទងទៅនឹងការអនុវត្តនូវមូលទោសរបស់អនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ ទៅក្រោមអាយុ ១៨ឆ្នាំ នោះ គឺមានលក្ខណៈពិសេសជាងនីតិជនធម្មតា នេះបើតាមមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌដោយបានចែងកំណត់ថា កាលណាតុលាការសម្រេចផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ឆ្នាំ ឡើងទៅ មូលទោសលើបទល្មើសដែលចោទប្រកាន់ត្រូវបានបន្ថយក្នុងលក្ខខណ្ឌដូចតទៅៈ

[35] មាត្រា៤០ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

[36] មាត្រា៤១ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

១- អតិបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្ដាល។

២- ប្រសិនបើអតិបរមានៃទោសនោះ គឺជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាត្រូវបន្ថយមកនៅពន្ធនាគារ ២០ (ម្ភៃ)ឆ្នាំ។

៣- អប្បបរមានៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្ដាល ប្រសិនបើអប្បបរមានេះលើសពី ១ថ្ងៃ។

៤- អប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្ដាល។ បន្ថយអតិបរមានៃទោសដាក់ពន្ធនាគារមកត្រឹមចិរវេលាមួយស្មើ ឬ តិចជាង ០៥ (ប្រាំ)ឆ្នាំ នោះបទល្មើសដែលចោទប្រកាន់នៅតែជាបទឧក្រិដ្ឋដដែល។

មាត្រានេះ គឺអាចអនុវត្តចំពោះតែអនីតិជន ហើយចៅក្រមសម្រេចប្រកាសទោសព្រហ្មទណ្ឌបានកាលណាការប្រព្រឹត្តបទល្មើសរបស់អនីតិជនមានភាពកាចសាហាវ។ ដូចនេះ ចៅក្រមមានជម្រើសតែមួយគឺ ប្រកាសទោសព្រហ្មទណ្ឌ។

**ឧទាហរណ៍៖** អនីតិជនអាយុ ១៦ឆ្នាំ បានប្រព្រឹត្តបទរំលោភសេពសន្ថវៈរួចហើយក៏សម្លាប់នារីរងគ្រោះ។ ចំពោះបទល្មើសនេះ មានលក្ខណៈកាចសាហាវដែលទាមទារឱ្យចៅក្រមត្រូវតែប្រើប្រាស់វិធានការដាក់ទោសព្រហ្មទណ្ឌជាដាច់ខាត ដើម្បីធានាថាអនីតិជនដែលបានប្រព្រឹត្តបទល្មើសនោះនឹងមិនទៅប្រព្រឹត្តបទល្មើសម្តងទៀតបាន ហើយដើម្បីធ្វើសមាហរណកម្មជននោះឱ្យកែប្រែខ្លួននឹងអាចចូលមករួមរស់ក្នុងសង្គមវិញបាន។ បើ ចៅក្រមហ៊ានប្រើវិធានការណាផ្សេងក្រៅពីវិធានការដាក់ទោសព្រហ្មទណ្ឌនោះ ជនដែលបានប្រព្រឹត្តបទល្មើស នឹងមិនខ្លាចច្បាប់ បើទោះបីជាគេបានប្រព្រឹត្តបទល្មើសក៏ដោយក៏មិនទទួលទណ្ឌកម្មព្រហ្មទណ្ឌ។ បើសម្រាប់ នីតិជននៅពេលប្រព្រឹត្តបទល្មើសត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០លានរៀល ទៅ ២០លានរៀល ។ តែបើសម្រាប់អនីតិជនវិញ ត្រូវបន្ថយពាក់កណ្ដាល គឺមកនៅសល់ត្រឹមប្រាក់ពី ៥លានរៀល ទៅ ១០លានរៀលវិញ។ ទាំងអស់ខាងលើនេះគឺជា របបគតិយុត្តពិសេសមួយសម្រាប់អនីតិជន។

## ២.២. ទោសបន្ថែម

### ២.២.១. និយមន័យនៃទោសបន្ថែម (អនុទោស)

ទោសបន្ថែម អាចហៅបានម្យ៉ាងទៀតថា អនុទោស ឬ ទោសបន្ទាប់បន្សំ[37]។ ទោសបន្ថែម បង្កើតឡើងក្នុងគោលបំណងឱ្យការដាក់ទណ្ឌកម្មមានកម្រិតសមស្របទៅនឹងអំពើល្មើសដែលបានប្រព្រឹត្ត។ ទោសបន្ថែម គឺជាទោសដែលត្រូវប្រកាសជាបន្ថែមទៅលើមូលទោសក្រមព្រហ្មទណ្ឌបានបញ្ញត្តិពីរបបគតិយុត្តិ (វិធានច្បាប់) នៃទោសបន្ថែមជាលក្ខណៈទូទៅ។ មុនពេលដែលក្រមព្រហ្មទណ្ឌចូលជាធរមាន ទោសបន្ថែមក៏មានវត្តមានរួចជាស្រេចទៅហើយ នៅក្នុងនីតិព្រហ្មទណ្ឌកម្ពុជា ជាក់ស្តែងដូចជាមាត្រា ៦៣ថ្មី ចំណុចទី៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរ

[37] សទ្ទានុក្រមពាក្យច្បាប់នៃក្រមព្រហ្មទណ្ឌ ទីស្តីការគណៈរដ្ឋមន្ត្រីឆ្នាំ ២០១១ លេខរៀងទី៥០។

កាលដែលចែងថា តុលាការអាចបញ្ជាឱ្យបិទផ្សាយសេចក្តីសម្រេចរបស់ខ្លួននៅទីកន្លែងទាំងឡាយដែលតុលាការនឹងបញ្ជាក់ដោយឱ្យជនជាប់ទោសទទួលបន្ទុកចេញសោហ៊ុយ ហើយតុលាការអាចចុះផ្សាយសាលក្រមនេះក្នុងសារព័ត៌មានមួយ ឬ ច្រើនដោយឱ្យជនជាប់ទោសទទួលបន្ទុកចេញហ៊ុយ រហូតដល់កម្រិតច្រើនបំផុត ១០ លាន រៀល។ នៅក្នុងច្បាប់ដទៃទៀត ដូចជាច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនចាស់ជាដើម អ្នកនីតិប្បញ្ញត្តិប្រើប្រាស់ ពាក្យទោសមានកំហិត និង ទោសឥតកំហិត តែតាមការពិតទៅ ទោសមានកំហិត ឬ ទោសឥតកំហិតមានលក្ខណៈដូចគ្នាទៅនិងទោសបន្ថែមដែរ។

ក្រៅពីនេះ ទោសបន្ថែមក៏ត្រូវបានចែងនៅក្នុងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលត្រូវបានប្រកាសប្រើនៅថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨ ដោយមាត្រា៤៨ នៃច្បាប់បានចែងថា ចំពោះបទល្មើសដែលមានចែងក្នុងច្បាប់នេះ អាចត្រូវទទួលទោសបន្ថែមដូចតទៅ ៖

១- រឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុទាំងឡាយដែលត្រូវបានប្រើប្រាស់ ឬ នឹងត្រូវប្រើប្រាស់ក្នុងពេលប្រព្រឹត្តបទល្មើស

២- រឹបអូសសម្ភារៈទាំងឡាយដែលជាកម្មវត្ថុនៃបទល្មើស

៣-រឹបអូសប្រាក់ចំណូល ឬ ទ្រព្យដែលរកបាន ឬ ជាផលនៃបទល្មើស

៤-បិទការផលិតដែលបម្រើដល់ការប្រព្រឹត្តបទល្មើស

៥-ការដាក់កំហិតលើសិទ្ធិពលរដ្ឋ និង

៦-ការហាមឃាត់ការស្នាក់នៅ។

### ២.២.២. ប្រភេទផ្សេងៗនៃទោសបន្ថែម

មាត្រា៥៣ នៃក្រមព្រហ្មទណ្ឌបានកំណត់ថា ទោសបន្ថែមមានចំនួន ១៩ ប្រភេទផ្សេងៗគ្នា។ ប៉ុន្តែសម្រាប់ការសិក្សាពីទោសបន្ថែមនៅក្នុងក្របខ័ណ្ឌនៃសៀវភៅសិក្សានេះទោសបន្ថែមដែលមានលក្ខណៈប្រហាក់ប្រហែល គ្នា និងត្រូវលើកយកមកពិចារណារួមបញ្ចូលគ្នាតែម្តង។

យោងតាមបញ្ញត្តិមាត្រា៥៣ ទោសបន្ថែមរួមមាន៖

១- ការដកសិទ្ធខ្លះជាពលរដ្ឋ

២- ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈណាដែលបទល្មើសនោះបានប្រព្រឹត្តនៅក្នុងពេលដែលប្រកបវិជ្ជាជីវៈនេះ ។

៣- ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ ។

៤- ការព្យួរលិខិតបើកបរ ។

៥- ការហាមឃាត់ចំពោះការស្នាក់នៅ ។

៦- ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

៧- ការហាមឃាត់ចំពោះការចូល និងការស្នាក់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះទណ្ឌិត ដែលជាបរទេស ។

៨- ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុដែលប្រើប្រាស់ក្នុងពេលប្រព្រឹត្តបទល្មើស ឬ ដែលទុកសម្រាប់ប្រព្រឹត្តបទល្មើស ។

៩- ការរឹបអូសវត្ថុ ឬ មូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស ។

១០- ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិ ដែលជាផលកើតចេញពីបទល្មើស ។

១១- ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬ ចលនវត្ថុ ដែលលំអទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត ។

១២-ការរឹបអូសយានជំនិះដែលជារបស់ទណ្ឌិត។

១៣-ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ។

១៤-ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ។

១៥-ការបិទគ្រឹះស្ថានដែលប្រើប្រាស់ ដើម្បីត្រៀម ឬ ប្រព្រឹត្តបទល្មើស។

១៦- ការហាមឃាត់ចំពោះការធ្វើអាជីវកម្មនៅក្នុងគ្រឹះស្ថានដែលបានបើកចំហសម្រាប់សាធារណជន ឬ ដែលប្រើប្រាស់ដោយសាធារណជន។

១៧- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស។

១៨- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន។

១៩- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍[38]។

ហេតុដូច្នេះ ទោសបន្ថែមដែលយើងខ្ញុំនឹងត្រូវលើកយកមកធ្វើការអត្ថាធិប្បាយនៅពេលនេះមានចំនួន ១៥ ចំណុចដូចរៀបរាប់ខាងក្រោមនេះ៖

- **ចំណុចទី១ ៖ ការដកសិទ្ធិខ្លះជាប្រជាពលរដ្ឋ**

សិទ្ធពលរដ្ឋដែលអាចដកហូតបានមានចំនួន ៦ ប្រភេទគឺ ៖

- សិទ្ធបោះឆ្នោត
- សិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត
- សិទ្ធិបំពេញការងារជាមន្ត្រីក្របខ័ណ្ឌមុខងារសាធារណៈ
- សិទ្ធទទួលការចាត់តាំងជាអ្នកជំនាញ ជាអាជ្ញាកណ្តាល ឬ ជាអាណត្តិគាហក[39]របស់តុលាការ

[38] មាត្រា៥៣ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីអំពី ប្រភេទនៃទោសបន្ថែម។

[39] អាណត្តិគាហក គឺជាបុគ្គលដែលបានទទួលសិទ្ធិអំណាចធ្វើការចាត់ចែងកិច្ចការអ្វីមួយដើម្បីអ្នកដទៃ តាមរយៈកិច្ចសន្យាអាណត្តិ។

- សិទ្ធទទួល និងពាក់គ្រឿងឥស្សរិយយសទាំងអស់

- សិទ្ធធ្វើជាសាក្សីដែលទទួលសម្បថនៅមុខតុលាការ។

ដោយយោងតាមមាត្រា៧១ នៃក្រមព្រហ្មទណ្ឌ ទោសបន្ថែមនេះត្រូវអនុវត្តនៅក្រោយពេលដែលទណ្ឌិត (អ្នកជាប់ទោស) បានទទួលរងទោសដាក់ពន្ធធនាគារចប់សព្វគ្រប់រួចហើយ លើកលែងតែតុលាការបានសម្រេចសេចក្តីផ្សេងពីនេះ។ ទោសដកសិទ្ធពលរដ្ឋអាចត្រូវបានប្រកាសជាស្ថាពរ ឬ ក៏ត្រឹមជាបណ្តោះអាសន្ន សម្រាប់រយៈពេលយ៉ាងច្រើន ៥ ឆ្នាំ[40]។

**ឧទាហរណ៍៖** តុលាការបានសម្រេចធ្វើការផ្តន្ទាទោសលើលោក **ក** ពីបទ **ប្រមាថបញ្ញុះសព** ដោយសារតែលោក **ក** បានជីកគាស់ផ្នូរសពមួយបំផ្លាញចោលដើម្បីយកដីមកធ្វើកម្មសិទ្ធិរបស់ខ្លួនឯង។បទប្រមាថទីបញ្ចុះសព គឺជាបទល្មើសព្រហ្មទណ្ឌដែលមានចែងនៅត្រង់មាត្រា២៦២ នៃក្រមព្រហ្មទណ្ឌ ហើយតម្រូវឱ្យផ្តន្ទាទោសដាក់ពន្ធធនាគារ ពី ១ខែ ទៅ ១ឆ្នាំ និងពិន័យជាប្រាក់ពី ១សែនរៀល ទៅ ២លានរៀល។ ម៉្យាងវិញទៀត ផ្អែកតាមមាត្រា២៦៤ ចំណុចទី ១ នៃក្រមព្រហ្មទណ្ឌ តុលាការអាចប្រកាសទោសបន្ថែម **ការដកសិទ្ធ ជាពលរដ្ឋខ្លះ** ចំពោះបទល្មើសនេះ។ ដូច្នេះ យោងតាមបទប្បញ្ញត្តិខាងលើនេះ តុលាការអាចប្រកាស ៖

១-ផ្តន្ទាទោសលោក **ក** ដាក់ពន្ធនាគារចំនួន ៣ខែ និងពិន័យជាប្រាក់ចំនួន ១លានរៀល (មូលទោស)។

២-ដកសិទ្ធិលោក **ក** ក្នុងការឈរឈ្មោះឲ្យគេបោះឆ្នោតឲ្យសម្រាប់រយៈពេល ៥ឆ្នាំ (ទោសបន្ថែម)។

- **ចំណុចទី២ ៖ ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ**

ក្នុងករណីដែលបទល្មើសបានប្រព្រឹត្ត នៅក្នុងពេលដែលប្រកបវិជ្ជាជីវៈណាមួយ ទោសបន្ថែមអាចជាការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈនោះ តែការហាមឃាត់នេះមិនអនុវត្តទៅលើ ៖

- ការបំពេញអាណត្តិដលជ្រើសតាំងដោយការបោះឆ្នោតជាសាធារណៈ។

**ឧទាហរណ៍៖** ការបំពេញមុខងារជាសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ស្រុក-ខណ្ឌ-ក្រុង ខេត្ត-រាជធានី គឺ ជាការបំពេញអាណត្តិដែលជ្រើសតាំងដោយការបោះឆ្នោតជាសាធារណៈ។ ដូច្នេះ តុលាការមិនអាចឱកាសនៅ ក្នុងសេចក្តីសម្រេច ដោយធ្វើការហាមឃាត់ជនជាប់ចោទមិនឱ្យបំពេញមុខងារជា ចៅសង្កាត់ ឬ មេឃុំ ដោយសារតែគាត់បានប្រព្រឹត្តបទល្មើសណាមួយនោះទេ ។

- ការទទួលខុសត្រូវខាងសហជីព ។

[40] មាត្រា៥៥ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីអំពី សិទ្ធិពលរដ្ឋដែលអាចដកបាន។

**ឧទាហរណ៍៖** មុខងារជាប្រតិភូបុគ្គលិក ឬ ប្រតិភូសហជីព តាមច្បាប់ស្តីពីការងារ គឺជាការទទួលខុសត្រូវ ខាងសហជីព។ ហេតុដូច្នេះ តុលាការមិនអាចប្រកាសទោសបន្ថែមដោយហាមឃាត់មិនឱ្យធ្វើជាប្រតិភូបុគ្គល ឬ ប្រតិភូសហជីពឡើយ។

- ចំពោះបទល្មើសរំលោភលើច្បាប់ស្តីពីរបបសារព័ត៌មាន ។

**ឧទាហរណ៍៖** អ្នកសារព័ត៌មានម្នាក់បានប្រព្រឹត្តបទល្មើសដែលបំពានលើច្បាប់ស្តីពី របបសារព័ត៌មាន។ ក្នុងករណីបែបនេះ តុលាការមិនអាចប្រកាសទោសបន្ថែមដោយហាមឃាត់មិនឱ្យជនជាប់ចោទប្រកបវិជ្ជាជីវៈជា អ្នកសារព័ត៌មានបានឡើយ ។

នៅក្នុងការប្រកាសទោសបន្ថែមនេះ តុលាការត្រូវបញ្ជាក់ឱ្យបានច្បាស់ពីមុខរបរដែលត្រូវហាមឃាត់។ សូមកត់សម្គាល់ថា ទោសបន្ថែមខាងលើត្រូវអនុវត្តក្រោយពេលទទួលរងទោសដាក់ពន្ធធនាគាររួចហើយ ប្រសិនបើមានលើកលែងតែមានសេចក្តីសម្រេចផ្សេងពីនេះរបស់តុលាការ។ មិនត្រឹមតែប៉ុណ្ណោះ ទោសបន្ថែមហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ អាចត្រូវប្រកាសជាស្ថាពរ (ជារៀងរហូត) ឬ ជាបណ្តោះអាសន្នសម្រាប់រយៈពេលយ៉ាងច្រើន៥ឆ្នាំ[41]។

**ឧទាហរណ៍៖** តុលាការបានសម្រេចផ្តន្ទាទោសលើលោក **ក** ដែលមានតួនាទីធ្វើជាអភិបាលនៃ ក្រុមហ៊ុនទទួលខុសត្រូវមានកម្រិតមួយពីបទ **ស៊ីសំណូករបស់អភិបាល** ដោយសារតែលោក **ក** បាន ទទួលអំណោយពីលោក **ខ** ដើម្បីជួយសម្រួលឱ្យលោក **ខ** ទទួលបានសិទ្ធិក្នុងការចុះកិច្ចសន្យាជាមួយនឹង ក្រុមហ៊ុន។ តាមមាត្រា២៨០ នៃក្រមព្រហ្មទណ្ឌ ជនដែលប្រព្រឹត្តបទស៊ីសំណូកដោយអភិបាលត្រូវទទួលការ ផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំទៅ ១០ឆ្នាំ ហើយយោងតាមមាត្រា២៨២ ចំណុចទី ២ នៃក្រមព្រហ្មទណ្ឌ តុលាការអាចនឹងប្រកាសទោសបន្ថែម **ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ** ចំពោះបទល្មើសនេះ។ ហេតុដូច្នេះ

ចំពោះករណី លោក **ក** តុលាការអាចប្រកាស ៖

១-ផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ៥ឆ្នាំ (មូលទោស)។

២-ហាមឃាត់លោក **ក** មិនឱ្យធ្វើជាអភិបាលក្រុមហ៊ុនសម្រាប់រយៈពេល ៣ឆ្នាំ ក្រោយពីបាន ទទួលរងទោសដាក់ពន្ធនាគារចប់សព្វគ្រប់ **(ទោសបន្ថែម)**។

[41] មាត្រា៥៦ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពី«ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ»។

- **ចំនុចទី៣ ៖ ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ**

ទោសបន្ថែម "**ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ**" ត្រូវអនុវត្តក្រោយពេលដែលបានទទួលរងទោសដាក់ពន្ធនាគាររួចហើយ លើកលែងតែមានសេចក្ដីសម្រេចផ្សេងពីនេះរបស់តុលាការ។ ទោសបន្ថែមនេះ ត្រូវមានរយៈពេលឱ្យលើសពី **៥ឆ្នាំ** ឡើយ[42]។

**ឧទាហរណ៍៖** តុលាការបានសម្រេចផ្ដន្ទាទោសលោក **ក** ពីបទ **លួច** ដោយសារតែលោក **ក** និង មិត្តភក្តិបានជិះម៉ូតូឆក់យកកាបូបដៃរបស់ជនរងគ្រោះជាស្ត្រី ហើយក្នុងការធ្វើសកម្មភាពម្ដងៗ លោក **ក** តែង តែគេចខ្លួនបានយ៉ាងស្រួល ដោយសារតែភាពប៉ិនប្រសប់ ក្នុងការបើកបរម៉ូតូគេចវេះពីការតាមចាប់ខ្លួនរបស់សមត្ថកិច្ច។

អំពើលួចមានចែងនៅមាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌដែលតម្រូវឱ្យផ្ដន្ទាទោសជនល្មើសដាក់ពន្ធនាគារពី ៦ខែ ទៅ ៣ឆ្នាំ និង ពិន័យជាប្រាក់ពី ១លានរៀល ទៅ ៦លានរៀល។ ម្យ៉ាងទៀត តាមមាត្រា៣៦២ ចំណុចទី ៣ នៃក្រមព្រហ្មទណ្ឌ តុលាការអាចប្រកាសទោសបន្ថែម **ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ** ចំពោះបទល្មើសនេះ។

ហេតុដូច្នេះ នៅក្នុងរឿងនេះ តុលាការអាចប្រកាស ៖

១-ផ្ដន្ទាទោសលោក **ក** ដាក់ពន្ធនាគារចំនួន ២ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៥លានរៀល (មូលទោស)។

២-ហាមឃាត់លោក **ក** ក្នុងការបើកបរយានយន្តគ្រប់ប្រភេទទាំងអស់សម្រាប់រយៈពេល ៥ឆ្នាំ ក្រោយពីបានអនុវត្តទោសដាក់ពន្ធនាគារចប់សព្វគ្រប់រួចហើយ **(ទោសបន្ថែម)**។

- **ចំណុចទី៤៖ ការព្យួរលិខិតបើកបរ**

ទោសបន្ថែម "ការព្យួរលិខិតបើកបរ" គឺជាទោសបន្ថែមដែលត្រូវអនុវត្តក្រោយពេលដែលទណ្ឌិតបានទទួលរងទោសដាក់ពន្ធនាគាររួចហើយ លើកលែងតែមានសេចក្ដីសម្រេចផ្សេងពីនេះរបស់តុលាការ។ ទោសព្យួរលិខិតបើកបរមិនត្រូវមានរយៈពេលលើសពី ៥ឆ្នាំ ឡើយ។ ទណ្ឌិតត្រូវប្រគល់លិខិតបើកបររបស់ខ្លួនទៅឱ្យក្រឡាបញ្ជីតុលាការ។ លិខិតបើកបរត្រូវរក្សាទុកតាមលក្ខខណ្ឌដែលកំណត់ដោយប្រកាសដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌[43]។

- **ចំណុចទី៥៖ ការហាមឃាត់ចំពោះការស្នាក់នៅ**

ទោសបន្ថែម "ការហាមឃាត់ចំពោះការស្នាក់នៅ" គឺជាការហាមឃាត់ដល់ទណ្ឌិត ចំពោះការមានមុខនៅទីកន្លែងខ្លះលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ ការហាមឃាត់ចំពោះការស្នាក់នៅ មិនអាចមានរយៈពេលលើសពី ១០ឆ្នាំ ឡើយ ចំពោះបទឧក្រិដ្ឋ និង ៥ឆ្នាំ ចំពោះបទមជ្ឈិម។ តុលាការមានសមត្ថកិច្ចជាអ្នកកំណត់បញ្ជីនៃទីកន្លែងដែលត្រូវហាមឃាត់ស្នាក់នៅ និងថិរវេលានៃការហាមឃាត់ចំពោះការស្នាក់នៅចំពោះទណ្ឌិត។ មួយវិញទៀត

[42] មាត្រា៥៧ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្ដីពី "ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ"។

[43] មាត្រា៥៨ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្ដីពី "ការព្យួរលិខិតបើកបរ"។

ការដាក់ទោសបន្ថែមនេះត្រូវតែរួមបញ្ចូលជាមួយផងដែរនូវវិធានការតាមដាន ទៀតផង។ វិធានការតាមដានត្រូវស្ដែងឡើង តាមរយៈការចូលបង្ហាញខ្លួនតាមដីកាកោះរបស់អាជ្ញាធរតុលាការ ឬ រដ្ឋបាលដែលតុលាការបានចាត់តាំង និងការចូលបង្ហាញខ្លួនឱ្យបានទៀងទាត់តាមការកំណត់នៅទីស្នាក់ការនគរបាល ឬ កងរាជអាវុធហត្ថ តាមការចាត់តាំងរបស់តុលាការ។ តុលាការត្រូវកំណត់នូវបែបបទនៃវិធានការតាមដាន ហើយព្រះរាជអាជ្ញាត្រូវជូនដំណឹងពីសេចក្ដីសម្រេចនេះដល់ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ[44]។ ទោសហាមឃាត់ចំពោះការស្នាក់នៅនេះ ត្រូវអនុវត្តក្រោយពេលដែលទណ្ឌិតបានទទួលរងនូវទោសដាក់ពន្ធនាគាររួចហើយ លើកលែងតែមានសេចក្ដីសម្រេចផ្សេងរបស់តុលាការ ។

**ឧទាហរណ៍៖** តុលាការបានសម្រេចផ្ដន្ទាទោសលោក **ក** ពីបទ អាសប្រព្រឹត្តទៅលើអនីតិជន អាយុតិចជាង ១៥ឆ្នាំ ដោយសារតែលោក **ក** តែងតែមានទម្លាប់រកក្មេងៗអាយុពី ១០ឆ្នាំ ទៅ ១២ឆ្នាំ ឱ្យមក លេងប្រដាប់ភេទរបស់ខ្លួន។ ជាញឹកញាប់ លោក **ក** តែងតែធ្វើអំពើបែបនេះនៅម្ដុំផ្ទះដែលគាត់ជួលគេស្នាក់ នៅក្នុងខណ្ឌដូនពេញ រាជធានីភ្នំពេញ។ បើពិនិត្យទៅលើច្បាប់ជាធរមានបច្ចុប្បន្នឃើញថា បទអាសប្រព្រឹត្តទៅលើ អនីតិជនអាយុតិចជាង ១៥ឆ្នាំ[45]ត្រូវទទួលការផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំ ទៅ ៣ឆ្នាំ និង ពិន័យជាប្រាក់ពី២លានរៀល ទៅ ៦លានរៀល។ លើសពីនេះទៀត តាមមាត្រា៣៤៩ ចំណុចទី ៣ នៃក្រមព្រហ្មទណ្ឌតុលាការអាចប្រកាសទោសបន្ថែម **ការហាមឃាត់ចំពោះការស្នាក់នៅ** ចំពោះការប្រព្រឹត្តបទល្មើសនេះបាន។

ហេតុដូច្នេះ តុលាការអាចសម្រេចសេចក្ដីដូចតទៅ ៖

១-ផ្ដន្ទាទោសលោក **ក** ដាក់ពន្ធនាគារចំនួន ២ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៣លានរៀល (មូលទោស)។

២-ហាមឃាត់លោក **ក** មិនឱ្យស្នាក់នៅរាជធានីភ្នំពេញ ក្នុងរយៈពេល ៥ឆ្នាំ បន្ទាប់ពីបានអនុវត្តទោសក្នុងពន្ធនាគារចប់សព្វគ្រប់ហើយ **(ទោសបន្ថែម)** ។

- **ចំណុចទី៦៖ ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា**

ដូចគ្នាទៅផងដែរ "**ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា**" ត្រូវអនុវត្តក្រោយពេលទណ្ឌិតបានទទួលរងទោសដាក់ពន្ធនាគាររួចរាល់អស់ហើយ លើកលែងតែករណីមានសេចក្ដីសម្រេចផ្សេងពីនេះរបស់តុលាការ។

---

[44] មាត្រា៥៩ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្ដីពី "ការហាមឃាត់ចំពោះការស្នាក់នៅ"។

[45] មាត្រា៣៤១ កថាខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌបានឱ្យនិយមន័យអំពើអាសថាជា អំពើនៃការប៉ះពាល់ ឬ ការបង្ហាញកេរភេទ ឬ ផ្នែកភេទផ្សេងទៀតរបស់ជនដទៃ ឬការឱ្យជនដទៃប៉ះពាល់កេរភេទ ឬ ផ្នែកភេទផ្សេងទៀតរបស់ជនល្មើសខ្លួនឯង ឬរបស់តតិយជន ក្នុងគោលបំណងធ្វើរំជួល ឬរីករាយដល់ចំណង់ផ្លូវភេទរបស់ជនល្មើស។

ទោសបន្ថែមខាងលើមានរយៈពេលមិនអាចលើសពី ៥ឆ្នាំ ឡើយដោយទណ្ឌិតត្រូវប្រគល់លិខិតឆ្លងដែនរបស់ខ្លួនទៅឱ្យក្រឡាបញ្ជីតុលាការ។ ទណ្ឌិតមិនអាចសុំលិខិតឆ្លងដែនវិញបានទេ ក្នុងរយៈពេលដែលកំពុងទទួលរងនូវទោសនោះ។ លិខិតឆ្លងដែនត្រូវរក្សាទុក តាមលក្ខខណ្ឌដែលបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌[46]។

**ឧទាហរណ៍៖** តុលាការបានសម្រេចផ្តន្ទាទោសលោក ខ ពីបទ **ប្រគល់ឱ្យរដ្ឋបរទេសនូវព័ត៌មានជា អាទិ៍ ដែលអាចធ្វើឱ្យអន្តរាយការការពារជាតិ**។ យោងតាមមាត្រា៤៤៥ នៃក្រមព្រហ្មទណ្ឌ បទប្រគល់ឱ្យរដ្ឋបរ ទេសនូវព័ត៌មានដែលអាចធ្វើឱ្យអន្តរាយការការពារជាតិ[47] ត្រូវទទួលរងការផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ឆ្នាំ ទៅ ១៥ឆ្នាំ។ តាមមាត្រា៤៥០ ចំណុចទី៤ នៃក្រមព្រហ្មទណ្ឌ តុលាការអាចប្រកាសទោសបន្ថែម **ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា** ចំពោះការប្រព្រឹត្តបទល្មើសនេះ។

ដូច្នេះ តុលាការអាចសម្រេចសេចក្តីថា ៖

១-ផ្តន្ទាទោសលោក **ខ** ដាក់ពន្ធនាគារចំនួន ១០ឆ្នាំ **(មូលទោស)**។

២-ហាមឃាត់លោក **ខ** មិនឱ្យចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់រយៈពេល ៥ឆ្នាំ បន្ទាប់ពីលោក ខ បានអនុវត្តទោសនៅក្នុងពន្ធធនាគារចប់សព្វគ្រប់ហើយ **(ទោសបន្ថែម)**។

- **ចំណុចទី៧៖ ការហាមឃាត់ចំពោះការចូល និងស្នាក់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា**

ទោសបន្ថែមខាងលើនេះ អាចយកទៅអនុវត្តបានចំពោះតែទណ្ឌិតដែលជាជនបរទេសតែប៉ុណ្ណោះ។ ដូច្នេះការហាមឃាត់ខាងលើអាចជាការហាមឃាត់ស្ថាពរ ឬ ជាការហាមឃាត់មានរយៈពេល ៥ឆ្នាំ យ៉ាងច្រើនបំផុត។ ព្រមជាមួយគ្នានេះ ការដាក់ទោសបន្ថែមខាងលើនឹងមានអានុភាពនាំឱ្យមានការបណ្តេញទណ្ឌិតជាជនបរទេស ឱ្យចាកចេញពីទឹកដីនៃព្រះរាជាណាចក្រកម្ពុជា នៅពេលដែលទណ្ឌិតបានបញ្ចប់ទោសដាក់ពន្ធនាគាររួចអស់ ហើយនោះ[48]។ ជាទូទៅទោសបន្ថែមខាងលើនេះត្រូវតែអនុវត្តក្រោយពេលដែលទណ្ឌិតបានទទួលរងទោសដាក់ពន្ធនាគារចប់សព្វគ្រប់រួចហើយ។

**ឧទាហរណ៍៖** តុលាការបានសម្រេចផ្តន្ទាទោសលោក **ផានេត** មានសញ្ជាតិជប៉ុនពី **បទរំលោភសេពសន្ថវៈ** លើនារីរងគ្រោះជាពលរដ្ឋខ្មែរ។ បទរំលោភសេពសន្ថវៈ ត្រូវទទួលការផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ទៅ ១០ឆ្នាំ តាម

[46] មាត្រា៦០ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពី "ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា"។

[47] បទប្រគល់ឱ្យរដ្ឋបរទេសនូវព័ត៌មានជាអាទិ៍ដែលអាចធ្វើឱ្យអន្តរាយការការពារជាតិ សំដៅទៅលើអំពើប្រគល់ ឬធ្វើឱ្យងាយស្រួលធ្លាក់ដល់ដៃរដ្ឋបរទេស ឬភ្នាក់ងារបរទេសនូវព័ត៌មាន វិធី វត្ថុ ឯកសារ ឬទិន្នន័យព័ត៌មានវិទ្យា ឬសាលាកបត្រ ដែលអាចធ្វើឱ្យអន្តរាយការការពាតជាតិ **(មាត្រា៤៤៥ នៃក្រមព្រហ្មទណ្ឌ)**។

[48] មាត្រា៦១ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពី "ការហាមឃាត់ចំពោះការចូល និងស្នាក់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា"។

មាត្រា២៣៩ នៃក្រមព្រហ្មទណ្ឌ ហើយចំពោះបទល្មើសនេះ តាមមាត្រា ២៤៥ នៃក្រមព្រហ្មទណ្ឌ តុលាការអាចប្រកាសទោសបន្ថែម ការហាមឃាត់ទណ្ឌិតបរទេសចំពោះការចូល ឬ ការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាជាស្ថាពរ ឬ សម្រាប់រយះពេល ៥ឆ្នាំ យ៉ាងច្រើន[49]។

នៅក្នុងសម្មតិកម្មខាងលើ តុលាការអាចសម្រេចសេចក្ដីដូចតទៅ ៖

១-ផ្ដន្ទាទោសលោក **ផានេត** ដាក់ពន្ធនាគារចំនួន ៩ឆ្នាំ **(មូលទោស)** ។

២-ហាមឃាត់លោក **ផានេត** មិនឱ្យចូល និងស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាជាស្ថាពរក្រោយ ពីបានអនុវត្តទោសនៅក្នុងពន្ធនាគារចប់សព្វគ្រប់ហើយ **(ទោសបន្ថែម)**។

យោងតាមក្រមព្រហ្មទណ្ឌ បន្ទាប់ពីលោក **ផានេត** បានបញ្ចប់ការអនុវត្តទោសក្នុងពន្ធនាគាររួចហើយលោក **ផានេត** នឹងត្រូវបណ្ដេញចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជាភ្លាម។

- **ចំណុចទី៨៖ ការរឹបអូស**

ការរឹបអូសអាចធ្វើទៅលើវត្ថុដូចតទៅ៖

- ឧបករណ៍ សម្ភារៈ ឬ វត្ថុមួយដែលបានប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើសឬដែលសម្រាប់ប្រព្រឹត្តបទល្មើស
- វត្ថុ ឬ មូលនិធិដែលជាកម្មវត្ថុនៃបទល្មើស
- ផលទុន ឬ ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស
- ឧបភោគភ័ណ្ឌ[50] សម្ភារៈ និង ចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសបានប្រព្រឹត្ត
- យានជំនិះដែលជារបស់ទណ្ឌិត ។

ការរឹបអូស ដែលនាំឱ្យមានការប៉ះពាល់ដល់សិទ្ធរបស់តតិយជន មិនអាចប្រកាសដោយតុលាការដោយតុលាការបានទេ។ ដោយឡែក ទ្រព្យសម្បត្តិដែលត្រូវបានរឹបអូសនឹងក្លាយជាកម្មសិទ្ធរបស់រដ្ឋ កាលបើការរឹប អូសនេះបានក្លាយជាស្ថាពរ លើកលែងតែមានបទប្បញ្ញត្តិដោយឡែកដែលចែងអំពីការប្រគល់ផ្សេងពីនេះ[51]។

**ឧទាហរណ៍៖** តុលាការបានសម្រេចផ្ដន្ទាទោសលោកស្រី **ក** ពី **បទគំរាមកំហែងថានឹងសម្លាប់** តាមមាត្រា ២៣៣ នៃក្រមព្រហ្មទណ្ឌ ដោយសារតែលោកស្រី **ក** បានធ្វើការគំរាមកំហែងថានឹងសម្លាប់កញ្ញា **គ** ដែលជាស្ត្រីកំណាន់ចិត្តប្ដីរបស់នាងតាមទូរស័ព្ទ។ ការគំរាមកំហែងថានឹងសម្លាប់ គឺជាបទល្មើសដែលមានចែង ឱ្យផ្ដន្ទាទោសតាមមាត្រា២៣៣ នៃក្រមព្រហ្មទណ្ឌ ហើយត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៦ខែ ទៅ២ឆ្នាំ និង ពិន័យជាប្រាក់ពី ១លានរៀល

[49] បទរំលោភសេពសន្ថវៈ សំដៅលើគ្រប់អំពើបញ្ចូលអង្គជាតិ តាមបែបណាក៏ដោយ ឬអំពើបញ្ចូលឧបករណ៍ណាមួយទៅក្នុងអង្គជាតិដែលប្រព្រឹត្តទៅលើអ្នកដទៃ ទោះបីមានភេទដូចគ្នាក៏ដោយ ឬមិនដូចគ្នាក៏ដោយ ដោយការប្រើហឹង្សា ការបង្ខិតបង្ខំ ការគំរាមគំហែង ឬដោយការឆ្មក់ឱកាស (**មាត្រា២៣៩ កថាខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌ**)។

[50] ឧបភោគភ័ណ្ឌ គឺជារបស់ ឬអីវ៉ាន់សម្រាប់ប្រើប្រាស់ជិតៗខ្លួន។

[51] មាត្រា៦៣ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្ដីអំពី"ការរឹបអូស"។

ទៅ ៤លានរៀល។ យោងតាមមាត្រា២៣៥ នៃក្រមព្រហ្មទណ្ឌ ទោសបន្ថែមដែល អាចប្រកាសបានសម្រាប់បទល្មើស នេះមានការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុដទៃទៀតដែលប្រើសម្រាប់ប្រព្រឹត្ត បទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស។

ដូច្នេះនៅក្នុងករណីបែបនេះ តុលាការអាចធ្វើការសម្រេចសេចក្តីដែលមានខ្លឹមសារដូចខាងក្រោម៖

១-ផ្តន្ទាទោសលោកស្រី **ក** ដាក់ពន្ធធនាគារចំនួន៦ខែនិងពិន័យជាប្រាក់ចំនួន ៣លានរៀល (មូលទោស)

២-រឹបអូសទូរស័ព្ទ (វត្ថុដែលលោកស្រី ក បានប្រើប្រាស់ដើម្បីសម្រេចបទល្មើស) **(ទោសបន្ថែម)**។

- **ចំណុចទី៩៖ ការហាមឃាត់ចំពោះការកាន់កាប់ ឬ យកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ**

ការហាមឃាត់នេះត្រូវអនុវត្តទៅលើអាវុធ គ្រឿងផ្ទុះនិងគ្រាប់រំសេវគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ មាត្រា៤៨៨ នៃក្រមព្រហ្មទណ្ឌបានឱ្យនិយមន័យ អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដូចតទៅ៖

- អាវុធ សំដៅដល់កាំភ្លើងគ្រប់ប្រភេទដែលផលិត ឬ កែច្នៃដំឡើង និងដែលអាចប្រើប្រាស់ដើម្បីសម្លាប់ឬធ្វើឱ្យរបួស ឬ ធ្វើឱ្យប៉ះពាល់ខូចខាតដល់ទ្រព្យសម្បត្តិ។

- គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ សំដៅដល់ឧបករណ៍ ឬ សម្ភារៈដែលគេផលិត ឬ កែច្នៃដែលអាចប្រើប្រាស់សម្លាប់ ឬ ធ្វើឱ្យរបួស ឬ ធ្វើឱ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិ។

ការហាមឃាត់ដូចខាងលើនេះអាចធ្វើឡើងជាស្ថាពរ ឬ ជាបណ្តោះអាសន្នសម្រាប់រយៈពេល៥ឆ្នាំយ៉ាងច្រើន[52]។ **ឧទាហរណ៍៖** តុលាការបានសម្រេចផ្តន្ទាទោសលោក **ក** ពី **បទបង្កឱ្យមានរបួសដោយអចេតនា** ដោយសារតែការធ្វេសប្រហែសធ្វើឱ្យកាំភ្លើងខ្លីរបស់ខ្លួនផ្ទុះបណ្តាលឱ្យរាលកែផ្ទុះមួយគ្រាប់ ទៅត្រូវជនម្នាក់ដែលកំពុងតែឈរនៅក្បែរនោះឱ្យទទួលរងរបួសយ៉ាងធ្ងន់ធ្ងរ។ ចំពោះបទបង្កឱ្យមានរបួសដោយអចេតនា[53] ជនល្មើសអាច ប្រឈមមុខនឹងការផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ខែ ទៅ ២ឆ្នាំ និងពិន័យជាប្រាក់ពី ១លានរៀល ទៅ ៤លានរៀល យោងតាមមាត្រា២៣៦ នៃក្រមព្រហ្មទណ្ឌ។ ផ្អែកតាមមាត្រា ២៣៧ នៃក្រមព្រហ្មទណ្ឌតុលាការអាចប្រកាស ទោសបន្ថែម **ការហាមឃាត់ការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ** សម្រាប់ រយៈពេល ៥ឆ្នាំយ៉ាងច្រើន។

ក្នុងស្ថានភាពដូចខាងលើនេះ តុលាការអាចប្រកាសទោសចំពោះលោក **ក** ដូចខាងក្រោម ៖

១-ផ្តន្ទាទោសលោក **ក** ដាក់ពន្ធនាគារចំនួន ១ឆ្នាំ និងពិន័យជាប្រាក់ចំនួន ២លានរៀល (មូលទោស)។

[52] មាត្រា៦៤ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីអំពី"ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ"។

[53] អំពើបង្កឱ្យមានរបួសដោយអចេតនា គឺជាអំពើដែលបណ្តាលឱ្យមានរបួសដល់អ្នកដទៃ ដោយការធ្វេសប្រហែស ការមិនប្រុងប្រយ័ត្ន ការខ្ជីខ្ជាដែលបង្កឱ្យមានសមត្ថភាពធ្វើការងារ ឬ លើសពី ៨ថ្ងៃ ឬក៏ដោយការបំពានលើកាតព្វកិច្ចសន្តិសុខ ឬកាតព្វកិច្ចប្រុងប្រយ័ត្នដែលច្បាប់តម្រូវ (មាត្រ២៣៦ កថាខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌ)។

២-ហាមឃាត់លោក **ក** មិនឱ្យកាន់កាប់ ឬ យកតាមខ្លួននូវអាវុធគ្រឿងផ្ទុះ និងគ្រប់រំសេវគ្រប់ប្រភេទសម្រាប់រយៈពេល ១ឆ្នាំ គិតចាប់ពីពេលដែលបានអនុវត្តទោសពន្ធនាគារចប់សព្វគ្រប់ (**ទោសបន្ថែម**)។

- **ចំណុចទី១០៖ ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ**

លទ្ធកម្មសាធារណៈ គឺជាកិច្ចសន្យាដែលបានស្នើឡើងដោយរដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ (**រាជធានី- ខេត្ត ក្រុង ស្រុក-ខណ្ឌ ឃុំ-សង្កាត់**) គ្រឹះស្ថានសាធារណៈ (**ឧទាហរណ៍ ៖ សាកលវិទ្យាល័យ**) និងសហគ្រាស ដែលត្រូវបានធ្វើ សម្បទាន ឬ ត្រួតត្រាដោយរដ្ឋ ឬ ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។

ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ ជាហេតុនាំឱ្យមានការហាមឃាត់ចំពោះការចូលរួមដោយផ្ទាល់ ឬ ដោយប្រយោលក្នុងលទ្ធកម្មសាធារណៈទាំងឡាយដែលរៀបចំដោយរដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈ សហគ្រាសដែលទទួលសម្បទានពីរដ្ឋ ឬ ពីរដ្ឋបាលថ្នាក់ក្រោមជាតិ ឬ ដែលត្រួតពិនិត្យដោយរដ្ឋ ឬ ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ[54]។

លើសពីនេះទៀត ទោសបណ្តេញចេញពីលទ្ធកម្មសាធារណៈ អាចជាការបណ្តេញចេញជាស្ថាពរបានន័យថា មិនអនុញ្ញាតឱ្យទណ្ឌិតចូលរួមនៅក្នុងលទ្ធកម្មសាធារណៈជារៀងរហូត ឬ ជាការបណ្តេញចេញសាធារណៈ សម្រាប់រយៈពេល ៥ឆ្នាំ យ៉ាងច្រើនបំផុត[55]។

**ឧទាហរណ៍៖** ក្រុមហ៊ុនឯកជន **ក** ដែលមានកម្មវត្ថុបើកភោជនីយដ្ឋានមួយកន្លែង ត្រូវបានតុលាការផ្តន្ទាទោសពីបទ **ផ្តល់អាហារដែលមានសារជាតិពុល** យោងតាមមាត្រា ២២៦ នៃក្រមព្រហ្មទណ្ឌ។ បញ្ញត្តិនេះចែង ថា អំពើលក់ ធ្វើអនុប្បទាន (**ផ្ទេរ**) ឬ ឱ្យចំណី ឬ ភេសជ្ជៈ ដោយដឹងថា ចំណី ឬ ភេសជ្ជៈនោះមានសារជាតិពុលនាំ ឱ្យខូចសុខភាពនោះ ត្រូវចាត់ទុកជាអំពើហិង្សាដោយចេតនា។ អំពើហិង្សាដោយចេតនា គឺជាបទល្មើសព្រហ្ម ទណ្ឌដែលមានចែងនៅមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំ ទៅ ៣ឆ្នាំ និង ពិន័យជាប្រាក់ពី ២លានរៀល ទៅ ៦លានរៀល ។ ក៏ប៉ុន្តែសម្រាប់ចារីជានីតិបុគ្គលវិញ មាត្រា២៣០ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌ តម្រូវឱ្យផ្តន្ទាទោសពិន័យជាប្រាក់ពី ១០លានរៀល ទៅ ៥០លានរៀល។ ចំពោះបទ ល្មើសប្រភេទនេះ តុលាការអាចប្រកាសទោសបន្ថែម **ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ** ដូចមានចែងនៅ មាត្រា២៣០ កថាខណ្ឌទី ២ ចំណុចទី៤ នៃក្រមព្រហ្មទណ្ឌ។

[54] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី-ខេត្ត-ក្រុង-ស្រុក-ខណ្ឌ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០០៨ត្រង់ មាត្រា៩ បានកំណត់ថា រាជធានី/ខេត្ត ក្រុង-ស្រុក-ខណ្ឌ គឺជានីតិបុគ្គលនៃនីតិសាធារណៈ។ ចំណែកគ្រឹះស្ថានសាធារណៈវិញ គឺជានីតិបុគ្គលនៃនីតិសាធារណៈក្រៅពីរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានភារកិច្ចគ្រប់គ្រងសេវាសាធារណៈណាមួយ។

[55] មាត្រា៦៥ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីអំពី"ការបណ្តេញចេញពីលទ្ធកម្មនៃសាធារណៈ"។

ហេតុដូច្នេះ នៅក្នុងសម្មតិកម្មដូចខាងលើ តុលាការអាចធ្វើការសម្រេចសេចក្តីដែលមានខ្លឹមសារដូចខាងក្រោម៖

១-ផ្តន្ទាទោស ក្រុមហ៊ុន **ក** ឱ្យបង់ប្រាក់ពិន័យចំនួន ៤០លានរៀល **(មូលទោស)**។

២-បណ្តេញក្រុមហ៊ុន **ក** ចេញពីលទ្ធកម្មសាធារណៈគ្រប់ប្រភេទរយៈពេល ២ឆ្នាំគិតចាប់ពីពេលសាលក្រមនេះចូលជាស្ថាពរ **(ទោសបន្ថែម)**។

- **ចំណុចទី១១៖ ការបិទគ្រឹះស្ថាន**

ទោសបន្ថែម "**បិទគ្រឹះស្ថាន**" គឺជាទោសដែលនាំឱ្យមានការហាមឃាត់ចំពោះការធ្វើសកម្មភាពនៅក្នុងគ្រឹះស្ថាន ដែលនៅក្នុងឱកាសធ្វើសកម្មភាពធ្វើសកម្មភាពនោះ បទល្មើសត្រូវបានប្រព្រឹត្តឡើង។ តុលាការអាចសម្រេចឱ្យបិទគ្រឹះស្ថានដែលពាក់ព័ន្ធជាស្ថាពរ ឬ ជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥ឆ្នាំ យ៉ាងច្រើន[56]។

**ឧទាហរណ៍ទី១៖** លោកស្រី **ក** ជាម្ចាស់ផ្ទះសំណាក់មួយកន្លែង ត្រូវបានតុលាការរកឃើញថា មានពិរុទ្ធភាពពីបទយល់ព្រមឱ្យសកម្មភាពពេស្យាចារនៅក្នុងគ្រឹះស្ថាន ដែលបានប្រព្រឹត្តនៅក្នុងផ្ទះសំណាក់របស់ គាត់ ដោយយោងតាមមាត្រា២៩២ នៃក្រមព្រហ្មទណ្ឌ។ អនុលោមតាមបញ្ញត្តិនេះ ជនល្មើសអាចប្រឈមនឹង ការផ្តន្ទាទោសដាក់ពន្ធនាគារពី ២ឆ្នាំ ទៅ ៥ឆ្នាំ និង ពិន័យជាប្រាក់ពី ៤លានរៀល ទៅ ១០លានរៀល។ ម្យ៉ាងទៀត មាត្រា២៩៥ ចំណុចទី១១ នៃក្រមព្រហ្មទណ្ឌបានអនុញ្ញាតុលាការឱ្យប្រកាសទោសបន្ថែមដែលជាការបិទ គ្រឹះស្ថាន ចំពោះការប្រព្រឹត្តបទល្មើសប្រភេទនេះ។

ដូច្នេះ តាមសម្មតិកម្មខាងលើ តុលាការប្រកាសមូលទោសដែលជាទោសដាក់ពន្ធនាគារ និង/ឬ ទោសពិន័យជាប្រាក់ ព្រមទាំងអាចប្រកាសទោសបន្ថែមដែលមានខ្លឹមសារតម្រូវឱ្យបិទទ្វារផ្ទះសំណាក់ខាងលើ ដែល ជាទីកន្លែងបទល្មើសត្រូវបានប្រព្រឹត្ត។ បើទោសបន្ថែមនេះត្រូវបានប្រកាសសម្រាប់រយៈពេលមួយជាកំណត់នោះ គឺមិនត្រូវឱ្យលើសពី ៥ឆ្នាំ ឡើយ។

- **ចំណុចទី១២៖ ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន**

ទោសបន្ថែមនេះ សំដៅទៅលើការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានដែលបើកចំហសម្រាប់សាធារណជន ឬ ដែលត្រូវបានប្រើប្រាស់ដោយសាធារណជន។ ទោសនេះអាចជាការហាមឃាត់ជាស្ថាពរ ឬ ជាការហាមឃាត់ជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥ឆ្នាំ យ៉ាងច្រើន[57]។

**ឧទាហរណ៍៖** តុលាការបានសម្រេចផ្តន្ទាទោសចំពោះលោក **ក** ជាម្ចាស់ហាងទទួលបញ្ចាំវត្ថុម្នាក់ដោយសារតែគាត់បានប្រព្រឹត្ត បទទទួលផលចារកម្ម ។ផ្អែកតាមមាត្រា៤០០ នៃក្រមព្រហ្មទណ្ឌ អំពើទទួលផលចារកម្មគឺជាបទ

[56] មាត្រា៦៦ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីអំពី"ការបិទគ្រឹះស្ថាន"។

[57] មាត្រា៦៧ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីអំពី"**ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន**"។

ល្មើសដែលត្រូវផ្តន្ទាទោសដាក់ពន្ធធនាគារពី ២ឆ្នាំ ទៅ ៥ឆ្នាំ និងពិន័យជាប្រាក់ពី ៤លានរៀលទៅ ១០លានរៀល។ ម្យ៉ាងវិញទៀត ទោសបន្ថែម **ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន** ត្រូវបានអនុញ្ញាតឱ្យយកទៅប្រកាសបាន ចំពោះជនដែលបានប្រព្រឹត្ត បទទទួលផលចោរកម្ម ស្របទៅតាមមាត្រា៤០៣ ចំណុចទី១៣ នៃក្រមព្រហ្មទណ្ឌ។

ហេតុដូច្នេះ តុលាការអាចសម្រេចសេចក្តីដូចខាងក្រោម៖

១-ផ្តន្ទាទោសលោក **ក** ដាក់ពន្ធធនាគារចំនួន ២ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៨លានរៀល **(មូលទោស)។**

២-ហាមឃាត់លោក **ក** មិនឱ្យធ្វើអាជីវកម្មទទួលបញ្ចាំ ក្នុងរយៈពេល ២ឆ្នាំ គិតចាប់ពីពេលសាលក្រមនេះចូលជាស្ថាពរ **(ទោសបន្ថែម)។**

- **ចំណុចទី១៣៖ ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស**

ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស ត្រូវតែអនុវត្តនៅទីកន្លែងដែលបានចង្អុលបង្ហាញដោយតុលាការ និងក្នុងរយៈពេលមួយដែលបានកំណត់ដោយតុលាការ។ ប៉ុន្តែការបិទផ្សាយនេះ មិនអាចមានរយៈពេលលើសពី២ខែ បានទេ។ មួយវិញទៀត តុលាការអាចបង្គាប់ឱ្យមានការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោសទាំងស្រុង ឬ តាមសម្រង់ ឬ តាមនិទ្ទេសធម្មតាក៏បានដែរ[58]។ ទោះក្នុងករណីណាក៏ដោយ សោហ៊ុយបិទផ្សាយគឺជាបន្ទុករបស់ទណ្ឌិត។

នៅក្នុងករណីដែលមានការបំបាត់ចោល ការលាក់បំបាំង ឬ ការហែកចោលសេចក្តីប្រកាសនេះ ចាំបាច់ត្រូវតែធ្វើការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោសសារជាថ្មី។ ក៏ប៉ុន្តែ ចំពោះការបិទផ្សាយលើកក្រោយនេះត្រូវ ចេញសោហ៊ុយដោយអ្នកបំបាត់ចោល អ្នកលាក់បាំង ឬ អ្នកដែលបានហែកចោលនូវសេចក្តីប្រកាសដែលបាន ធ្វើលើកមុន[59]។ តាមការពិត ទោសបន្ថែមខាងលើនេះមានគោលបំណងធ្វើឱ្យប៉ះពាល់ដល់កិត្តិយស និងកេរ្តិ៍ឈ្មោះរបស់ទណ្ឌិត ដោយសារតែតុលាការបានសម្រេចផ្តន្ទាទោសលើទណ្ឌិតអំពីបទល្មើសដែលទណ្ឌិតបានប្រព្រឹត្ត។

**ឧទាហរណ៍៖** តុលាការបានសម្រេចផ្តន្ទាទោសលោក **ក** ពី **បទឆបោក**។ តាមមាត្រា ៣៧៨ នៃក្រម ព្រហ្មទណ្ឌ អំពើឆបោកដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ខែ ទៅ ៣ឆ្នាំ និងពិន័យជាប្រាក់ពី ១លានរៀល ទៅ៦លានរៀល។ សម្រាប់បទល្មើសនេះ តុលាការអាចប្រកាសទោសបន្ថែម **ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស** បានអនុលោមតាមមាត្រា៣៨២ ចំណុចទី ១១ នៃក្រមព្រហ្មទណ្ឌ។ ហេតុដូច្នេះ បន្ថែមពីលើមូលទោសនៃបទល្មើសនេះ

[58] ការបិទផ្សាយនូវសេចក្តីសម្រេចផ្តន្ទាទោសទាំងស្រុង សំដៅទៅលើការបិទផ្សាយនូវខ្លឹមសារនៃសាលក្រម ឬសាលដីកាទាំងមូល។ **សម្រង់សេចក្តីសម្រេច** គឺជាការដកស្រង់យកផ្នែកនៃសេចក្តីសម្រេចចុងក្រោយរបស់សាលក្រម ឬសាលដីកាផ្តន្ទាទោស។ ការបិទផ្សាយតាមនិទ្ទេសធម្មតា សំដៅទៅលើការបិទផ្សាយឯកសារដែលមានខ្លឹមសារគ្រាន់តែបញ្ជាក់ថា មានការផ្តន្ទាទោសលើទណ្ឌិតចំពោះបទល្មើសដែលបានប្រព្រឹត្ត។

[59] មាត្រា៦៨ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីអំពី"ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស"។

**(ពោលគឺទោសដាក់ពន្ធនាគារ និង ពិន័យជាប្រាក់)** តុលាការអាចបង្គាប់ឱ្យបិទផ្សាយ សេចក្តីសម្រេចអំពីទណ្ឌកម្ម ដែលបានផ្តន្ទាលើលោក **ក** នៅមុខលំនៅឋានផ្ទាល់របស់លោក **ក** និងនៅ សាលាសង្កាត់ដែលលោក **ក** រស់នៅ សម្រាប់រយៈពេល ១ខែ ដោយតម្រូវឱ្យលោក **ក** ជាអ្នកទទួលបន្ទុក ចេញសោហ៊ុយនៃការបិទផ្សាយនេះ[60]។

- **ចំណុចទី១៤៖ ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ**

ទោសបន្ថែមស្តីពី **"ការផ្សាយសេចក្តីសម្រេចរបស់តុលាការក្នុងសារពត៌មានសរសេរ"** សំដៅទៅលើការចុះផ្សាយពីសេចក្តីសម្រេចផ្តន្ទាទោសលើទណ្ឌិតទៅក្នុងសារព័ត៌មានសរសេរអនុលោមតាមបែបបទនិងក្នុងថិរវេលាដែរកំណត់ដោយតុលាការ ហើយសោហ៊ុយក្នុងការចុះផ្សាយត្រូវជាបន្ទុករបស់ទណ្ឌិត។ នៅក្នុងករណីមិនព្រមគោរពតាម ទណ្ឌិតអាចត្រូវបង្ខំដល់រូបកាយ។ ប្រសិនបើ តុលាការបានបង្គាប់ឱ្យធ្វើការផ្សព្វផ្សាយសេចក្តី សម្រេចផ្តន្ទាទោសតាមរយៈសារព័ត៌មាននោះសារព័ត៌មានមិនអាចធ្វើការបដិសេធការផ្សព្វផ្សាយនេះបានទេ[61]។

**ឧទាហរណ៍៖** តុលាការបានសម្រេចផ្តន្ទាទោសលើលោក **ក** ពី **បទគំរាមកំហែងហែកកេរ្តិ៍** ដោយសារតែលោក **ក** បានគំរាមយកប្រាក់ចំនួន ២០លានរៀល ពីសង្សាររបស់ខ្លួនជាថ្នូរទៅនឹងការមិនផ្សព្វផ្សាយរូបភាព អាសអាភាសរបស់នាង។ បទគំរាមកំហែងហែកកេរ្តិ៍ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ឆ្នាំ ទៅ ៥ឆ្នាំ និងពិន័យជាប្រាក់ពី ៤លានរៀល ទៅ ១០លានរៀល បើយោងតាមមាត្រា៣៧៣ នៃក្រមព្រហ្មទណ្ឌ[62] ។ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន គឺជាទោសបន្ថែមដែលអាចយកមកអនុវត្តបានចំពោះបទល្មើសនេះស្រប តាមមាត្រា៣៧៦ ចំណុចទី ១២ នៃក្រមព្រហ្មទណ្ឌ។

ហេតុដូច្នេះ តុលាការអាចសម្រេចសេចក្តីដូចតទៅ ៖

១-ផ្តន្ទាទោសលោក **ក** ដាក់ពន្ធនាគារចំនួន ៣ឆ្នាំ **(មូលទោស)**។

២-បង្គាប់ឱ្យធ្វើការបិទផ្សាយនូវសេចក្តីសម្រេចផ្តន្ទាទោសខាងលើនេះ នៅក្នុងសារពត៌មាន **"រស្មីកម្ពុជា"** សម្រាប់រយៈពេល ៧ថ្ងៃ ជាបន្តបន្ទាប់ជាប់ៗ គ្នាក្រោយពីសាលក្រមនេះបានចូលជាធរមានជាស្ថាពរ **(ទោសបន្ថែម)**

៣-បង្គាប់ឱ្យលោក **ក** ទទួលបន្ទុកចេញសោហ៊ុយនៃការបិទផ្សាយតាមចំណុចទី ២ ខាងលើ។

- **ចំណុចទី១៥៖ ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសតាមមធ្យាបាយទូរគមនាមន៍សោតទស្សន៍**

ទោសបន្ថែមស្តីពី **"ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍"** ត្រូវអនុវត្តស្របតាមបែបបទដែលកំណត់ដោយតុលាការ។មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សំដៅទៅទូរទស្សន៍ វិទ្យុ ជាដើម។ អនុលោមតាមក្រមព្រហ្មទណ្ឌ ការផ្សាយនេះមិនអាចមានរយៈពេលលើសពី ៨ថ្ងៃ បានឡើយហើយការ

---

[60] មាត្រា៣៧៧ នៃក្រមព្រហ្មទណ្ឌចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ បានឱ្យនិយមន័យការឆបោក។

[61] មាត្រា៦៩ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីអំពី"ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ"។

[62] មាត្រា៣៧២ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ បានឱ្យនិយមន័យនៃការគំរាមកំហែងហែកកេរ្តិ៍។

ផ្សព្វផ្សាយសេចក្តីសម្រេចផ្តន្ទាទោសអាចធ្វើឡើងទាំងស្រុង ឬ តាមសម្រង់ ឬ តាមនិទ្ទេសក៏បានដែរ។ ចំពោះសោហ៊ុយនៃការផ្សព្វផ្សាយគឺជាបន្ទុករបស់ទណ្ឌិត[63]។

**ឧទាហរណ៍៖** ដូចក្នុងសម្មតិកម្មខាងលើទាក់ទងនឹងអំពើរបស់លោក **ក** នៅក្នុងឧទាហរណ៍ខាងលើ តុលាការអាចសម្រេចឱ្យធ្វើការផ្សាយសេចក្តីសម្រង់ទណ្ឌកម្មលើលោក **ក** នៅតាមទូរទស្សន៍ **ទ.ទ.ក.** សម្រាប់រយៈពេល ៣ថ្ងៃ ជាប់ៗគ្នា ដោយឱ្យលោក **ក** ជាអ្នកទទួលបន្ទុកចេញសោហ៊ុយនៃការផ្សព្វផ្សាយនេះ[64]។ ទោះបីជាក្រមព្រហ្មទណ្ឌបានកំណត់ឱ្យមានទោសបន្ថែម ក្នុងចំនួនដូចមានចែងនៅមាត្រា៥៣ កថាខណ្ឌទី១ នៃក្រម ព្រហ្មទណ្ឌក្តី ក៏ក្រមព្រហ្មទណ្ឌអនុញ្ញាតឱ្យបទប្បញ្ញត្តិដោយឡែកបង្កើតជាទោសបន្ថែមផ្សេងៗទៀតបានដែរ[65]។

### ២.២.៣. លក្ខខណ្ឌនៃការប្រកាសទោសបន្ថែម

តាមបញ្ញត្តិនៃមាត្រា៥៤ បានចែងថា៖ ទោសបន្ថែមនឹងអាចប្រកាសទៅបាន លុះត្រាតែទោសនេះត្រូវបានបែងចែកដោយជាក់លាក់ចំពោះបទ ឧក្រិដ្ឋ បទមជ្ឈិម ឬ បទលហុ ដែលត្រូវចោទប្រកាន់។ ម្យ៉ាងវិញទៀត ទោសបន្ថែមអាចប្រកាសក៏បានមិនប្រកាសក៏បាន។ ទោសបន្ថែមត្រូវប្រកាសជាកាតព្វកិច្ច ប្រសិនបើច្បាប់ចែងយ៉ាងជាក់លាក់[66]។

ខ្លឹមសារខាងលើ បានសេចក្តីថា ការប្រកាសទោសបន្ថែមអាចធ្វើទៅបាន លុះត្រាតែបទល្មើសដែលត្រូវ ចោទប្រកាន់នោះ បានចែងអំពីទោសបន្ថែម។ ករណីដែលពុំមានចែងអំពីទោសបន្ថែម តុលាការមិនអាចជ្រើស រើសប្រភេទនៃទោសបន្ថែមណាមួយយកមកប្រកាសបាននោះទេ។ ហើយចំពោះការប្រកាសទោសបន្ថែម ពុំមាន លក្ខណៈដាច់ខាតដែលតុលាការត្រូវតែប្រកាសគ្រប់ទោសបន្ថែមដែលមាននោះទេ ការប្រកាសទោសបន្ថែមអាច ត្រូវប្រកាស ឬ មិនត្រូវប្រកាស អាស្រ័យលើការថ្លឹងថ្លែងរបស់តុលាការ ព្រោះដើម្បីឱ្យសមស្របទៅនឹងទម្ងន់នៃ បទល្មើស និងកាលៈទេសៈដែលពាក់ព័ន្ធបទល្មើស។ ក៏ប៉ុន្តែ ប្រសិនបើច្បាប់បានចែងជាកាតព្វកិច្ចថា ត្រូវតែប្រកាសនោះតុលាការមិនអាចមិនប្រកាសបាននោះទេ។

### ២.២.៤. ការប្រកាសទោសបន្ថែមចំពោះរូបវន្តបុគ្គល

រូបវន្តបុគ្គល (នីតិជន អនីតិជន) ក្រោយពីប្រកាសមូលទោស ក៏អាចត្រូវបានប្រកាសទោសបន្ថែមដែរ។ ហើយតាមបញ្ញត្តិមាត្រា៥៤ ការប្រកាសទោសបន្ថែម កថាខណ្ឌទី២ បានកំណត់ថា ទោសបន្ថែមអាចប្រកាសក៏បាន មិនប្រកាសក៏បាន។ ទោសបន្ថែមត្រូវប្រកាសជាកាតព្វកិច្ច។

[63] មាត្រា៧០ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីអំពី"ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍"។

[64] មាត្រា៣៧៦ ចំណុចទី១៣ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

[65] មាត្រា៥៣ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

[66] មាត្រា៥៤ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីអំពី"លក្ខខណ្ឌនៃការប្រកាសទោសបន្ថែម"។

### ២.២.៤.១. ការប្រកាសទោសបន្ថែមចំពោះរូបវន្តបុគ្គលជានីតិជន

ជាទូទៅ តាមរយៈបញ្ញត្តិនៃក្រមព្រហ្មទណ្ឌ ការប្រកាសទោសបន្ថែមអាចធ្វើឡើងជា ពីរករណីគឺការប្រកាសទោសបន្ថែមលើមូលទោស និងការប្រកាសទោសបន្ថែមជំនួសមូលទោស។ ការប្រកាសទោសបន្ថែមលើមូលទោសគឺសំដៅដល់ការប្រកាសទោសបន្ថែមត្រួតជាមួយនឹងមូលទោស មានន័យថា ប្រកាសមូលទោសផង និងប្រកាសទោសបន្ថែមផង ដើម្បីឱ្យទណ្ឌិតអនុវត្តទាំងពីរ។

នៅក្នុងមាត្រា៩៩ កាលណាបទល្មើសត្រូវផ្តន្ទាទោសដោយទោសបន្ថែមមួយ ឬ ច្រើនទោសបន្ថែមនេះត្រូវបន្ថែមទៅលើមូលទោស លើកលែងតែបញ្ញត្តិនៃមាត្រា១០០ (ការជំនួសមូលទោស ដោយទោសបន្ថែម) នៃក្រមនេះចេញ[67]។

**ឧទាហរណ៍៖** តុលាការប្រកាសមូលទោសដាក់ពន្ធនាគារ ១ឆ្នាំ និងទោសបន្ថែម ដោយហាមមិនឱ្យបើកបរយានយន្តគ្រប់ប្រភេទក្នុងរយៈពេល ២ឆ្នាំ។ ដូចនេះ ទោសទាំងពីរត្រូវអនុវត្តរួមគ្នាដោយជាប់ពន្ធនាគាររយៈពេល ១ឆ្នាំ និងហាមមិនឱ្យបើកបរយានយន្តគ្រប់ប្រភេទក្នុងរយៈពេល ២ឆ្នាំ។ ជាទូទៅ ដើម្បីអាចប្រកាសទោសបន្ថែមបាន លុះត្រាតែ ទោសបន្ថែមនេះមានចែងយ៉ាងជាក់លាក់ដូចបានរៀបរាប់ខាងលើនៅក្នុងមាត្រា៥៤ ដែលជាលក្ខខណ្ឌនៃការប្រកាសទោសបន្ថែមមានន័យថា បានចែងយ៉ាងជាក់លាក់ចំពោះមាត្រាដែលបានផ្តន្ទាទោសចំពោះបទល្មើសនឹងតែម្តង។ បើសិនជាមិនបានចែងជាក់លាក់ទេ ចៅក្រមមិនអាចប្រកាសពីទោសបន្ថែមដើម្បី បន្ថែមទៅលើមូលទោសឡើយ។

បទប្បញ្ញត្តិនៃមាត្រា២០៧ ក្នុងក្រមព្រហ្មទណ្ឌថ្មី ដែលចែងអំពីករណីមនុស្សឃាតដោយអចេតនា។ ច្បាប់ចែងផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ ពី ២លានរៀល ទៅ ៦លាន រៀល។ ប៉ុន្តែដើម្បីចៅក្រមអាចប្រកាសអំពីទោសបន្ថែមទៅលើមូលទោស ដូចជាទោសគុក ឬ មួយទោសពិន័យជាប្រាក់បាននោះ លុះត្រាតែ មានបញ្ញត្តិមួយទៀតចែងថា ចំពោះបទល្មើសទាក់ទងជាមួយមនុស្សឃាតដោយអចេតនាចៅក្រមអាចប្រកាសទោសបន្ថែមមួយ ឬ ច្រើនបាន។ បើយោងលើន័យនេះ មាត្រា២០៨ ទោសបន្ថែមអាចត្រូវប្រកាសចំពោះបទល្មើសមនុស្សឃាតដោយអចេតនា បានកំណត់ចាប់ពីចំណុចទី១ ដល់ ចំណុចទី៧ ៖

- **ចំណុចទី១៖** ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ បើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។
- **ចំណុចទី២៖** ការហាមឃាត់ចំពោះការបើកបរយានយន្ត ទោះបីជាប្រភេទណាក៏ដោយសម្រាប់រយៈ ពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។
- **ចំណុចទី៣៖** ការព្យួរលិខិតបើកបរ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

[67] មាត្រា៩៩ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីអំពី"ការប្រកាសទោសបន្ថែមលើមូលទោស"។

- **ចំណុចទី៤៖** ហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និង គ្រាប់រំសេវគ្រប់ប្រភេទ សម្រាប់រយៈពេល ៥ (ប្រាំ) យ៉ាងច្រើន ។

- **ចំណុចទី៥៖** ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន។

- **ចំណុចទី៦៖** ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន។

- **ចំណុចទី៧៖** ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។ ហេតុនេះ នៅពេលដែលមានចែងជាក់លាក់ ដូចនេះចៅក្រមអាចប្រកាសទោសបន្ថែមមួយ ឬ ច្រើនដែលមានចែងនៅក្នុងបញ្ញត្តិនៃមាត្រា២០៨ ដើម្បីអនុវត្តទៅលើមូលទោសដែលគាត់ផ្តន្ទាទោសយោងតាមបញ្ញត្តិនៃមាត្រា២០៧ ទាក់ទងជាមួយបទមនុស្សឃាតដោយអចេតនាបាន។ ការប្រកាសទោសបន្ថែមជំនួសមូលទោស សំដៅដល់ការប្រកាសតែទោសបន្ថែមដោយជំនួសលើមូលទោសតែម្តងពោលគឺប្រកាសតែទោសបន្ថែមតែឯកឯង។ កាលណាសម្រេចប្រកាសទោសបន្ថែមមួយ ឬ ច្រើនជំនួសមូលទោស តុលាការមិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬ ទោសពិន័យជាប្រាក់បានទេ[68]។

ដូចបានរៀបរាប់ខាងលើនេះ ការប្រកាសទោសបន្ថែមមាន ២ករណីគឺការប្រកាសទោសបន្ថែមលើមូលទោស និងការប្រកាសទោសបន្ថែមជំនួសមូលទោស ។

### ២.២.៤.២. ការប្រកាសទោសបន្ថែមចំពោះរូបវន្តបុគ្គលជាអនីតិជន

ក្រមព្រហ្មទណ្ឌបានកំណត់ពី ការប្រកាសទោសបន្ថែមចំពោះរូបវន្តបុគ្គលជានីតិជន ដូចបានបកស្រាយខាងលើនេះ ក៏បានកំណត់ពីការប្រកាសទោសបន្ថែមចំពោះរូបវន្តបុគ្គលជាអនីតិជនដែរ ដោយក្រមព្រហ្មទណ្ឌបានបញ្ញត្តិនៅក្នុងមាត្រា ១៦១ ស្តីពីទោសបន្ថែម ចំពោះរូបវន្តបុគ្គលជាអនីតិជន។ តើការប្រកាសទោសបន្ថែមចំពោះរូបវន្តបុគ្គលជាអនីតិជន ធ្វើឡើងយ៉ាងដូចម្តេច? ចំពោះអនីតិជនដែលមានអាយុក្រោម ១៤ឆ្នាំ និងអនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ។

#### ក. អនីតិជនដែលមានអាយុក្រោម ១៤ឆ្នាំ

អនីតិជនដែលមានអាយុក្រោម ១៤ឆ្នាំ ក្រមព្រហ្មទណ្ឌមិនបានកំណត់ពីការប្រកាសទោសបន្ថែមឡើយជាពិសេសមូលទោសក៏មិនត្រូវបានរងនោះដែរមានន័យថាទាំងមូលទោសនិងទាំងទោសបន្ថែមចំពោះអនីតិជនដែលមានអាយុក្រោម ១៤ឆ្នាំ ត្រូវបានរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ។ ប៉ុន្តែអនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ ច្បាប់បានកំណត់ពីការទទួលខុសត្រូវមួយចំនួនចំពោះការប្រកាសទោសបន្ថែមសម្រាប់បុគ្គលប្រភេទនេះ។ តើការទទួលខុសត្រូវមួយចំនួន ចំពោះការប្រកាសទោសបន្ថែមសម្រាប់អនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ មានអ្វីខ្លះ?

[68] មាត្រា១០០ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីអំពី“ការជំនួសមូលទោសដោយទោសបន្ថែម”។

**ខ. អនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ**

កាលណាបញ្ញត្តិនៃច្បាប់ព្រហ្មទណ្ឌ មិនបានកំណត់ពីការសម្រេចផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំទេ តុលាការក៏មានសិទ្ធិប្រើប្រាស់នូវទោសបន្ថែម ដើម្បីអនុវត្តដូចបុគ្គលជានីតិជនផងដែរ។ ប៉ុន្តែខុសត្រង់ថា ទោសបន្ថែមដែលអាចប្រកាសសម្រាប់អនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ នេះ គឺមានកំណត់ត្រង់មាត្រា១៦១ ស្តីពី ទោសបន្ថែមមាន ៥ ចំណុចតែប៉ុណ្ណោះ។ តើទោសបន្ថែម ៥ ចំណុចនេះមាន អ្វីខ្លះ? ។

ដូច្នេះ ដោយយោងតាមបញ្ញត្តិមាត្រា១៦១ បានបញ្ញត្តិថា៖ មានតែទោសបន្ថែមដូចតទៅនេះប៉ុណ្ណោះ ដែលអាចអនុវត្តទៅលើអនីតិជនៈ

១. ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុអ្វីមួយដែលបានប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

២. ការរឹបអូសវត្ថុ ឬ មូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

៣. ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៤. ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬ ចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត។

៥. ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និង គ្រាប់រំសេវគ្រប់ប្រភេទ។

## ២.៣ ទោសជំនួស

ទោសជំនួស គឺមានចែងក្នុងក្រមព្រហ្មទណ្ឌជាប្រភេទទី៣ នៃទោសចាប់ពីមាត្រា៧២ ដល់មាត្រា៧៦ ដែលចែងអំពីទោសជំនួសនេះ។ ម៉្យាងវិញទៀត ទោសជំនួស គឺជាទោសការងារសហគមន៍ និងទោសស្តីបន្ទោស ដែលត្រូវបានកំណត់ជំនួសទោសដាក់ពន្ធនាគារ[69]។

កាលដែលតុលាការប្រើទោសជំនួសដើម្បីជំនួសមូលទោស គឺអាស្រ័យទៅលើស្ថានភាពកាលៈទេសៈនៃបទល្មើស ហើយជាពិសេសផ្អែកទៅលើគោលការណ៍មនុស្សធម៌។

### ២.៣.១. និយមន័យនៃទោសជំនួស

ទោសជំនួស គឺជាទោសដែលតុលាការយកមកប្រកាសជំនួសឱ្យមូលទោស និងសម្រាប់អនុវត្តជំនួសមូលទោស។ ក្នុងករណីដូចនេះ មាត្រា ៩៨ នៃក្រមព្រហ្មទណ្ឌមិនតម្រូវឱ្យតុលាការប្រកាសការផ្តន្ទាទោសដាក់ពន្ធនាគារ ឬ ពិន័យជាប្រាក់ទេ។ ដោយផ្អែកទៅលើគោលការណ៍មនុស្សធម៌ចៅក្រមអាចពិនិត្យទៅលើស្ថានភាពកាលៈទេសៈនៃការប្រព្រឹត្តបទល្មើសដោយមិនអនុវត្តទោស ដែលជាមូលដ្ឋានដោយយកទោសជំនួសមកអនុវត្តវិញ។

[69] សទ្ទានុក្រមពាក្យច្បាប់នៃក្រមព្រហ្មទណ្ឌ ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ ២០១១ លេខរៀងទី ៤៨។

### ២.៣.២. ប្រភេទនៃទោសជំនួស

យោងតាមក្រមព្រហ្មទណ្ឌ ទោសជំនួសត្រូវបានបែងចែកចេញជា ២ ប្រភេទគឺៈ

១-ទោសការងារសហគមន៍ និង

២-ទោសស្តីបន្ទោស ។

### ២.៣.២.១. ទោសការងារសហគមន៍

ទោសការងារសហគមន៍ គឺជាជម្រើសមួយដ៏ល្អសម្រាប់តុលាការយកទៅអនុវត្តចំពោះទណ្ឌិតក្នុងគោលបំណងជាប្រយោជន៍ដល់សហគមន៍ឱ្យសមស្របនឹងស្ថានភាពនៃបទល្មើស។

**ក. និយមន័យនៃទោសការងារសហគមន៍**

ទោសការងារសហគមន៍ គឺជាកាតព្វកិច្ចត្រូវបំពេញក្នុងថិរវេលាចន្លោះពី ៣០ ម៉ោង ទៅ ២០០ ម៉ោង នូវការងារគ្មានកម្រៃជាប្រយោជន៍ដល់រដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ ឬ នីតិបុគ្គលនៃនីតិសាធារណៈផ្សេងៗទៀត ដល់សមាគម ឬ ដល់អង្គការមិនមែនរដ្ឋាភិបាល[70]។ សម្រាប់អនីតិជនវិញ ទោសការងារសហគមន៍ អាចប្រកាសបាន លុះត្រាតែជននេះមានអាយុយ៉ាងតិច ១៦ឆ្នាំ និងត្រូវមានថិរវេលាមិនត្រូវលើសពី ១០០ ម៉ោង ឡើយ ស្របតាមមាត្រា១៦២ នៃក្រមព្រហ្មទណ្ឌ។

ទោះក្នុងករណីណាក៏ដោយ ការងារសហគមន៍ពុំអាចបំពេញជាប្រយោជន៍ ដល់រូបវន្តបុគ្គលបានទេ។ តុលាការអាចប្រកាសទោសការងារសហគមន៍ បើកាលណាជនជាប់ចោទទទួលទោសដាក់ពន្ធនាគារដែលអតិបរមាតិចជាង ឬ ស្មើនឹង ៣ (បី) ឆ្នាំ។

ដូចនេះ ទោសការងារសហគមន៍ គឺសំដៅដល់កាតព្វកិច្ចមួយ ដែលត្រូវបំពេញនូវការងារមួយដែលគ្មានកម្រៃ និងជាប្រយោជន៍សាធារណៈ មានន័យថា ជាប្រយោជន៍របស់រដ្ឋរបស់រដ្ឋបាលថ្នាក់ក្រោមជាតិរបស់នីតិបុគ្គលនៃនីតិសាធារណៈដ៏ទៃទៀត ឬ របស់សហគមន៍របស់អង្គការមិនមែនរដ្ឋាភិបាល។

**ខ. របបគតិយុត្តនៃការងារសហគមន៍**[71]

គតិយុត្ត មានន័យថា តាមគន្លងច្បាប់ ឬ ដែលទាក់ទងទៅនឹងច្បាប់ដែលត្រឹមត្រូវទៅតាមច្បាប់។

ការងារសហគមន៍អាចត្រួតគ្នាបានជាមួយនឹងការអនុវត្តសកម្មភាពវិជ្ជាជីវៈ។ ការងារសហគមន៍ គឺត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ការងារជាអាទិ៍ ការងារនៅពេលយប់ អនាម័យ សន្តិសុខ និងការងាររបស់ស្ត្រី។ ប៉ុន្តែ ភាគច្រើនគឺ មិនសូវប្រើចំពោះការងារកុមារនោះទេ ព្រោះកុមារ ឬ អនីតិជន ដែលមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ ច្រើនតែប្រើប្រាស់នូវយន្តការថ្មីស្តីពី "**ការស្តីបន្ទោស**" ទៅវិញ។

[70] សទ្ទានុក្រមពាក្យច្បាប់នៃក្រមព្រហ្មទណ្ឌ ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ ២០១១ លេខរៀងទី ៤៧។

[71] មាត្រា៧៤ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែ វិច្ឆកា ឆ្នាំ ២០០៩ ស្តីអំពី "របបគតិយុត្តនៃការងារសហគមន៍"។

**គ. អ្នកមិនទទួលផលប្រយោជន៍នៃការងារសហគមន៍**[72]

នៅក្នុងគ្រប់ករណីទាំងអស់ ការងារសហគមន៍មិនអាចបំពេញជាប្រយោជន៍នៃរូបវន្តបុគ្គលទេ ព្រោះនេះជាផលប្រយោជន៍របស់ឯកជនសុទ្ធសាធមិនមែនជាផលប្រយោជន៍របស់សាធារណៈទេ ។

**ឃ. គោលការណ៍ជួសជុលការខូចខាតដល់អ្នកដទៃ**[73]

រដ្ឋត្រូវតែចេញសោហ៊ុយជួសជុលការខូចខាតដែលបង្កដល់អ្នកដទៃដោយទណ្ឌិតនៅក្នុងពេលដែលកំពុងអនុវត្តការងារសហគមន៍។ រដ្ឋត្រូវធ្វើឧបាទេសកម្មដោយពេញច្បាប់ទៅក្នុងសិទ្ធិជនរងគ្រោះ ពីព្រោះពេលខ្លះជនដែលទទួលរងនូវការងារសហគមន៍នេះគ្មានថវិកាបង់ខ្លួនឯងទេ។ ផ្ទុយទៅវិញ បើរដ្ឋមិនចេញសំណងឱ្យនោះទេ ជនរងគ្រោះនឹងមិនទទួលបានការជួសជុលនូវព្យសនកម្ម ឬ ការខូចខាតឡើយ។ សរុបមក ដើម្បីឱ្យមានយុត្តិធម៌ ក្រមព្រហ្មទណ្ឌថ្មី ក៏បានកំណត់ឱ្យរដ្ឋត្រូវធ្វើឧបាទេសកម្មដោយពេញច្បាប់ទៅក្នុងសិទ្ធិរបស់ជនរងគ្រោះវិញ។

ឧបាទេសកម្ម គឺជាឋានៈមួយដែលបុគ្គលម្នាក់ទទួលជំនួសបុគ្គលណាមួយទៅតាមផ្លូវច្បាប់។ ដូចនេះរដ្ឋក្លាយទៅជាម្ចាស់បំណុលដើម្បីប្ដឹងទាមទារសំណងពីទណ្ឌិតនោះវិញ ប៉ុន្តែបើជននោះគ្មានថវិកាបង់សងជូនរដ្ឋទាល់តែសោះ ហេតុនេះ ថវិកាដែលរដ្ឋចេញសងជំនួសនោះមិនទទួលបានត្រឡប់មករដ្ឋវិញទេ ពីព្រោះទណ្ឌិតគ្មានថវិកាសងរដ្ឋឡើយ។

**២.៣.២.២. ទោសស្ដីបន្ទោស**

ទោសស្ដីបន្ទោស គឺជាប្រភេទទោសមួយដែលចៅក្រមយកមកអនុវត្តសម្រាប់បទល្មើសស្រាល ដោយមិនមានការផ្ដន្ទាទោសដាក់ពន្ធនាគារ ក៏ពិន័យជាប្រាក់ទេ។ ម្យ៉ាងវិញទៀត ទោសស្ដីបន្ទោស គឺជាការព្រមាន ការស្ដីប្រដៅអំពីទោស ឬ កំហុសឆ្គង ដែលជនល្មើសបានប្រព្រឹត្ត ហើយជាការប្រមានថាលើកក្រោយកុំប្រព្រឹត្តបទល្មើសតទៅទៀត។ ទោសស្ដីបន្ទោស គឺភាគច្រើនប្រើចំពោះកុមារ ឬ អនីតិជន ដែលមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោមអាយុ ១៨ឆ្នាំ ព្រោះថាកុមារមិនមែនជាកម្មវត្ថុនៃតុលាការព្រហ្មទណ្ឌ ឬ នីតិវិធីព្រហ្មទណ្ឌ ក៏ដូចជាទោសព្រហ្មទណ្ឌដែលមានចែងក្នុងក្រមព្រហ្មទណ្ឌនោះដែរ។

ហេតុដូច្នេះ តុលាការអាចប្រកាសនូវយន្តការស្ដីបន្ទោសមួយនេះ ទៅលើអនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោមអាយុ ១៨ឆ្នាំ បាន។ ប៉ុន្តែ តុលាការនឹងប្រាប់ផងដែរថា ថ្ងៃក្រោយគ្មានការអនុគ្រោះណាមួយទៀតទេ ប្រសិនបើជននោះនៅតែប្រព្រឹត្តធ្វើបែបនោះទៀត។

[72] មាត្រា៧៣ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែ វិច្ឆកា ឆ្នាំ ២០០៩ ស្ដីអំពី "អ្នកមិនទទួលផលប្រយោជន៍នៃការងារសហគមន៍"។

[73] មាត្រា៧៥ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែ វិច្ឆកា ឆ្នាំ ២០០៩ ស្ដីអំពី "គោលការណ៍ជួសជុលការខូតខាតដល់អ្នកដទៃ"។

**ក. និយមន័យនៃទោសស្ដីបន្ទោស**

អត្ថន័យនៃទោសស្ដីបន្ទោស មិនខុសអំពីការបកស្រាយខាងលើនេះទេ ព្រោះថាទោសស្ដីបន្ទោសប្រើសម្រាប់តែបទល្មើសស្រាល តាមរយៈការប្រមានការប្រដៅអំពីទោសកំហុសឆ្គងដើម្បីកុំឱ្យគាត់ប្រព្រឹត្តបទល្មើសតទៅទៀត[74]។

ទោសស្ដីបន្ទោសនេះភាគច្រើនប្រើដូចបានបកស្រាយពីចំណុចខាងលើនេះប្រើសម្រាប់តែចំពោះ កុមារ ឬ អនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោមអាយុ ១៨ឆ្នាំ។

បើយោងតាមអនុសញ្ញាស្ដីពី សិទ្ធកុមារ ដែលបានអនុម័តចុះហត្ថលេខាសច្ចាប័ន និងចូលជាសមាជិក តាមសេចក្ដីសម្រេច លេខ ៤៤/២៥ ចុះថ្ងៃពី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩ របស់មហាសន្និបាតអង្គការសហប្រជាជាតិ ដែលចូលជាធរមាននៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៩០ ស្របតាមមាត្រា ៤៩ បានបញ្ជាក់ឱ្យដឹងថា កុមារមិនមែនជាកម្មវត្ថុនៃតុលាការព្រហ្មទណ្ឌ ឬ នីតិវិធីព្រហ្មទណ្ឌ ក៏ដូចជាទោសព្រហ្មទណ្ឌដូចមានចែងនៅក្នុងក្រមព្រហ្មទណ្ឌនោះដែរ។ ផ្ទុយទៅវិញ ប្រសិនបើករណីនេះជាជម្រើសចុងក្រោយដែលនាំឱ្យតុលាការប្រកាសទណ្ឌកម្មព្រហ្មទណ្ឌខាងលើ អនីតិជនមានអាយុចាប់ពី ១៤ឆ្នាំ ឡើងទៅ តុលាការអាចប្រើប្រាស់នូវយន្តការថ្មីមួយនេះ បានមានន័យថាប្រើការស្ដីបន្ទោសទៅលើគាត់តែម្ដង។

**ខ. របបគតិយុត្តនៃការស្ដីបន្ទោស**[75]

កាលបើជនជាប់ចោទរងទោសដាក់ពន្ធនាគារដែលអតិបរមាតិចជាង ឬ ស្មើនឹង ៣ (បី) ឆ្នាំ តុលាការអាចប្រកាសទោសស្ដីបន្ទោស ប្រសិនបើមានគ្រប់លក្ខខណ្ឌទាំងបីដូចតទៅនេះ៖

- ភាពចលាចលដល់សណ្ដាប់ធ្នាប់សាធារណៈដែលបណ្ដាលមកពីបទល្មើសបានបញ្ចប់
- ការខូចខាតត្រូវបានជួសជុលរួចហើយ និង
- ជនជាប់ចោទបានបង្ហាញការធានាក្នុងការចូលទៅរួមរស់នៅក្នុងសង្គមវិញ។

**២.៣.៣. ការប្រកាសទោសជំនួស**

តាមការបកស្រាយខាងលើ ចំពោះទោសជំនួសត្រូវបានបែងចែកជា ២ ប្រភេទគឺ ទោសការងារសហគមន៍ និងទោសស្ដីបន្ទោស។

ការប្រកាសទោសជំនួស គឺប្រកាសទៅលើទោសការងារសហគមន៍ និងទោសស្ដីបន្ទោស ដោយការប្រកាសនេះគឺ ប្រកាសចំពោះរូបវន្តបុគ្គលជានីតិជន និងជានីតិជន។

---

[74] យោងតាមប្រសាសន៍របស់ឯកឧត្តម កើត រិទ្ធ អនុប្រធានក្រុមការងារចូលរួមតាក់តែង និងការពារសេចក្ដីព្រាងក្រមព្រហ្មទណ្ឌ នៅក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្ដីពី "ក្រមព្រហ្មទណ្ឌ" ដែលរៀបចំឡើងដោយក្រសួងយុត្តិធម៌សហការជាមួយក្រសួងពត៌មាន តាមរយៈទូរទស្សន៍ជាតិកម្ពុជា ឆ្នាំ ២០១០។

[75] មាត្រា៧៦ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែ វិច្ឆកា ឆ្នាំ ២០០៩ ស្ដីអំពី "របបគតិយុត្តនៃការស្ដីបន្ទោស"។

ការប្រកាសទោសការងារសហគមន៍ និងទោសស្តីបន្ទោសនេះ ត្រូវគោរពទៅតាមលក្ខខណ្ឌដែលមានកំណត់នៅក្នុងក្រមព្រហ្មទណ្ឌ។

តើការប្រកាសទោសការងារសហគមន៍ និងទោសស្តីបន្ទោសមានលក្ខខណ្ឌអ្វីខ្លះ? ហើយប្រកាសចំពោះរូបវន្តបុគ្គលជានីតិជន និងអនីតិជនមានលក្ខណៈដូចម្តេច?

### ២.៣.៣.១. ការប្រកាសទោសការងារសហគមន៍

ទោសការងារសហគមន៍ គឺជាទោសដែលគេតម្រូវឱ្យទណ្ឌិតធ្វើប្រយោជន៍រួមគ្មានកម្រៃទេ ក៏ប៉ុន្តែជា ប្រយោជន៍សម្រាប់សាធារណៈ។ ទោសនេះអាចអនុវត្តបានអាស្រ័យទៅតាមលក្ខខណ្ឌដែលមានចែងនៅក្នុងបទប្បញ្ញត្តិចាប់ពីមាត្រា៧២ ដល់ មាត្រា៧៤ មាត្រា៩៨ និងចាប់ពីមាត្រា១០១ ដល់ មាត្រា១០៣ នៃក្រមព្រហ្មទណ្ឌដែលជាលក្ខខណ្ឌរួម។

#### ក. លក្ខខណ្ឌនៃការប្រកាសទោសការងារសហគមន៍

តុលាការអាចប្រកាសទោសការងារសហគមន៍បាន លុះត្រាតែបំពេញនូវលក្ខខណ្ឌខាងក្រោម៖

- កាលណាជនជាប់ចោទទទួលទោសដាក់ពន្ធនាគារ ដែលអតិបរមា តិចជាង ឬ ស្មើនឹង ៣ (បី) ឆ្នាំ យោងតាម (មាត្រា៧២ កថាខណ្ឌទី១)[76] ។

- ជនជាប់ចោទមានវត្តមាននៅពេលសវនាការហើយយល់ព្រមធ្វើការងារនេះ យោងតាម (មាត្រា១០១ នៃក្រមព្រហ្មទណ្ឌ)[77]។

#### ខ. ការប្រកាសទោសការងារសហគមន៍

ទោសការងារសហគមន៍ជំនួសឱ្យមូលទោស តុលាការដែលប្រកាសទោសការងារសហគមន៍មិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬ ពិន័យជាប្រាក់បានទេដោយយោងតាមមាត្រា៩៨ កថាខណ្ឌទី ១នៃក្រមព្រហ្មទណ្ឌ ។

តុលាការដែលប្រកាសទោសការងារសហគមន៍ ត្រូវប្រកាសតាមការកំណត់ខាងក្រោម៖

- កំណត់កាតព្វកិច្ចដែលត្រូវបំពេញការងារចន្លោះពី ៣០ (សាមសិប) ម៉ោង ទៅ ២០០ (ពីររយម៉ោង) ម៉ោង(យោងតាមមាត្រា ៧២ កថាខណ្ឌទី ២ នៃក្រមព្រហ្មទណ្ឌ)។

- កំណត់អំពីថិរវេលានៃការងារ និងរយៈពេលដែលត្រូវបំពេញមិនលើសពី ១ ឆ្នាំ យោងតាម (មាត្រា១០២ នៃក្រមព្រហ្មទណ្ឌ)[78]។

---

[76] មាត្រា៧២ កថាខណ្ឌទី ២ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែ វិច្ឆកា ឆ្នាំ ២០០៩ ស្តីអំពី "និយមន័យនៃការងារសហគមន៍"។

[77] មាត្រា១០១ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែ វិច្ឆកា ឆ្នាំ ២០០៩ ស្តីអំពី វិធានដោយឡែកសម្រាប់ការប្រកាសទោសការងារសហគមន៍"។

[78] មាត្រា១០២ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែ វិច្ឆកា ឆ្នាំ ២០០៩ ស្តីអំពី "ថិរវេលា និងអំឡុងពេលនៃការងារសហគមន៍"។

បែបបទនៃការអនុវត្តទោសការងារសហគមន៍ត្រូវកំណត់ដោយព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញាចង្អុលប្រាប់នីតិបុគ្គលដែលត្រូវទទួលអត្ថប្រយោជន៍ពីការងារនេះ។ ទោសនេះត្រូវអនុវត្តនៅក្រោមការត្រួតពិនិត្យរបស់ព្រះរាជអាជ្ញាយោងតាម (មាត្រា១០៣ នៃក្រមព្រហ្មទណ្ឌ)[79]។

### គ. ការប្រកាសទោសការងារសហគមន៍ទៅលើរូបវន្តបុគ្គលជានីតិជន

ទោសការងារសហគមន៍ គឺជាទោសមួយដែលគេតម្រូវឱ្យធ្វើការងារជាប្រយោជន៍រួមមួយគ្មានកម្រៃទេ ប៉ុន្តែជាប្រយោជន៍សម្រាប់សាធារណៈ។ ទោសនេះអាចអនុវត្តបានអាស្រ័យទៅតាមលក្ខខណ្ឌដែលមានចែងនៅក្នុងបទប្បញ្ញត្តិចាប់ពីមាត្រា៧២ ដល់មាត្រា៧៤, មាត្រា៩៨ និង ចាប់ពីមាត្រា១០១ ដល់ មាត្រា១០៣ នៃក្រមព្រហ្មទណ្ឌដែលជាលក្ខខណ្ឌរួម។

មាត្រា៧២ បានផ្តល់ជាលក្ខខណ្ឌរួម កាលណាជនជាប់ចោទទទួលទោសដាក់ពន្ធនាគារ ដែលអតិបរមាតិចជាង ឬ ស្មើនឹង ៣ (បី) ឆ្នាំ តុលាការអាចប្រកាសទោសការងារសហគមន៍បាន មានន័យថា លក្ខខណ្ឌបើប្រើជាមួយបទល្មើសធ្ងន់ធ្ងរត្រូវផ្តន្ទាទោសលើសពី ៣ (បី) ឆ្នាំ គឺមិនអាចប្រើទោសការងារសហគមន៍បានឡើយ។ ផ្ទុយទៅវិញ បើសិនជាផ្តន្ទាទោសដាក់ពន្ធនាគារដែលអតិបរមានោះតិចជាង ឬ ស្មើនឹង ៣ (បី) ឆ្នាំ ទើបតុលាការអាចប្រកាសទោសការងារសហគមន៍នេះបាន។ ប៉ុន្តែបន្ថែមទៅលើលក្ខខណ្ឌមួយនេះច្បាប់ចែងថា ទោសការងារសហគមន៍អាចប្រកាសទៅបានលុះត្រាតែ ជនជាប់ចោទមានវត្តមាននៅពេលសវនាការ ហើយគាត់យល់ព្រមទទួលយកទោសការងារសហគមន៍នេះ។ ចំពោះមាត្រា ១០១ គឺបញ្ញត្តិកុំឱ្យផ្ទុយទៅនឹងនិយាមការងាររបស់អង្គការពលកម្មអន្តរជាតិនៃអង្គការសហប្រជាជាតិ ព្រោះបានហាមឃាត់ការងារដោយបង្ខំ។ ដូចនេះ លុះត្រាតែជនជាប់ចោទគាត់បានព្រមទទួលយកខ្លួនឯងនៅក្នុងពេលសវនាការ។ ហើយដើម្បីបញ្ជាក់ពីលក្ខខណ្ឌនោះ ក្រមព្រហ្មទណ្ឌ បានបញ្ជាក់បន្ថែមទៀតថា មុនពេលដែលចៅក្រមប្រកាសសាលក្រម ឬ សាលដីកាទាក់ទងទៅនឹងការងារសហគមន៍នេះ គាត់ត្រូវសួរបញ្ជាក់ជនជាប់ចោទនៅពេលសវនាការមុនសិនថា តើជនជាប់ចោទយល់ព្រមទទួលនូវ ការងារសហគមន៍ដែរ ឬ ទេ? បានសេចក្តីថា ជនជាប់ចោទមានសិទ្ធិប្រកែកមិនព្រមធ្វើកិច្ចការនេះបាន តែគាត់ជៀសមិនរួចពីជាប់គុកឡើយ។ រាល់ចម្លើយជនជាប់ចោទត្រូវកត់ត្រាចូលទៅក្នុងសាលក្រម ឬ សាលដីកា ដែលជាសេចក្តីសម្រេចរបស់តុលាការ។

ការប្រកាសទោសការងារសហគមន៍ ត្រូវកំណត់ពីថិរវេលា គឺមានចាប់ពី ៣០ (សាមសិប) ម៉ោង រហូតដល់ ២០០ (ពីររយ) ម៉ោង ហើយចៅក្រមត្រូវកំណត់អំឡុងពេលមិនឱ្យលើសពីមួយឆ្នាំ ការអនុវត្តទោសការងារសហគមន៍ គឺត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ព្រះរាជអាជ្ញា ហើយព្រះរាជអាជ្ញាជាអ្នកកំណត់អំពីបែបបទ

[79] មាត្រា១០៣ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែ វិច្ឆកា ឆ្នាំ ២០០៩ ស្តីអំពី "បែបបទនៃការអនុវត្តទោសកាងារសហគមន៍"។

នៃការអនុវត្តទោសការងារសហគមន៍នេះ ជាពិសេស ព្រះរាជអាជ្ញាគឺគាត់ចង្អុលនីតិបុគ្គលណាមួយដែលទទួលផលប្រយោជន៍ពីការងារសហគមន៍។

**ឃ. ការប្រកាសទោសការងារសហគមន៍ទៅលើរូបវន្តបុគ្គលជាអនីតិជន**

អនីតិជនដែលត្រូវទទួលបានការប្រកាសទោសការងារសហគមន៍ និងមិនត្រូវទទួលបានការប្រកាសមានៈ

- អនីតិជនដែលមានអាយុក្រោម ១៦ឆ្នាំ មិនត្រូវទទួលបានការប្រកាសទោសការងារសហគមន៍។
- អនីតិជនដែលមានអាយុយ៉ាងតិច ១៦ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ ត្រូវទទួលបានការប្រកាសទោសការងារសហគមន៍ ។

**ឃ.១. អនីតិជនដែលមានអាយុក្រោម ១៦ ឆ្នាំ**

អនីតិជនប្រភេទនេះ មិនត្រូវបានតុលាការប្រកាសពីទោសការងារសហគមន៍ទេ ចំពោះអាយុក្រោម ១៦ ឆ្នាំ មានន័យថា ចៅក្រមមិនអាចធ្វើការប្រកាសបានឡើយ ដូចជាការប្រកាសមូលទោស និងទោសបន្ថែម ចំពោះអនីតិជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ មិនត្រូវទទួលបានការប្រកាសដូចគ្នា។

**ឃ.២. អនីតិជនដែលមានអាយុយ៉ាងតិច ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ**

យោងតាមបញ្ញត្តិនៃក្រមព្រហ្មទណ្ឌមាត្រា១៦២ អនីតិជនដែលត្រូវបានប្រកាសទោសការងារសហគមន៍មានអាយុយ៉ាងតិច ១៦ (ដប់ប្រាំមួយ) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ[80]។ ហើយចំពោះថិរវេលាដែលអាចឱ្យអនីតិជននោះធ្វើការងារមិនឱ្យលើសពី ១០០ (មួយរយ) ម៉ោង ទេ។ បានន័យថា ថិរវេលានៃទោសការងារសហគមន៍ ចំពោះអនីតិជនដែលមានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ច្បាប់កំណត់ត្រឹមពាក់កណ្ដាលនៃថិរវេលារបស់នីតិជន ដូចនេះ ពាក់កណ្ដាលនៃ ២០០ (ពីររយ) ម៉ោង ស្មើនឹង ១០០ (មួយរយ) ម៉ោង។ មួយវិញទៀត គឺត្រូវជ្រើសរើសការងារមួយដែលសមស្របសម្រាប់អនីតិជននោះ ជាពិសេសគឺស្ថានភាពរបស់អនីតិជនដែលទាក់ទងនឹងការបណ្តុះបណ្តាល និងស្ថានភាពដែលអនុញ្ញាតឱ្យកែសម្រួលអនីតិជន កែប្រែអប់រំ អនីតិជននោះឱ្យចូលទៅរួមរស់នៅក្នុងសង្គមវិញ។ ហេតុដូចនេះលក្ខខណ្ឌទាក់ទងជាមួយទោសការងារសហគមន៍ ចំពោះអនីតិជនត្រូវធ្វើការងារនៅកន្លែងណាដែលមានលក្ខណៈជាបណ្តុះបណ្តាលដើម្បីឱ្យគាត់បានរៀនសូត្រ ដើម្បីឱ្យគាត់អប់រំកែប្រែខ្លួនឯង ដើម្បីចូលទៅរួមរស់នៅក្នុងសង្គមវិញ។

**គួរកត់សម្គាល់ ៖** ក្នុងច្បាប់ស្តីពីការងារ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ពាក់ព័ន្ធនឹង "ការងារសម្រាប់ក្មេង" មាត្រា១៧៧ បានកំណត់ត្រឹមអាយុ ១៥ (ដប់ប្រាំ) ឆ្នាំ ប៉ុណ្ណោះ គឺអនីតិជនអាចធ្វើការងារជាកម្មករនិយោជិតបានហើយ។ ព្រោះការងារនេះបានកម្រៃដើម្បីចិញ្ចឹមគ្រួសារ និងខ្លួនឯង ប៉ុន្តែការងារសហគមន៍គឺគ្មាន កម្រៃទេ។

[80] មាត្រា៧២ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែ វិច្ឆកា ឆ្នាំ ២០០៩ ស្តីអំពី "ទោសការងារសហគមន៍"។

### ២.៣.៣.២ ការប្រកាសទោសស្តីបន្ទោស

ទោសស្តីបន្ទោស គឺជាប្រភេទនៃទោសមួយដែលមានគោលបំណងបន្ធូរបន្ថយដល់ការទទួលទណ្ឌកម្ម ត្រឹមជាការស្តីបន្ទោសប៉ុណ្ណោះ ចំពោះទណ្ឌិតដែលបានប្រព្រឹត្តបទល្មើសដែលពុំមានលក្ខណៈធ្ងន់ធ្ងរ។ ទោសប្រភេទនេះក៏មិនខុសពីប្រភេទទោសដទៃទៀតផងដែរ គឺបង្កើតឡើងក្នុងគោលបំណងដាក់ទណ្ឌកម្មដល់ទណ្ឌិតឱ្យសមស្របទៅនឹងទម្ងន់នៃបទល្មើស។

**ក. លក្ខខណ្ឌនៃការប្រកាសទោសស្តីបន្ទោស**

ការប្រកាសទោសស្តីបន្ទោស អាចប្រព្រឹត្តទៅបានចំពោះជនជាប់ចោទដែលត្រូវរងទោសដាក់ពន្ធនាគារតិចជាង ឬ ស្មើនឹង ៣ (បី) ឆ្នាំ និងលក្ខខណ្ឌ ៣ ត្រូវបំពេញ៖

- ភាពចលាចលដល់សណ្តាប់ធ្នាប់សាធារណៈដែលបណ្តាលមកពីបទល្មើសបានបញ្ចប់
- ការខូចខាតត្រូវបានជួសជុលរួចហើយ និង
- ជនជាប់ចោទបានបង្ហាញការធានាក្នុងការចូលទៅរួមរស់នៅក្នុងសង្គមវិញ (មាត្រា ៧៦)។

ប្រសិនបើតុលាការសម្រេចប្រកាសទោសស្តីបន្ទោស តុលាការមិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬពិន័យជាប្រាក់បានទេ។

**ខ. ការប្រកាសទោសស្តីបន្ទោសចំពោះរូបវន្តបុគ្គលទាំងពីរប្រភេទ**

តាមរយៈទោសដែលអាចអនុវត្ត ចំពោះអនីតិជនមានចែងចាប់ពីមាត្រា១៦០ ដល់មាត្រា១៦៦ ឃើញមានតែមូលទោស ទោសបន្ថែម និងទោសជំនួស ក្នុងប្រភេទជាទោសការងារសហគមន៍ប៉ុណ្ណោះ ផ្ទុយទៅវិញមិនឃើញមានចែងអំពីទោសជំនួសក្នុងប្រភេទជាការស្តីបន្ទោស នៅក្នុងមាត្រាណាមួយនោះទេ សម្រាប់យកទៅអនុវត្តចំពោះអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំឡើងទៅដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ។ ប៉ុន្តែចម្ងល់នេះយើងអាចដោះស្រាយបាន ដោយលើកយកមាត្រា៧៦ ស្តីពី "របបគតិយុត្តនៃការស្តីបន្ទោស" ដើម្បីយកមកធ្វើជាទឡ្ហីករណ៍ផ្នែកគតិយុត្ត ឬ អំណះអំណាងតាមផ្លូវច្បាប់បាន។ បើយោងតាមស្មារតីនៃក្រមនេះអាចបញ្ជាក់ឱ្យឃើញថា ទាំងរូបវន្តបុគ្គលជានីតិជន ទាំងរូបវន្តបុគ្គលជាអនីតិជន មានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ គឺចៅក្រមអាចយកមាត្រា៧៦ មកប្រកាសបានដូចគ្នា ព្រោះមាត្រានេះជាបញ្ញត្តិទូទៅនៃទោសស្តីបន្ទោស ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ។ នៅទីនេះ គឺមិននិយាយពីអនីតិជនមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ ព្រោះបើយកមាត្រា ៣៩ កថាខណ្ឌទី ២ មកពិនិត្យមើលទៅឃើញថាអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅតុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌចំពោះគាត់បាន ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬ បុគ្គលិកលក្ខណៈរបស់អនីតិជននោះតម្រូវ។ ផ្ទុយទៅវិញ យើងអាចនិយាយបានថាអនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ មិនត្រូវរងទោសព្រហ្មទណ្ឌទេ រួមទាំងទោសស្តីបន្ទោស ឬ ទោសការងារ

សហាគមន៍ ក្នុងឋានៈជាទោសជំនួស ទោសបន្ថែម និង មូលទោស គឺចៅក្រម មិនអាចប្រកាសទោសលើគាត់ឡើយ ពីព្រោះបើគ្មានច្បាប់ចែងទេ អនីតិជនអាយុ ១៤ (ដប់បួន) ឆ្នាំ ក៏គ្មានទោសដែរ។

សរុបសេចក្តីមក ចំពោះរូបវន្តបុគ្គលទាំងពីរប្រភេទ គឺតុលាការអាចប្រកាសទោសចំពោះពួកគាត់បានដូចគ្នាប្រសិនបើលក្ខខណ្ឌនៃរបបគតិយុត្តពាក់ព័ន្ធនឹងការស្តីបន្ទោសត្រូវបានបំពេញ តាមមាត្រា៧៦ និងលើកលែងតែអនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំចេញតែប៉ុណ្ណោះទើបមិនប្រកាសទោសបាន។

# ជំពូកទី៣
# ទោសដែលអនុវត្តសម្រាប់នីតិបុគ្គល

# ជំពូកទី៣
# ទោសដែលអនុវត្តសម្រាប់នីតិបុគ្គល

នីតិបុគ្គលគឺជាក្រុមមនុស្សឬ មូលនិធិដែលមានបុគ្គលភាពគតិយុត្តហើយជាម្ចាស់នៃសិទ្ធិ និងកាតព្វកិច្ច[81]។ នីតិបុគ្គលសំដៅដល់អង្គការ ស្ថាប័នដែលបង្កើតឡើងដោយច្បាប់ ក្រុមហ៊ុន សមាគមន៍សហជីព រោងចក្រជាដើម ដែលទទួលស្គាល់ដោយច្បាប់ហើយជាបណ្តុំនៃរូបវន្តបុគ្គល។

នីតិបុគ្គលត្រូវបានបែងចែកជាពីរផ្សេងគ្នា និងមានទំនួលខុសត្រូវផ្សេងគ្នាដែលមាន នីតិបុគ្គលសាធារណៈ និងនីតិបុគ្គលដែលជានីតិបុគ្គលឯកជន។

ហើយជាគោលការណ៍ទោសដែលអនុវត្តសម្រាប់នីតិបុគ្គលគឺមានលក្ខណៈខុសគ្នាអំពីទោសដែលអនុវត្ត សម្រាប់រូបវន្តបុគ្គល។

ទោសដែលអនុវត្តសម្រាប់នីតិបុគ្គលមាន មូលទោសក្នុងប្រភេទជាទោសពិន័យ និងទោសបន្ថែមទាំង ១៤ ចំណុចដែលមានប្បញ្ញត្តិនៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា និងធ្វើឡើងតាមរយៈការប្រកាសទោស របស់ចៅក្រមដែលជាអ្នកប្រកាស[82]។

## ៣.១ មូលទោសក្នុងប្រភេទជាទោសពិន័យ

ដោយសារតែនីតិបុគ្គលមិនមែនជាមនុស្ស ដូច្នោះហើយចំពោះទណ្ឌកម្មដែលអនុវត្តចំពោះនីតិបុគ្គលក៏វា មានលក្ខណៈខុសគ្នាអំពីទោសដែលអនុវត្តសម្រាប់រូបវន្តបុគ្គលផងដែរ។

ចំពោះមូលទោសដែលអនុវត្តសម្រាប់នីតិបុគ្គលនៅទីនេះ គឺមានតែទោសពិន័យជាប្រាក់ និងទោស បន្ថែមទាំង ១៤ ចំណុចតែប៉ុណ្ណោះ ពីព្រោះថានីតិបុគ្គលគឺជាគ្រឹះស្ថាន ស្ថាប័នសាធារណៈ ឬ ឯកជនណាមួយ ហេតុដូច្នេះហើយគេមិនអាចចាប់នីតិបុគ្គលដែលជាគ្រឹះស្ថានស្ថាប័នដាក់ពន្ធនាគារបាននោះទេ។

ចំពោះទោសដែលអនុវត្តសម្រាប់នីតិបុគ្គលគឺយើងឃើញថាមានប្បញ្ញត្តិនៅក្នុងមាត្រា១៦៧ ដល់ មាត្រា១៨២ នៃក្រមព្រហ្មទណ្ឌ។ ហើយនៅក្នុងមាត្រា១៦៧ រហូតដល់មាត្រា១៨២ នៃក្រមព្រហ្មទណ្ឌនេះ យើងឃើញថាទោសពិន័យក្នុងឋានៈជាមូលទោសនេះយើងប្រើប្រាស់ដូចគ្នាជាមួយនឹងទោសពិន័យសម្រាប់ រូបវន្តបុគ្គល។

ហើយប្រសិនបើចំពោះការប្រកាសទោសទៅលើនីតិបុគ្គលគឺអនុវត្តដូចគ្នាទៅនិងរូបវន្តបុគ្គលចំពោះទោស ពិន័យ ដោយកម្រិតនៃទោសពិន័យនៅទីនេះ គឺគិតទៅលើចន្លោះពីអប្បបរមា និង អតិប្បបរមានៃទោសពិន័យ។

[81] មាត្រា៤ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយកថាខ័ណ្ឌទី៣ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១០។

[82] មាត្រា១៦៧ នៃក្រមព្រហ្មទណ្ឌចុះថ្ងៃទី៣០ ខែវិច្ឆកា ឆ្នាំ២០០៩។

មានន័យថាកាលណាតុលាការធ្វើការប្រកាសទោស គឺតុលាការអាចធ្វើការពិចារណាពីការពិន័យក្នុងចន្លោះកម្រិតទោសពីអប្បបរមា និងអតិប្បបរមាសមស្របណាមួយចំពោះបទល្មើសដែលមានបញ្ញត្តិ។

## ៣.២. ទោសបន្ថែមទាំង១៤ចំណុចកំណត់ដោយក្រមព្រហ្មទណ្ឌ

ទោសបន្ថែម ដែលត្រូវអនុវត្តចំពោះនីតិបុគ្គលគឺមានប្បញ្ញត្តិនៅក្នុងនៃក្រមព្រហ្មទណ្ឌ ដែលទោសបន្ថែមនៅក្នុងមាត្រានោះមាន១៤ ចំណុច[83]។

ទោសបន្ថែមទាំង ១៤ ចំណុចដែលអនុវត្តសម្រាប់នីតិបុគ្គលនៅទីនេះគឺមានលក្ខណៈខុសគ្នាមួយចំនួនរវាងទោសដែលអនុវត្តសម្រាប់រូបវន្តបុគ្គល។ ហើយដើម្បីដឹងថាទោសដែលអនុត្តន៍ចំពោះនីតិបុគ្គលបែបណាខ្លះនោះគឺយើងនិងធ្វើការបង្ហាញដូចខាងក្រោម។

យោងតាមប្បញ្ញត្តិមាត្រា១៦៨ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ទោសបន្ថែមដែលអនុវត្តសម្រាប់នីតិបុគ្គលមានដូចតទៅៈ

១- ការរំលាយចោល ។

២- ការដាក់ឲ្យនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ ។

៣- ការហាមឃាត់ចំពោះការអនុវត្តសកម្មភាពមួយ ឬ ច្រើន ។

៤- ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ ។

៥- ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈដល់ការសន្សំសំចៃ ។

៦- ការហាមឃាត់ចំពោះការចេញឧបករណ៍អាចជួញដូរ បាន ក្រៅពីឧបរណ៍អាចជួញដូរបាន ដែលកំណត់ដោយធនាគារ ។

៧- ការហាមឃាត់ចំពោះការប្រើប្រាស់ប័ណ្ណទូទាត់ ។

៨- ការបិទគ្រឹះស្ថានដែលប្រើសម្រាប់ធ្វើការរៀបចំ ឬ ប្រព្រឹត្តបទល្មើស

៩- ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានដែលបើកចំហដល់សារធារណៈជន ឬ ដែលបានប្រើប្រាស់ដោយសារធារណៈជន ។

១០-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុណាមួយដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅសម្រាប់ប្រព្រឹត្តល្មើស ។

១១-ការឹបអូសវត្ថុ ឬ មូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

១២-ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

[83] មាត្រា១៦៨ នៃក្រមព្រហ្មទណ្ឌ ចុះទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

១៣-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬ ចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសបានប្រព្រឹត្ត ។

១៤-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារពត៌មានសរសេរ ឬ ការផ្សាយតាមមធ្យោបាលទូរគមនាគមន៍សោតទស្សន៍។

- **ចំណុចទី១ ( ការរំលាយចោល )៖**

ដោយយោងទៅតាមប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (ការរំលាយ និងការជម្រះបញ្ជីនីតិបុគ្គល)៖

សេចក្តីសម្រេចដែលបង្គាប់ឲ្យរំលាយនីតិបុគ្គល នាំឲ្យមានការបញ្ជូននីតិបុគ្គលទៅតុលាការមានសមត្ថកិច្ចដើម្បីធ្វើការជម្រះបញ្ជី[84]។

ការរំលាយនីតិបុគ្គលចោលគឺជាសេចក្តីសម្រេចប្រកាសមួយដែលមានលក្ខណៈធ្ងន់ធ្ងរ ពីព្រោះថាក្រៅអំពីទោសពិន័យជាប្រាក់ហើយតុលាការអាចប្រកាសទោសរំលាយក្រុមហ៊ុន សមាគន៍ ឬ នីតិបុគ្គលណាមួយចោលដែលវាគឺជាប្រភេទនៃទោសមួយដែលមានលក្ខណៈធ្ងន់ធ្ងរសម្រាប់នីតិបុគ្គលដែលត្រូវទទួលរង។

- **ចំណុចទី២ ( ការដាក់ឱ្យនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ )៖**

ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ មិនអាចលើសពី៥ (ប្រាំ) ឆ្នាំទេ។ សេចក្តីសម្រេចដាក់ការត្រួតពិនិត្យតាមដានរបស់តុលាការនាំឲ្យមានការចាត់តាំងអាណត្តិគាហកតុលាការដែលតុលាការបញ្ជាក់បេសកកម្ម ។ ជារៀងរាល់ ៦ (ប្រាំមួយ) ខែ យ៉ាងតិចអាណត្តិគាហកតុលាការត្រូវធ្វើរបាយការណ៍ជូនព្រះរាជអាជ្ញាអំពីដំណើរការនៃបេសកកម្មរបស់ខ្លួន ។

ក្រោយពីបានឃើញរបាយការណ៍របស់អាណត្តិគាហកតុលាការ ព្រះរាជអាជ្ញាអាចប្ដឹងទៅតុលាការដែលបានប្រកាស ឲ្យធ្វើការដាក់ក្រោមការតាមដានរបស់តុលាការ ។ តុលាការអាចប្រកាសនូវទោសថ្មីមួយ។ តុលាការសម្រេចក្នុងពេលសវនាការជាសាធារណៈ ក្រោយពីបានស្តាប់យោបល់របស់តំណាង អយ្យការ អាណត្តិគាហកតុលាការ និងជាយថាហេតុ មេធាវីរបស់នីតិបុគ្គលនោះ[85]។

- **ចំណុចទី៣ ( ការហាមឃាត់ចំពោះការអនុវត្តសកម្មភាពមួយ ឬ ច្រើន )៖**

យោងតាមមាត្រា១៧២ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ការហាមឃាត់ចំពោះការធ្វើសកម្មភាព៖

ការហាមឃាត់ចំពោះការធ្វើសកម្មភាព អាចជាស្ថាពរ ឬ ជាបណ្តោះអាសន្នសម្រាប់ចិរវេលា ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

---

[84] មាត្រា១៧០ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

[85] មាត្រា១៧១ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

តុលាការបញ្ជាក់ពីសកម្មភាពដែលត្រូវហាមឃាត់[86]។

- **ចំណុចទី៤ ( ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ )៖**

ទោសបណ្តេញចេញពីលទ្ធកម្មសាធារណៈ នាំឱ្យមានការហាមឃាត់ចំពោះការចូលរួម ដោយផ្ទាល់ ឬ ដោយប្រយោលនៅក្នុងគ្រប់លទ្ធកម្មសាធារណៈដែលរៀបចំដោយ៖

១-រដ្ឋ។

២-រដ្ឋបាលថ្នាក់ក្រោមជាតិ។

៣-គ្រឹះស្ថានសាធារណៈ។

៤-សហគ្រាសដែលទទួលសម្បទានពីរដ្ឋ ឬ ពីរដ្ឋបាលថ្នាក់ក្រោមជាតិ ឬ ដែលត្រួតពិនិត្យដោយរដ្ឋ ឬ ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។

ទោសនេះអាចជាស្ថាពរ ឬ ជាបណ្តោះអាសន្ន សម្រាប់ថេរវេលាមួយមិនលើសពី ៥ ( ប្រាំ )ឆ្នាំ[87]។

- **ចំណុចទី៥ ( ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈដល់ការសន្សំសំចៃ )៖**

ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈឱ្យធ្វើការដាក់ប្រាក់សន្សំអាចជាស្ថាពរ ឬជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥ ( ប្រាំ ) ឆ្នាំយ៉ាងច្រើន។

ការហាមឃាត់នេះ នាំឱ្យមានការហាមឃាត់ដល់នីតិបុគ្គលចំពោះការអំពាវនាវដើម្បីឱ្យ ដាក់ឧបករណ៍អាចជួញដូរបានរបស់ខ្លួនទៅក្នុងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឬ ក្រុមហ៊ុនមូលបទានបត្រ។

ការហាមឃាត់នេះនាំឱ្យមានការហាមឃាត់ចំពោះការផ្សព្វផ្សាយជាសាធារណៈដែរ[88]។

- **ចំណុចទី៦ ( ការហាមឃាត់ចំពោះការចេញឧបករណ៍អាចជួញដូរកបាន ក្រៅពីឧបករណ៍អាចជួញដូរបានដែលកំណត់ដោយធនាគារ )៖**

ការហាមឃាត់ចំពោះការចេញឧបករណ៍អាចជួញដូរបាន អាចជាស្ថាពរ ឬ ជាបណ្តោះអាសន្នសម្រាប់រយៈពេល៥ ( ប្រាំ )ឆ្នាំយ៉ាងច្រើន[89]។

- **ចំណុចទី៧ ( ការហាមឃាត់ចំពោះការប្រើប្រាស់ប័ណ្ណទូទាត់ )៖**

ផ្អែកតាមមាត្រា១៧៥ នៃក្រមព្រហ្មទណ្ឌកថាខ័ណ្ឌទី ២ ចំពោះការហាមឃាត់ប្រើប្រាស់ប័ណ្ណទូទាត់ក៏ដូចគ្នាដែរ។

[86] មាត្រា១៧២ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។
[87] មាត្រា១៧៣ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។
[88] មាត្រា១៧៤ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។
[89] មាត្រា១៧៥ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

- **ចំណុចទី៨ ( ការបិទគ្រឹះស្ថានដែលប្រើសម្រាប់ធ្វើការរៀបចំ ឬ ប្រព្រឹត្តបទល្មើស )៖**

ទោសបិទគ្រឹះស្ថាននាំឱ្យមានការហាមឃាត់ចំពោះការប្រព្រឹត្តនៅក្នុងគ្រឹះស្ថាននេះ នូវសកម្មភាពដែលបទល្មើសបានកើតឡើងនៅក្នុងឱកាសដែលធ្វើសកម្មភាពនេះ[90]។

ទោសនេះអាចជាស្ថាពរ ឬ ជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥ (ប្រាំ)ឆ្នាំយ៉ាងច្រើន។

- **ចំណុចទី៩ ( ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានដែលបើកចំហដល់សាធារណៈជន ឬ ដែលបានប្រើប្រាស់ដោយសាធារណៈជន )៖**

ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានមួយ ដែលបើកចំហដល់សាធារណៈជន ឬ ដែលប្រើប្រាស់ដោយសាធារណជនអាចជាស្ថាពរ ឬ ជាបណ្តោះអាសន្នក្នុងរយៈពេល៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន[91]។

- **ចំណុចទី១០ ( ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុណាមួយដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅសម្រាប់ការប្រព្រឹត្តបទល្មើស)៖**

តាមបញ្ញត្តិនៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ការរឹបអូស និង សិទ្ធិតតិយជនៈ

កថាខ័ណ្ឌទី១ : ឧបករណ៍សម្ភារៈ ឬ វត្ថុអ្វីមួយដែលបានប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅសម្រាប់ការប្រព្រឹត្តបទល្មើស[92]។

កថាខ័ណ្ឌទី៤ : ឧបភោគភណ្ឌ សម្ភារៈ និងចលវត្ថុនៅទីកន្លែងដែលបទល្មើសបានកើត ក៏ប៉ុន្តែការរឹបអូសមិនអាចត្រូវបានប្រកាសបានទេ ប្រសិនបើការរឹបអូសនោះប៉ះពាល់ដល់សិទ្ធិរបស់តតិយជន។

- **ចំណុចទី១១ ( ការរឹបអូសវត្ថុ ឬ មូលនិធិដែលជាកម្មនៃបទល្មើស )៖**

កថាខ័ណ្ឌទី២ : វត្ថុ ឬ មូលនិធិដែលជាកម្មវត្ថុនៃបទល្មើស។

យោងតាមប្បញ្ញត្តិមាត្រា១៧៩ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ការរឹបអូស និង សិទ្ធិតតិយជនៈ

- **ចំណុចទី១២ ( ការរឹបអូស ផលទុនឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស )៖**

មាត្រា១៧៩ នៃក្រមព្រហ្មទណ្ឌ កថាខ័ណ្ឌទី៣ : ផលទុនឬទ្រព្យសម្បត្តិ ដែលជាផលកើតចេញពីបទល្មើស។

[90] មាត្រា១៧៦ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។
[91] មាត្រា១៧៧ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។
[92] មាត្រា១៧៩ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

- **ចំណុចទី១៣ ( ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬ ចលនាវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសបានប្រព្រឹត្ត )៖**

មាត្រា១៧៩ នៃក្រមព្រហ្មទណ្ឌដដែលកថាខ័ណ្ឌទី៤ : ឧបភោគភណ្ឌ សម្ភារៈ និងចលនវត្ថុនៅទីកន្លែងដែលបទល្មើសបានកើត ក៏ប៉ុន្តែការរឹបអូសមិនអាចត្រូវបានប្រកាសបានទេ ប្រសិនបើការរឹបអូសនោះប៉ះពាល់ដល់សិទ្ធិរបស់តតិយជន។

- **ចំណុចទី១៤ (ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស ការផ្សាយសេចក្តីសម្រេចផ្តន្ទាសនៅក្នុងសារពត៌មានសរសេរ ឬ ការផ្សាយតាមសមធ្យោបាយទូរគមនាគមន៍សោតទស្សន៍)៖**

ការបិទផ្សាយសេចក្តីសម្រេច ត្រូវអនុវត្តនៅទីកន្លែងដែលចង្អុលប្រាប់ដោយតុលាការ និងសម្រាប់រយៈពេលមួយដែលកំណត់ឡើងដោយតុលាការ ។ ការបិទផ្សាយមិនអាចលើសពី ២ (ខែ) ។ ការបិទផ្សាយអាចទាំងស្រុងតាមសម្រង់ ឬ តាមនិទ្ទេសធម្មតា ។ សោហ៊ុយនៃការបិទផ្សាយជាបន្ទុករបស់នីតិបុគ្គលដែលត្រូវផ្តន្ទាទោស ។

ក្នុងករណីដែលដកបំបាត់ចេញ លាក់កំបាំង ឬ ហែកចោលសេចក្តីប្រកាសបិទផ្សាយនោះ ត្រូវធ្វើការបិទផ្សាយជាថ្មីម្តងទៀត ។ សោហ៊ុយនៃការបិទផ្សាយនេះ ត្រូវចេញដោយជនល្មើសដែលជាអ្នកដកបំបាត់ចោល លាក់កំបាំង ឬ ហែកចោល [93]។

តាមក្រមព្រហ្មទណ្ឌបានចែងថា ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយ ទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍ :

ទោសផ្សាយសេចក្តីសម្រេច តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ត្រូវអនុវត្តតាមបែបបទដែលកំណត់ឡើងដោយតុលាការ ។ ការផ្សាយនេះ មិនអាចលើសពីរ ៨ (ប្រាំបី) ថ្ងៃ ។ ការផ្សាយនេះ អាចផ្សាយទាំងស្រុងតាមសម្រង់ ឬ តាមនិទ្ទេស ។សោហ៊ុយការផ្សាយនេះជាបន្ទុករបស់នីតិបុគ្គលដែលត្រូវផ្តន្ទាទោស ។

ទោសផ្សព្វផ្សាយសេចក្តីសម្រេចរបស់តុលាការត្រូវចុះផ្សាយក្នុងសារពត៌មាន មិនអាចបដិសេធការចុះផ្សាយនេះបានទេ ។

ទោសផ្សព្វផ្សាយសេចក្តីសម្រេចរបស់តុលាការត្រូវចុះផ្សាយក្នុងសារពត៌មានសរសេរតាមបែបបទនិងថិរវេលាដែលកំណត់ដោយតុលារ ។ សោហ៊ុយក្នុងការចុះផ្សាយជាបន្ទុករបស់នីតិបុគ្គល ។ បើតុលាការបានបង្គាប់ការផ្សព្វផ្សាយសេចក្តីសម្រេច សារពត៌មានមិនអាចបដិសេធការចុះផ្សាយនេះបានទេ[94]។

---

93 មាត្រា១៨០ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

94 មាត្រា១៨១ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

## ៣.៣. ការប្រកាសទោសព្រហ្មទណ្ឌ ចំពោះទោសនីមួយៗនៅលើនីតិបុគ្គល

យើងដឹងហើយថានីតិបុគ្គលគឺជាក្រុមមនុស្ស ឬ មូលនិធិ ដែលមានបុគ្គលភាពគតិយុត្ត ដែលបង្កើតឡើងដោយច្បាប់ និងជាប្រធាននៃសិទ្ធ និងកាតព្វកិច្ច ។ ហើយនីតិបុគ្គលនេះទៀតសោតត្រូវបានបែងចែកជាពីរ គឺ នីតិបុគ្គលនៃនីតិសាធារណៈ (នីតិបុគ្គលដែលជារដ្ឋ) និង នីតិបុគ្គលដែលជានីតិឯកជន (នីតិបុគ្គលមិនមែនជារដ្ឋ)ដែលយើងនឹងធ្វើការបកស្រាយដូចខាងក្រោម ៖

### ៣.៣.១. នីតិបុគ្គលនៃនីតិសាធារណៈ ឬ នីតិបុគ្គលដែលជារដ្ឋ

នីតិបុគ្គលនៃនីតិសាធារណៈ (នីតិបុគ្គលដែលជារដ្ឋ) គឺជាក្រុមមនុស្សដែលច្បាប់បានអនុញ្ញាតឲ្យធ្វើសកម្មភាពដូចជាបុគ្គល ដើម្បីជាផលប្រយោជន៍សាធារណៈនិងគ្មានគោលបំណងដើម្បីទទួលបានប្រាក់ចំណេញដែលវាមានលក្ខណៈខុសគ្នាអំពីនីតិបុគ្គលដែលជានីតិបុគ្គលឯកជន ។ នីតិបុគ្គលសាធារណៈ គឺជាស្ថាប័នដែលត្រូវបានបង្កើតឡើងដោយច្បាប់ និងត្រូវគ្រប់គ្រងដោយច្បាប់សាធារណៈ ហើយមានសិទ្ធ អំណាចក្នុងការគ្រប់គ្រងកិច្ចការរដ្ឋបាល[95]។

នីតិបុគ្គលនៃនីតិសាធារណៈនៅទីនេះគឺ សំដៅដល់រដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ (រាជធានី ខេត្តក្រុង ស្រុក ខ័ណ្ឌ ឃុំ សង្កាត់) និងគ្រឹះស្ថានសាធារណៈដែលមានលក្ខណៈរដ្ឋបាល និងឧស្សាហកម្ម ពាណិជ្ជកម្ម ។ ចំពោះការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គលវិញយើងឃើញថា ដោយយោងទៅតាមបញ្ញត្តិ មាត្រា ៤២ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដែលបញ្ញត្តិអំពី ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិ បុគ្គលបានចែងថា នៅក្នុងករណីដែលមានចែងជាក់លាក់នៅក្នុងច្បាប់ និងបទដ្ឋានគតិយុត្តិផ្សេងទៀត នីតិ បុគ្គលលើកលែងតែរដ្ឋចេញអាចត្រូវបានប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌពីបទល្មើសដែលប្រព្រឹត្ត ដោយអង្គការ ឬ អ្នកដំណាងរបស់ខ្លួនដើម្បីជាប្រយោជន៍របស់នីតិបុគ្គលនោះ ។

ដោយយោងទៅតាមបញ្ញត្តិមាត្រានេះយើឃើញថា រដ្ឋដែលជានីតិបុគ្គលនៃនីតិសាធារណៈគឺមិនតម្រូវឲ្យមាននូវការទទួលខុសត្រូវព្រហ្មទណ្ឌណាមួយទេ ហើយក៏មិនត្រូវទទួលនូវទោសព្រហ្មទណ្ឌដែរ ។

**តើមានមូលហេតុអ្វីខ្លះបានជារដ្ឋមិនទទួលខុសត្រូវព្រហ្មទណ្ឌ ឬ ទោសព្រហ្មទណ្ឌ?**

ដើម្បីដឹងថាហេតុអ្វីបានជារដ្ឋមិនទទួលខុសត្រូវព្រហ្មទណ្ឌ ឬ ទោសព្រហ្មទណ្ឌនោះ ដំបូងយើងត្រូវស្វែងយល់នូវពាក្យថារដ្ឋជាមុនសិន ។ រដ្ឋគឺជានគរ ឬ បុរី ឬ ប្រទេសមួយ ហេតុនេះហើយក្រមព្រហ្មទណ្ឌគឺមិនអាចចែងដើម្បីរំលាយ រដ្ឋ ឬ នគរ ឬ បុរី ឬ ប្រទេសមួយបានឡើយ ដោយសារតែរដ្ឋជាអ្នកគ្រប់គ្រងសង្គម ដូច្នេះ រដ្ឋត្រូវតែបង្កើតច្បាប់ដើម្បីដាក់ទោសទៅលើសមាជិកសង្គមណាដែលបានប្រព្រឹត្តបទល្មើស ។ អាស្រ័យហេតុ នេះប្រសិនបើរដ្ឋត្រូវមានទោស ឬ ទទួលខុសត្រូវព្រហ្មទណ្ឌ មានន័យថារដ្ឋបង្កើតច្បាប់ព្រហ្មទណ្ឌ

[95] យោងតាមសន្ទានុក្រមនៃច្បាប់ស្តីអំពីការគ្រប់គ្រងរដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ។

ដើម្បីដាក់ទោស រដ្ឋខ្លួនឯងហើយ ដែលវាគឺជារឿងមួយដែលមិនអាចធ្វើទៅបាន ហើយវានិងបណ្តាលឲ្យប៉ះពាល់ដល់អធិប្បតេយ្យរបស់ជាតិ[96]។

ដូចនេះនីតិបុគ្គលដែលជារដ្ឋមិនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌណាមួយឡើយ លើកលែងតែបទល្មើសចំនួន ៤ ដែលស្ថិតក្នុងសមត្ថកិច្ចរបស់យុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) ដែលជាបទល្មើសធ្ងន់ធ្ងរនិងមិនអាចលើកលែងបាន រវាងរដ្ឋ និងប្រជាពលរដ្ឋ ដែលកើតមាននៅក្នុងប្រទេសមួយប៉ុណ្ណោះ។

បទល្មើសទាំង ៤ នោះមានដូចជា៖

១. បទឧក្រិដ្ឋប្រល័យពូជសាសន៍

២.បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ

៣.បទឧក្រិដ្ឋសង្គ្រាម និង

៤. បទឧក្រិដ្ឋកម្មឈ្លានពាន ។

ដែលបទល្មើសទាំង ៤ នេះគឺជាប្រភេទនៃបទល្មើសដែលមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរនិងមិនអាចលើកលែងឲ្យបាន ។

មួយវិញទៀតដោយយោងទៅតាមបញ្ញត្តិ (មាត្រា១៧០)នៃក្រមព្រហ្មទណ្ឌដដែលនេះ ចំពោះទោសបន្ថែមដែលអនុវត្តទៅលើនីតិបុគ្គល គឺចែងអំពីការរំលាយនីតិបុគ្គលនោះចោល ដែលនីតិបុគ្គលនៅទីនេះគឺសំដៅ ដល់នីតិបុគ្គលដែលមិនមែនជារដ្ឋតែប៉ុណ្ណោះ ពីព្រោះថាប្រសិនបើមានការអនុញ្ញាតឲ្យរំលាយនីតិបុគ្គលដែលជារដ្ឋ ឧទាហរណ៍ដូចជាប្រទេសកម្ពុជាយើង ប្រសិនបើមានការអនុញ្ញារឲ្យរំលាយប្រទេសចោលបាននោះគឺវា និងមានផលប៉ះពាល់ទៅដល់អធិប្បតេយ្យជាតិរបស់ព្រះរាជាណាចក្រកម្ពុជាហើយ ដូច្នេះក្រមព្រហ្មទណ្ឌថ្មីនេះ និងអធម្មនុញ្ញភាព។ ចំពោះនីតិបុគ្គលដែលមិនមែនជារដ្ឋវិញចំពោះទោសបន្ថែមនៅក្នុងការរំលាយនីតិបុគ្គលនេះ អាចធ្វើទៅបានតាមសេចក្តីសម្រេចរបស់តុលាការ តាមរយៈការបញ្ជូននីតិបុគ្គលនោះទៅតុលាការមានសមត្ថកិច្ចដើម្បីធ្វើការជម្រះបញ្ជី ក្នុងន័យនីតិបុគ្គលមិនមែនជារដ្ឋ (ជាអង្គការ ឬសមាគមន៍)។

### ៣.៣.២. នីតិបុគ្គលដែលជានីតិឯកជន ឬ នីតិបុគ្គលដែលមិនមែនជារដ្ឋ

នីតិបុគ្គលឯកជនគឺជាក្រុមមនុស្ស ឬ មូលនិធិ ដែលមានបុគ្គលភាពគតិយុត្តិ ហើយជាប្រធាននៃសិទ្ធិនិងកាតព្វកិច្ច និងស្ថិតក្រោមវិធានទាំងឡាយណាដែលគ្រប់គ្រងទំនាក់ទំនងគតិយុត្តរវាង បុគ្គលឯកជន និងបុគ្គលឯកជន និងមិនស្ថិតនៅក្រោមនីតិសាធារណៈទេ ។ នីតិបុគ្គលឯកជនមានដូចជា អង្គការ ក្រុមហ៊ុនសមាគមន៍ សហជីព រោងចក្រ.ល. ។ ដែលជាប្រធាននៃបទល្មើសនៅក្នុងសង្គមបច្ចុប្បន្ន និងត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ឬ ទទួលទោសព្រហ្មទណ្ឌចំពោះទង្វើដែលបានប្រព្រឹត្ត ។

[96] មាត្រា១ ដល់មាត្រា៦ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។

ហើយចំពោះការប្រកាសទោសព្រហ្មទណ្ឌទៅលើនីតិបុគ្គលនេះវិញជាគោលការណ៍ គឺធ្វើឡើងតាមរយៈចៅក្រមដែលជាអ្នកមានសិទ្ធិនៅក្នុងការប្រកាសទោស ដែលជាកាតព្វកិច្ចនិងកំណត់ដោយតុលាការ ។ តើនីតិបុគ្គលដែលជានីតិឯកជន ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌបែបណា?

ដើម្បីដឹងថានីតិបុគ្គលដែលជានីតិបុគ្គលឯកជនទទួលខុសត្រូវព្រហ្មទណ្ឌបែបណានោះគឺយើងនិងធ្វើការបកស្រាយដូខាងក្រោមៈ

ចំពោះទោសដែលត្រូវបានយកទៅអនុវត្តចំពោះនីតិបុគ្គលតែមានតែពីរប្រភេទប៉ុណ្ណោះគឺ ទោសពិន័យជាប្រាក់ក្នុងឋានៈជាមូលទោស និង ទោសបន្ថែមទាំង ១៤ ចំណុច។ ហើយចំពោះទោសជំនួសវិញគឺមិនត្រូវបាន យកមកអនុវត្តចំពោះនីតិបុគ្គលនោះទេ ព្រោះថានីតិបុគ្គលគឺជាមនុស្សអរូបិយ៍ (គ្មានរូបរាងពិតប្រាកដ) ដូច្នេះហើយមិនអាចយកទោសជំនួសដែលជាប្រភេទនៃទោសបែបជាទោសកាងារសហគមន៍ ឬ ទោសស្ដីបន្ទោស យកទៅអនុវត្តចំពោះ នីតិបុគ្គលដែលអរូបិយ៍បានឡើយ ព្រោះថានីតិបុគ្គលគឺអរូបិយ៍គ្មានរូបរាង ដូច្នេះហើយយើងមិនអាចយកទោសប្រភេទនេះទៅអនុវត្តចំពោះនីតិបុគ្គលបានទេ ។

### ៣.៣.៣. ទោសពិន័យជាប្រាក់ក្នុងឋានៈជាមូលទោស

ទោសពិន័យជាប្រាក់ក្នុងឋានៈជាមូលទោស គឺជាទោសមួយប្រភេទដែលត្រូវបានយកទៅអនុវត្តចំពោះនីតិបុគ្គល ដែលជាទោសពិន័យជាប្រាក់ និងកំណត់ជាមូលទោសដោយគ្មានទោសដាក់ពន្ធនាគារទៀតនោះទេ ព្រោះថានីតិបុគ្គលគឺមានលក្ខណៈខុសពីរូបវន្តបុគ្គលដែលជាបុគ្គលមានសាច់ មានឈាម មានជីវិត ។ ហេតុនេះហើយការដែលចាប់នីតិបុគ្គលដែលជាក្រុមហ៊ុន គ្រឹះស្ថាន សហគ្រាស រោងចក្រដែលមានលក្ខណៈជា (អរូបិយ) ដាក់ពន្ធនាគារគឺមិនអាចធ្វើបាននោះទេ ។

ហើយចំពោះទោសដែលអាចយកទៅអនុវត្តចំពោះនីតិបុគ្គលបានទៀតនោះគឺមានទោសមួយប្រភេទទៀត គឺទោសបន្ថែមទាំង ១៤ ចំណុច ។

### ៣.៣.៤. ទោសបន្ថែមទាំង ១៤ ចំណុច

ចំពោះទោសបន្ថែមនៅទីនេះ គឺជាប្រភេទនៃទោសមួយប្រភេទទៀតដែលបន្ថែមទៅលើមូលទោសដែលមានន័យថាក្រៅពីមូលទោសក្នុងប្រភេទជាទោសពិន័យជាប្រាក់ហើយតុលាការអាចប្រកាសទោសបន្ថែមទៅលើនីតិបុគ្គលបានផងដែរ ហើយការប្រកាសទោសបន្ថែមនេះត្រូវបានក្រមព្រហ្មទណ្ឌចងជាកាតព្វកិច្ចចំពោះចៅក្រម ឬចាប់បង្ខំឲ្យចៅក្រមត្រូវតែប្រកាសទោសបន្ថែមទៅលើនីតិបុគ្គល មានន័យថាទោសបន្ថែមនៅទីនេះវាមិនមែនជាជម្រើសរបស់ចៅក្រមនៅក្នុងការសម្រេចថាប្រកាស ឬមិនប្រកាសឡើយ ដែលវាមានលក្ខណៈខុសពីទោសបន្ថែមសម្រាប់រូបវន្តបុគ្គល។ ដូចនេះនៅពេលដែលតុលាការសម្រេចផ្តន្ទាទោសជាប្រាក់ក្នុងឋានៈ

ជាមូលទោសចំពោះនីតិបុគ្គលណាមួយហើយ តុលាការមានកាតព្វកិច្ចត្រូវតែប្រកាសនូវទោសបន្ថែមជាដាច់ខាតទៅលើនីតិបុគ្គលណាមួយនោះ ។

**ឧទាហរណ៍៖** មាត្រា៣៣៦ នៃក្រមព្រហ្មទណ្ឌដដែលនេះដែលនិយាយអំពី ការអនុវត្តទោសចំពោះនីតិបុគ្គលដែលមានខ្លឹមសាថា នីតិបុគ្គលអាចនឹងត្រូវបានប្រកាសថាទទួលខុសត្រូវព្រហ្មទណ្ឌទៅតាមលក្ខណ្ឌដែលមានចែងនៅក្នុងមាត្រា៤២ នៃក្រមព្រហ្មទណ្ឌ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមនេះ ចំពោះបទល្មើសដែលមានចែងនៅក្នុងមាត្រា៣៣០ (បទញុះញង់អោយបោះបង់ទារក ) មាត្រា៣៣១ ( បទ អន្តរកាលរវាងអ្នកសុំកូននិងអ្នកបោះបង់កូន) មាត្រា៣៣២នៃក្រមព្រហ្មទណ្ឌ (បទអន្តរកាលរវាងអ្នកសុំកូន និងស្ត្រីពរពោះ) នៃក្រមនេះ។ នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀលទៅ ៥.០០០.០០០ (ប្រាំលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬ ច្រើន។ ចំពោះទោសបន្ថែមដែលត្រូវយកទៅ អនុវត្តចំពោះនីតិបុគ្គល ជាកាតព្វកិច្ចដែលបានចងចៅក្រមឲ្យត្រូវតែប្រកាសជាមួយមូលទោសក្នុងប្រភេទជាទោសពិន័យតែម្តង។

ជារួមមកចំពោះទោសដែលអនុវត្តទាក់ទងទៅនិងនីតិបុគ្គលគឺមានចែងយ៉ាងពិសេសចាប់ពីមាត្រា១៦៧ ទៅដល់មាត្រា១៨២ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩នេះ ។ប៉ុន្តែអ្វីដែលមិនបានចែងចាប់ពីមាត្រ១៦៧ ដល់មាត្រា១៨១ នៃក្រមព្រហ្មទណ្ឌនេះ គឺត្រូវបានបកស្រាយជូនហើយអំពីបទបញ្ញត្តទូទៅដែលអនុវត្តសម្រាប់រូបវន្តបុគ្គល។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

សរុបមក ប្រភេទនៃទោសព្រហ្មទណ្ឌដែលកំណត់ដោយក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩ បានកំណត់ទោសជា ៣ (បី) ប្រភេទរួមមាន មូលទោស ទោសបន្ថែម និងទោសជំនួស ដែលប្រភេទនៃទោសទាំងបីនេះ តុលាការបានយកទៅអនុវត្តចំពោះបុគ្គលបានប្រព្រឹត្តបទល្មើស ដែលបង្កគ្រោះថ្នាក់ដល់សង្គម ឬ សមាជិកសង្គម។ ដោយគោរពទៅតាមគោលការណ៍នីត្យានុកូលភាពនៃបទល្មើស និងនៃទោសកំណត់ដោយ មាត្រា៣ នៃក្រមព្រហ្មទណ្ឌ។ ទោសដែលអនុវត្តចំពោះរូបវន្តបុគ្គល តាមបញ្ញត្តិនៃក្រមព្រហ្មទណ្ឌ ប្រភេទនៃទោសនេះមាន មូលទោស ទោសបន្ថែម និងទោសជំនួស។ ចំណែកឯទោសដែលអនុវត្តចំពោះនីតិបុគ្គល ប្រភេទនៃទោសនេះមានទោសពិន័យក្នុង ឋានៈជាមូលទោស កំណត់ដោយមាត្រា១៦៧ នៃក្រមព្រហ្មទណ្ឌ និងទោសបន្ថែមទាំង ១៤ ចំណុច កណត់ដោយមាត្រា១៦៨ នៃក្រមព្រហ្មទណ្ឌ។ ចំពោះនីតិបុគ្គល មាននីតិបុគ្គលជារដ្ឋ និងនីតិបុគ្គលឯកជន។ មាត្រា៤៣ នៃក្រមព្រហ្មទណ្ឌ បានកំណត់ពីមូលទោស មានទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់។ មាត្រា៥៣ នៃក្រមព្រហ្មទណ្ឌ បានកំណត់ពីប្រភេទទោសបន្ថែមមានកំណត់ ១៩ ចំណុច ។ ទោសជំនួសមានទោសការងារសហគមន៍កំណត់ដោយមាត្រា៧២ នៃក្រមព្រហ្មទណ្ឌ និងទោសស្តីបន្ទោសកំណត់ដោយមាត្រា៧៦ នៃក្រមព្រហ្មទណ្ឌ ។ ជាទូទៅ មូលទោសត្រូវបានកំណត់ពីអប្បបរមា និងអតិបរមា ដែលជាទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ ហើយច្បាប់ក៏បានកំណត់ពីស្ថានទម្ងន់ទោស និងស្ថានសម្រាលទោសផងដែរ។ យ៉ាងណាមិញ ចំពោះអំពើដែលត្រូវទទួលបាននូវស្ថានទម្ងន់ទោស អាស្រ័យទៅលើច្បាប់បានកំណត់អំពី(ចរិតគ្រោះថ្នាក់នៃអំពើរបស់ជនល្មើស និងការមិនរាងចាល)។ ចំណែកឯស្ថានសម្រាលទោសវិញ ច្បាប់បានកំណត់អំពី ខ្នាតនៃស្ថានសម្រាលចំពោះរូបវន្តបុគ្គល(ជានីតិជន និងអនីតិជន)។ ច្បាប់ក៏បានកំណត់ពីការប្រកាសទោសព្រហ្មទណ្ឌផងដែរ ជាទូទៅការប្រកាសទោស គឺប្រកាសចំពោះ មូលទោស ទោសបន្ថែម និងទោសជំនួស ។ ការប្រកាសមូលទោសរួមមាន ទោសដាក់ពន្ធនាគារ ទោសពិន័យជាប្រាក់ និងទាំងទោសដាក់ពន្ធនាគារនិងពិន័យជាប្រាក់ ជាមួយគ្នា។ ការប្រកាសទោសបន្ថែម គឺការប្រកាសទោសបន្ថែមទៅលើមូលទោស និងការប្រកាសទោសបន្ថែមជំនួសមូលទោស ។ ការប្រកាសទោសជំនួស គឺប្រកាសចំពោះទោសការងារសហគមន៍ និងការប្រកាសទោសស្តីបន្ទោស ។ ការប្រកាសទោសត្រូវគោរពទៅតាមលក្ខខណ្ឌច្បាប់បានកំណត់ ។

យោងតាមការបកស្រាយប្រធានបទខាងលើនេះឃើញថា ប្រភេទនៃទោសក្នុងក្រមព្រហ្មទណ្ឌ គឺបានចង្អុលបង្ហាញពី ការកំណត់នូវកម្រិតក្នុងការផ្តន្ទាទោសទៅតាមស្ថានភាពនៃបទល្មើសដែលមានចែងតាមប្រភេទនៃបទល្មើសហើយនឹងត្រូវផ្តន្ទាទោសតាមប្រភេទនៃទោសដូចជា មូលទោស ទោសបន្ថែម និងទោសជំនួស។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីបានឆ្លងកាត់តាមរយៈការសិក្សាស្រាវជ្រាវទាក់ទងទៅនឹងប្រធានបទ **ប្រភេទនៃបទល្មើសព្រហ្មទណ្ឌ** រួចជាស្ថាពរមក យើងខ្ញុំបានពិនិត្យឃើញថា ប្រធានបទមួយនេះពិតជាមានសារៈសំខាន់ខ្លាំងណាស់ ក្នុងការចូលរួមស្វែងរកយុត្តិធម៌ជូនជនដែលរងគ្រោះពិតប្រាកដ ហើយជាពិសេសនោះ គឺបានជួយថែរក្សាសន្តិសុខសុវត្ថិភាពទូទាំងប្រទេសផងដែរ។ តាមការសិក្សាស្រាវជ្រាវទាក់ទងទៅនិងប្រធានបទ ប្រភេទទោសតាមក្រមព្រហ្មទណ្ឌ រួចមកយើងសង្កេតឃើញថា ទោសព្រហ្មទណ្ឌត្រូវបានបញ្ញាត្តិបានយ៉ាងតឹងរឹង ដោយយោងតាមក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩។ ជាក់ស្តែងនោះ ទោសព្រហ្មទណ្ឌបានផ្តន្ទាទោសទៅលើគ្រប់បុគ្គល ដែលជាសមាជិករបស់សង្គម ដែល បានប្រព្រឹត្តផ្ទុយនឹងច្បាប់។ ទោសព្រហ្មទណ្ឌ ត្រូវបានផ្តន្ទាទោសមិនថាតែរូបវន្តបុគ្គល ឬ នីតិបុគ្គលឡើយ ហើយ រាល់នីតិបុគ្គលដែលបានប្រព្រឹត្តបទល្មើសដែលបង្កភាពចលាចដល់សង្គមជាតិ។ ដោយឡែក ប្រសិនបើយើងក្រឡេកមើលទៅលើសង្គមមួយដែលមានការរីកចម្រើនលូតលាស់យ៉ាង ឆាប់រហ័ស ក៏ដោយសារតែសង្គមនោះមាននូវការប្បញ្ញត្តិច្បាប់បានយ៉ាងតឹងរឹង ការគោរពប្រត្តិបត្តិ និងអនុវត្តបាន យ៉ាងខ្ជាប់ខ្ជួនទៅតាមច្បាប់ដែលបានចែងជាធរមាន។ ដើម្បីឱ្យការអនុវត្តច្បាប់ប្រកបទៅដោយភាពជោគជ័យ ចាំបាច់ត្រូវមានការចូលរួមពីសំណាក់មន្ត្រីដែល មានការពាក់ព័ន្ធ ក៏ដូចជាប្រជាជនផងដែរ។ ជាពិសេស មន្ត្រីសាធារណៈ ត្រូវធ្វើយ៉ាងណាឱ្យប្រជាជនយល់ដឹង អំពីច្បាប់ជាការចាំបាច់ យើងត្រូវប្រើប្រាស់នៅវិធានការដូចជា៖

**ការផ្សព្វផ្សាយ៖** យើងបានដឹងស្រាប់ហើយថា ក្រោយការប្រកាសឱ្យប្រើនូវក្រមព្រហ្មទណ្ឌថ្មីនេះ គឺ ក្រសួងយុត្តិធម៌ បានសហការជាមួយនឹងក្រសួងព័ត៌មានក្នុងការផ្សព្វផ្សាយនូវច្បាប់ថ្មីនេះ តាមរយៈមធ្យោបាយ ទូរគមនាគម៍ផ្សេងៗ ដើម្បីឱ្យអ្នកអនុវត្តច្បាប់ទាំងឡាយ រួមទាំងពលរដ្ឋមានការយល់ដឹងឱ្យបានកាន់តែច្រើនអំពី បញ្ហាផ្លូវច្បាប់។ ប៉ុន្តែ ការផ្សព្វផ្សាយបែបនេះនៅមានភាពខ្វះចន្លោះ ព្រោះថាបើសិនអាជ្ញាធរបានបង្កើតក្រុមការងារចុះធ្វើការផ្សព្វផ្សាយផ្ទាល់ជាមួយពលរដ្ឋក្នុងមូលដ្ឋាន នោះច្បាប់ដែលបានប្រកាសឱ្យប្រើនេះគឺកាន់តែមានប្រសិទ្ធិភាពក្នុងការអនុវត្ត ហើយប្រជាពលរដ្ឋក៏យល់ដឹងច្រើនអំពីបញ្ហាផ្លូវច្បាប់ដែរ។

**ការចូលរួម៖** ការចូលរួមក្នុងន័យនេះ គឺចង់សំដៅដល់ការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងការចូលរួមតាមដានសម្តែងជាមតិទាំងឡាយណាដែលខ្លួនយល់ឃើញថាគួរ ឬ មិនគួរនៅពេលដែលសភាធ្វើការអនុម័តនូវអត្ថបទច្បាប់ណាមួយ។

**ការបណ្តុះបណ្តាល៖** ការបណ្តុះបណ្តាលនេះ គឺពិតជាមានសារៈសំខាន់ណាស់សម្រាប់ប្រទេជាតិ នានានូវទូទាំងសកលលោក ព្រោះថាបើច្បាប់ចែងមកល្អហើយ តែមន្ត្រីអនុវត្តមិនបានល្អនោះប្រាកដណាស់ ថា និងធ្វើឱ្យរាស្ត្ររងទុក្ខជាក់ជាមិនខាន។ ដូច្នេះ គុណភាពមន្ត្រី គឺត្រូវតែមានសមត្ថភាព និងចំណេះជំនាញពិត

ប្រាកដទើបអាចធ្វើឱ្យសង្គមជាតិមានភាពរីកចម្រើនបាន។ ជាចុងក្រោយ សូមឱ្យនិស្សិតជំនាន់ក្រោយៗ និងបងប្អូនប្រជាពលរដ្ឋគ្រប់រូប ខិតខំនិងព្យាយាមសិក្សា ស្វែងយល់អំពីច្បាប់ព្រហ្មទណ្ឌដើម្បីជាពុទ្ធិក្នុងការរស់នៅដោយតាមរយៈការស្តាប់ ការអាន ការឆ្លល់រួចសួរទៅ កាន់អ្នកជំនាញច្បាប់ និងចូលរួមអនុវត្តច្បាប់ព្រហ្មទណ្ឌឱ្យខ្ជាប់ខ្ជួន ដើម្បីជៀសវាងកុំឱ្យធ្លាក់ខ្លួនទៅប្រព្រឹត្តបទ ល្មើសដែលនាំឱ្យមានការផ្តន្ទាទោសព្រហ្មទណ្ឌពីតុលាការ និងបណ្តាលខូចខាតនូវផលប្រយោជន៍របស់ខ្លួនឯង ក៏ដូចជា ក្រុមគ្រួសារ និងសង្គមជាតិទាំងមូលផងដែរ។

# ឯកសារយោង

# ឯកសារយោង


❖ **លិខិតបទដ្ឋានគតិយុត្តជាតិ**

១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ១៩៩៣។

២. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

៣. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

៤. ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១២។

៥. ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦។

៦. ច្បាប់ស្តីពីឯកពន្ធភាព ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ ២០០៦។

៧. ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១០។

៨. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី-ខេត្ត-ក្រុង-ស្រុក-ខណ្ឌ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម លេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨។

៩. ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិច្បាប់ស្តីពីការងារ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០២។

❖ **វចនានុក្រម និងសទ្ទានុក្រម**

១. សទ្ទានុក្រមពាក្យច្បាប់ ផ្នែករដ្ឋប្បវេណី ទីស្តីការគណៈរដ្ឋមន្ត្រីឆ្នាំ ២០០៧ ។

២. សទ្ទានុក្រមពាក្យច្បាប់ ផ្នែកក្រមព្រហ្មទណ្ឌ ទីស្តីការគណៈរដ្ឋមន្ត្រីឆ្នាំ ២០១១។

៣. វចនានុក្រមខ្មែរសម្តេចសង្ឃរាជ **ជួន ណាត** ។

៤. សទ្ទានុក្រមនៃច្បាប់ស្តីអំពីការគ្រប់គ្រងរដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ។

❖ **ឯកសារជាសៀវភៅ និងឯកសារផ្សេងៗ**

១. សៀវភៅនីតិព្រហ្មទណ្ឌទូទៅរបស់សាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងសាស្ត្រាចារ្យ **ចាំង ស៊ីណាត** ២០២២។

២. សៀវភៅនីតិព្រហ្មទណ្ឌទូទៅ របស់សាស្ត្រាចារ្យ **កៅ សីហា** ឆ្នាំ២០១៣។

៣. សៀវភៅនីតិព្រហ្មទណ្ឌទូទៅ របស់សាស្ត្រាចារ្យ **មីន សំអុល** ។

៤. សម្រង់មេរៀនស្តីពីនីតិព្រហ្មទណ្ឌខ្មែរ ត្រង់ចំណុច "ទោសព្រហ្មទណ្ឌ" ឧទ្ទេសនាមដោយឯកឧត្តម **សេង ស៊ីវុត្ថា** អនុប្រធានសាលាឧទ្ធរណ៍ សម្រាប់កម្មសិក្សាការីមន្ត្រីជាន់ខ្ពស់នៃសាលាភូមិន្ទរដ្ឋបាល ឆ្នាំសិក្សា២០១០-២០១១។

៥. យោងប្រសាសន៍របស់ ឯកឧត្តម **ផូវ សំភី** នៅក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពី "ក្រមព្រហ្មទណ្ឌ" រៀបចំឡើងដោយក្រសួងយុត្តិធម៌សហការជាមួយក្រសួងព័ត៌មានតាមរយៈទូរទស្សន៍ជាតិកម្ពុជា។

៦. យោងតាមប្រសាសន៍របស់ឯកឧត្តម **កើត រិទ្ធ** អនុប្រធានក្រុមការងារចូលរួមតាក់តែង និងការពារសេចក្តីព្រាងក្រមព្រហ្មទណ្ឌ នៅក្នុង កម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពី "ក្រមព្រហ្មទណ្ឌ" ដែលរៀបចំឡើងដោយក្រសួងយុត្តិធម៌សហការជាមួយក្រសួងពត៌មាន តាមរយៈទូរទស្សន៍ ជាតិកម្ពុជា ឆ្នាំ ២០១០។

៧. រៀបរៀងដោយលោក **លីន សិលា** និយាយអំពីនិយមន័យនៃមូលទោស។

៨. ការផ្សព្វផ្សាយក្រមព្រហ្មទណ្ឌ តាមរយៈទូរទស្សន៍ជាតិ ឆ្នាំ២០១០ និង

៩. ឯកសារផ្សេងទៀត។

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ

- **ឧបសម្ព័ន្ធទី ១** រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ១៩៩៣។
- **ឧបសម្ព័ន្ធទី ២** ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។
- **ឧបសម្ព័ន្ធទី ៣** ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០៩។
- **ឧបសម្ព័ន្ធទី ៤** សាលដីកាតុលាការកំពូល។

# ឧបសម្ព័ន្ធទី ១

# រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

# ឧបសម្ព័ន្ធទី ៣

# ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

# ឧបសម្ព័ន្ធទី ៤
# សាលដីកាតុលាការកំពូល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ១២៩
ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩
សាលដីកា
លេខ: ០៨ "I"
ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០

# សាលដីកា

## នាមនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០២០

ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម ៖

១.ឯកឧត្តម [redacted] ប្រធានអង្គជំនុំជម្រះ
២.លោក [redacted] ចៅក្រម
៣.លោក [redacted] ចៅក្រម
៤.លោក [redacted] ចៅក្រម
៥.លោកស្រី [redacted] ចៅក្រមរបាយការណ៍

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

**តំណាងមហាអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញា

**ដើម្បីជំនុំជម្រះ**

លើពាក្យបណ្តឹងសាទុក្ខលេខ ១២៩ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៣៦ ក្រI "ស.វ" ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ដែលមាន ៖

**ជនជាប់ចោទឈ្មោះ** [redacted] ភេទប្រុស អាយុ៣៤ឆ្នាំ ជាតិខ្មែរ មុខរបររត់កង់បី ទីកន្លែងកំណើតនៅភូមិគ្រួស ឃុំសំរោង ស្រុកពញាឮ ខេត្តកណ្តាល មានទីលំនៅមុនពេលឃាត់ខ្លួនផ្ទះ[redacted]រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] មានកូន០៣នាក់ ជានីតិជន ទោសពីមុនគ្មាន ។ (អ្នកប្តឹងសាទុក្ខ)

មេធាវីការពារសិទ្ធិ លោកស្រី [redacted] និងលោក [redacted] ។

**ជាប់ចោទពីបទ ៖ រំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ** ប្រព្រឹត្តនៅចំណុចបន្ទប់ទឹកនៅសាលាសង្កាត់សំរោង ផ្លូវបេតុង ភូមិសំរោង សង្កាត់សំរោង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨ បទល្មើសមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ ។

**ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ**[redacted] ភេទស្រី អាយុ៣៥ឆ្នាំ ជាតិខ្មែរ មុខរបរមេផ្ទះ មានទីលំនៅបច្ចុប្បន្នភូមិសំរោងជើង សង្កាត់សំរោង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ។

**ជនរងគ្រោះឈ្មោះ**[redacted] ភេទស្រី កើតថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០៨ ទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] រាជធានីភ្នំពេញ ។

**អំពីអង្គហេតុ ៖**

កាលពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨ វេលាម៉ោង១០ និង០០នាទី ជនរងគ្រោះឈ្មោះ [redacted] ភេទស្រី អាយុ១០ឆ្នាំ កំពុងអង្គុយលេងក្បែរសាលាសង្កាត់សំរោង ផ្លូវបេតុង ភូមិសំរោង សង្កាត់សំរោង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ស្រាប់តែជនសង្ស័យឈ្មោះ[redacted] ភេទប្រុស អាយុ៣៤ឆ្នាំ បានមកឈប់ពីមុខសាលាសង្កាត់សំរោង ចាប់ដៃជនរងគ្រោះទាញចូលក្នុងបន្ទប់ទឹកសាលាសំរោង បិទទ្វារចាក់សោរហើយបានចាប់ជនរងគ្រោះដាក់លើអាងទឹក រួចធ្វើសកម្មភាពរំលោភ ដោយជនសង្ស័យយកប្រដាប់ភេទរបស់ខ្លួនដាក់បញ្ចូលក្នុងប្រដាប់ភេទរបស់ជនរងគ្រោះ ហើយធ្វើសកម្មភាពរំលោភបានសម្រេច រួចក៏ត្រឡប់មកផ្ទះវិញ ។ លុះដល់ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៨ វេលាម៉ោង៧ និង៣០នាទី អាណាព្យាបាលរបស់ជនរងគ្រោះឈ្មោះ [redacted] ប្រទះឃើញជនសង្ស័យបានធ្វើការចាប់ឃាត់ខ្លួនប្រគល់ឱ្យសមត្ថកិច្ច ដើម្បីចាត់តាមនីតិវិធីច្បាប់ ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៧៥៦ “ព” ក្រ៨ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៨ របស់សាលា ដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ផ្តន្ទាទោសឈ្មោះ[redacted] ភេទប្រុស អាយុ៣៤ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន ០៨ (ប្រាំបី)ឆ្នាំ ពីបទ ៖ រំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ ប្រព្រឹត្តនៅចំណុច បន្ទប់ទឹកនៅសាលាសង្កាត់សំរោង ផ្លូវបេតុង ភូមិសំរោង សង្កាត់សំរោង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨ បទល្មើសដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ ។

២-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] សងសំណងជម្ងឺចិត្តជាប្រាក់ចំនួន ១២.០០០.០០០ (ដប់ពីរលាន)រៀល ឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] ។ ការទាមទារលើសពីនេះបដិសេធចោល។

៣-រឹបអូសវត្ថុចាប់យកដែលមានដូចក្នុងកំណត់ហេតុទទួលវត្ថុចាប់យកលេខ ៤០៤ រ.រ.ត ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៨ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ រួមមាន៖

ក.អាវយឺតដៃខ្លីពណ៌ផ្កាឈូក ចំនួន ០១

ខ.ខោខូប៊ិយជើងខ្លីពណ៌ខៀវ ចំនួន ០១

សាលក្រមនេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទលោក [redacted] និងលោក [redacted] កំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ជនរងគ្រោះឈ្មោះ [redacted] និងមេធាវីការពារសិទ្ធិឱ្យ ដើមបណ្ដឹងរដ្ឋប្បវេណីលោកស្រី [redacted] និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៨ ។

ទុកសិទ្ធិប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

-បានឃើញ បណ្ដឹងឧទ្ធរណ៍លេខ ៧២៦ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] ដែលប្ដឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៧៥៦ "ព" ក្រ៨ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ៣៦ ក្រ "ស.វ" ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ ៖

១-ទទួលបណ្ដឹងឧទ្ធរណ៍លេខ ៧២៦ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់គតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៧៥៦ "ព" ក្រ៨ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ ។

៣-បន្តឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] តាមនីតិវិធីច្បាប់ ។

សាលដីកានេះ ជំនុំជម្រះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៩ និងប្រកាសជាសាធារណៈថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទ និងកំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណី។ បើកសិទ្ធិប្ដឹងតវ៉ាក្នុងកំណត់ច្បាប់ ។

-បានឃើញ បណ្ដឹងសាទុក្ខលេខ ១២៩ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] ដែលប្ដឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ៣៦ ក្រ "ស.វ" ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល។

**នាពេលសវនាការ**

-ចៅក្រមបានអានរបាយការណ៍ ។

-តំណាងមហាអយ្យការអមតុលាការកំពូល ធ្វើសេចក្ដីសន្និដ្ឋានសុំថា ៖

ការសម្រេចសេចក្ដីរបស់សាលាឧទ្ធរណ៍ ដែលតម្កល់សាលក្រមរបស់សាលាដំបូងទុកជាបានការដដែល គឺមានសំអាងហេតុច្បាស់លាស់ និង ភស្តុតាងត្រឹមត្រូវតាមច្បាប់ ព្រោះថា ៖ ជនជាប់ចោទបានសារភាពកំហុស នៅមុខមន្ត្រីនគរបាល ស៊ីសង្វាក់គ្នាទៅ នឹងចម្លើយកុមាររងគ្រោះ ព្រមជាមួយលិខិតពិនិត្យ

ផ្លូវភេទរបស់មន្ទីរពេទ្យ បង្ហាញឱ្យឃើញថា ជនជាប់ចោទពិត ជាបានប្រព្រឹត្តបទល្មើសដូចបទចោទមែន ដូចមានក្នុងសំអាងហេតុចំណុច ទី២នៃសាលដីកាសាលាឧទ្ធរណ៍ស្រាប់ ។ ការបដិសេធរបស់ជនជាប់ចោទ គ្រាន់តែជាការឆ្លើយដោះសារតែប៉ុណ្ណោះ មិនអាចឱ្យជឿបានទេ ។

ហេតុដូច្នេះ

តំណាងមហាអយ្យការ ស្នើសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេច ៖

-សុំតម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៣៦ ក្រ "ស.វ" ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩ របស់សាលា ឧទ្ធរណ៍ ទុកជាបានការដដែល។

-លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] បានធ្វើសេចក្តីសន្និដ្ឋានថា ៖ កូនក្តីខ្ញុំប្តឹងមកនេះ គឺគាត់មិនសុខចិត្តពីការកាត់ទោស ។ បើពិនិត្យទៅលើអង្គហេតុ ចម្លើយគឺបានមកពីសាក្សី ហើយការដែលកូនក្តីខ្ញុំឆ្លើយសារភាព គឺដោយសារប៉ូលិសចាប់បង្ខំគាត់ ។

នៅចៅក្រមស៊ើបសួរគាត់បានបដិសេធថា គាត់មិនបានប្រព្រឹត្តទេ គ្រាន់តែបានលូកប្រដាប់ភេទតែប៉ុណ្ណោះ ចំពោះមន្ទីរពេទ្យបានធ្វើកោសល្យវិច័យ គឺប្រដាប់ភេទរបស់ជនរងគ្រោះ មិនបានដាច់ទេ គឺគ្រាន់តែក្រហមផ្នែកខាងក្រៅ ។

តាមអង្គហេតុរបស់សាក្សី គឺមិនមែនរំលោភសេពសន្ថវៈទេ ។

សំណូមពរ ៖ មេត្តាពិនិត្យពិចារណាទៅលើបទចោទ មាត្រា ២៤១ ពីបទរួមភេទ មាត្រា ៤៤៦ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីឱ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យ ពិចារណា ពិភាក្សា វិនិច្ឆ័យ ត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

១-យល់ឃើញថា បណ្តឹងសាទុកលេខ ១២៩ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជម្រះបាន តាមបទប្បញ្ញត្តិមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងបទប្បញ្ញត្តិមាត្រា ៤១៧ មាត្រា ៤១៨ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-យល់ឃើញថា សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីឱ្យជនជាប់ចោទបានលើកឡើងអះអាងថា កូនក្តីខ្លួនមិនបានប្រព្រឹត្តអំពើរំលោភសេពសន្ថវៈទៅលើកុមារីរងគ្រោះឈ្មោះ [redacted] ដូចការចោទប្រកាន់នោះទេ ។ គឺកុមារីឈ្មោះ [redacted] បានយល់ព្រមដោះខោអាវដោយខ្លួនឯង ហើយកូនក្តីខ្លួនគ្រាន់តែបានយកដៃទៅ ប៉ះពាល់ប្រដាប់ភេទកុមារីឈ្មោះ [redacted] តែប៉ុណ្ណោះ កូនក្តីខ្លួនមិនបានធ្វើសកម្មភាពរំលោភសេពសន្ថវៈលើកុមារីឈ្មោះ [redacted] នោះទេ ។ អំពើប្រព្រឹត្តរបស់កូនក្តីខ្លួន គ្រាន់តែជាអំពើប្រទូសកេរ្តិ៍ភេទតែប៉ុណ្ណោះ ។ ម្យ៉ាងវិញទៀត យោងតាមលទ្ធផលនៃការធ្វើកោសល្យវិច្ឆ័យក៏មិនបានបង្ហាញថា មានការដាច់រហែកប្រដាប់ភេទរបស់កុមារីជនរងគ្រោះ ឬមានស្លាកស្នាមនៅលើប្រដាប់ភេទនោះដែរ ។ ឯចម្លើយរបស់កូនក្តីខ្លួននៅចំពោះមុខនគរបាលយុត្តិធម៌នោះ មិនអាចយកជាបានការទេ ពីព្រោះមានការវាយដំ និងបង្ខិតបង្ខំពីសំណាក់មន្ត្រីនគរបាលយុត្តិធម៌នោះ ជាសេចក្តីសន្និដ្ឋានមិនមានមូលដ្ឋានអង្គហេតុ ភស្តុតាង និងអង្គច្បាប់អាចឱ្យតុលាការជឿបានឡើយ ហើយវាខុសទាំងស្រុងទៅអង្គហេតុ ភស្តុតាង និងអង្គច្បាប់ដែលមាននៅក្នុងសំណើរឿងក្តី ហើយត្រូវបានតុលាការអង្គហេតុលើកឡើងបង្ហាញនៅក្នុងផ្នែកសំអាងហេតុ និងសេចក្តីសម្រេចបានត្រឹមត្រូវហើយ ។

៣-យល់ឃើញថា បណ្តឹងសាទុកលេខ ១២៩ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] ធ្វើឡើងដោយមិនមានមូលហេតុនៃបណ្តឹងសាទុក្ខ សមស្រប ដូចមានបញ្ញត្តក្នុងមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឡើយ ។

៤-យល់ឃើញថា សេចក្តីសន្និដ្ឋានផ្ទាល់មាត់នាពេលសវនាការ ក៏ដូចជាសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់តំណាងមហាអយ្យការអមតុលាការកំពូល បានលើកឡើងអះអាងថា សេចក្តីសម្រេចសាលាឧទ្ធរណ៍ដែលបានសន្និដ្ឋានសុំឱ្យតម្កល់សាលក្រមរបស់តុលាការសាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ គឺមានសំអាងហេតុ ភស្តុតាង ត្រឹមត្រូវតាមច្បាប់ហើយ ដោយហេតុថា ជនជាប់ចោទបានសារភាពកំហុសរបស់ខ្លួននៅចំពោះមុខនគរបាលយុត្តិធម៌ ហើយចម្លើយសារភាពនោះ វាមានភាពស៊ីចង្វាក់គ្នាទៅនឹងចម្លើយរបស់កុមារីរងគ្រោះ ព្រមទាំងលិខិតបញ្ជាក់ពីលទ្ធផលពិនិត្យប្រដាប់ភេទរបស់កុមារីរងគ្រោះរបស់មន្ទីរពេទ្យ ដែលបង្ហាញថា ជនជាប់ចោទ ពិតជាបានប្រព្រឹត្តបទល្មើសដូចបទចោទប្រកាន់ ដូចមានក្នុងផ្នែកសំអាងហេតុទី២ នៃសាលដីការបស់សាលាឧទ្ធរណ៍ ការបដិសេធរបស់ជនជាប់ចោទគ្រាន់តែជាការឆ្លើយដោះសា ដោយមិនមានមូលដ្ឋានភស្តុតាងអ្វីមកបង្ហាញបញ្ជាក់ឡើយ មិនអាចឱ្យជឿបានឡើយ និងប្តឹងសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះតម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៣៦ ក្រI "ស.វ" ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩ ទុកជាបានការដដែលនោះ គឺជាសេចក្តីសន្និដ្ឋានផ្អែកលើមូលដ្ឋានអង្គហេតុ ភស្តុតាង និងអង្គច្បាប់សមស្រប អាចឱ្យតុលាការទទួលយកជាមូលដ្ឋានក្នុងការពិចារណា វិនិច្ឆ័យ សម្រេចសេចក្តីបាន ។

៥-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៣៦ ក្រ.I "ស.វ" ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលបានសម្រេចសេចក្ដីមកនេះ ត្រឹមត្រូវតាមច្បាប់ហើយ។

**ហេតុដូច្នេះ**

**សម្រេចសេចក្ដី**

១-បដិសេធចោលបណ្ដឹងសាទុក្ខលេខ ១២៩ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] ដោយមូលហេតុខុសនឹងគតិច្បាប់។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៣៦ ក្រ.I "ស.វ" ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ភ្នំពេញ ទុកជាបានការដដែល។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃសុក្រ ទី១០ ខែមករា ឆ្នាំ២០២០ និងប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃសុក្រ ទី១៧ ខែមករា ឆ្នាំ២០២០។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**

**សភាព្រហ្មទណ្ឌ**
សំណុំរឿងព្រហ្មទណ្ឌ
លេខ ២០៣
ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩
សាលដីកា
លេខ ០៤ "II"
ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០

# សាលដីកា

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០២០
ដោយអង្គជំនុំជម្រះមានសមាសភាពចៅក្រមដូចខាងក្រោម ៖

១. លោកស្រី [redacted] ជាប្រធាន
២. លោក [redacted] ជាចៅក្រម
៣. លោក [redacted] ជាចៅក្រម
៤. លោក [redacted] ជាចៅក្រម
៥. លោក [redacted] ជាចៅក្រម

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

**តំណាងមហាអយ្យការ**

លោក [redacted] ឋានៈជាព្រះរាជអាជ្ញា

**ដើម្បីជំនុំជម្រះ**

លើបណ្តឹងសាទុក្ខលេខ ២៥២ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៩ របស់ទណ្ឌិតឈ្មោះ [redacted] ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ០៥ ក្រVII (ធ) ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ដែលមាន ៖

- ទណ្ឌិតឈ្មោះ [redacted] ភេទប្រុស អាយុ២២ឆ្នាំ សញ្ជាតិខ្មែរ មុខរបរជាងកាត់កញ្ចក់ មានទីកន្លែងកំណើតនៅភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ទីលំនៅមុនពេលចាប់ខ្លួន [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "រ" នៅលីវ ទោសពីមុនគ្មាន។ ឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១ (ម១) នៃអគ្គនាយកដ្ឋានពន្ធនាគារក្រសួងមហាផ្ទៃ។ (អ្នកប្តឹងសុំស្រូបទោស)

- **កម្មវត្ថុ** ប្ដឹងសុំស្រូបទោសបញ្ចូលគ្នា ។

**អំពីមូលហេតុនៃបណ្ដឹង**

តាមពាក្យសុំឱ្យស្រូបទោសបញ្ចូលគ្នា ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៩ របស់ទណ្ឌិតឈ្មោះ [redacted] បានលើកឡើងថា ខ្លួនមានសំណុំរឿងព្រហ្មទណ្ឌចំនួន០២ ករណីដែលមានសាលដីកាបានចូលជាស្ថាពរទាំងពីររួចហើយ។

**សំណុំរឿងទី១**

-សំណុំរឿងព្រហ្មទណ្ឌលេខ ១៤៩៦ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ។

-សាលក្រមលេខ ៨៨ "ម" ក្រ៦ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ចំនួន ០៦ឆ្នាំ (ប្រាំមួយឆ្នាំ) ពីបទ លួចមានស្ថានទម្ងន់ទោស (ប្រើអាវុធខ្លីភ្ជង់ជនរងគ្រោះ) ប្រព្រឹត្តនៅចំណុចមុខសាលាបឋមសិក្សាពញាក្រែក ផ្លូវលេខ៩៣ ក្រុមទី១៩ ភូមិទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥។

-សំណុំរឿងព្រហ្មទណ្ឌលេខ ៧៩៨ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧ របស់សាលាឧទ្ធរណ៍។

-សាលដីកាស្ថាពរលេខ ៣១ ក្រVI "ប.ស" ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៨ បានសម្រេចតម្កល់សាលក្រមលេខ ៨៨ "ម" ក្រ៦ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល។

**សំណុំរឿងទី២**

-សំណុំរឿងព្រហ្មទណ្ឌលេខ ១៤៨១ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ។

-សាលក្រមលេខ ៤៧២ "ក្រ១ន" ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ចំនួន ០៦ឆ្នាំ (ប្រាំមួយឆ្នាំ) ពីបទ លួចមានស្ថានទម្ងន់ទោស (ប្រើអាវុធខ្លីភ្ជង់ជនរងគ្រោះ) ប្រព្រឹត្តនៅចំណុចមុខសាលាបឋមសិក្សាពញាក្រែកផ្លូវលេខ ៩៣ ក្រុមទី១៩ ភូមិទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥។

-សំណុំរឿងព្រហ្មទណ្ឌលេខ ១៣៣៧ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៦ របស់សាលាឧទ្ធរណ៍។

-សាលដីកាស្ថាពរលេខ ២៣ ក្រV "រ" ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨ បានសម្រេចតម្កល់សាលក្រមលេខ ៤៧២ "ក្រ១ន" ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល។

ដោយឆ្លងកាត់តាមការអប់រំ ក្នុងមណ្ឌលអប់រំកែប្រែទី១ នាពេលកន្លងមកខ្លួនបានដឹងពីកំហុសរបស់ខ្លួន បានគោរពប្រតិបត្តិយ៉ាងហ្មត់ចត់ ត្រឹមត្រូវតាមបទបញ្ជាផ្ទៃក្នុងរបស់មណ្ឌល និងបានយកចិត្ត

ទុកដាក់បំពេញការងារពលកម្ម យ៉ាងសកម្មទៀងទាត់ដែលជាគំរូដល់ទណ្ឌិតដទៃទៀត។ ខ្លួនមានស្មារតីភ្ញាក់រលឹក ខិតខំលត់ដំកែប្រែខ្លួនបានល្អ និងបានប្តេជ្ញាចិត្ត ខិតខំរៀនសូត្រអប់រំខ្លួនឱ្យក្លាយជាពលរដ្ឋសុចរិតមានប្រយោជន៍ដល់សង្គមជាតិ។

សំណូមពរ ខ្លួនស្នើសុំអនុវត្តឱ្យស្រូបទោសបញ្ចូលគ្នា ដោយសុំឱ្យសាលក្រមលេខ ៨៨ "ម" ក្រ៦ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ និងសាលដីកាស្ថាពរលេខ ៣១ ក្រVI "ប.ស" ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ និងសាលក្រមលេខ ៤៧២ "ក្រ១ន" ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ និងសាលដីកាស្ថាពរលេខ ២៣ ក្រV "វ" ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ ស្រូបទោសបញ្ចូលគ្នាទាំងមូល។

អាស្រ័យហេតុដូចបានគោរពជម្រាបជូនខាងលើ សូម ឯកឧត្តមប្រធាន មេត្តាពិនិត្យ និងលើកយកសាលក្រម និងសាលដីកាស្ថាពរទាំង០២ នេះមកធ្វើការជំនុំជម្រះ ដោយស្រូបទោសបញ្ចូលគ្នា ដល់ខ្លួនដោយក្តីអនុគ្រោះ។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ០៥ ក្រVII (ធ) ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១.ទទួលពាក្យសុំស្រូបទោសបញ្ចូលគ្នា ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៩ របស់ទណ្ឌិតឈ្មោះ [redacted] ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

២.ស្រូបទោសក្នុងសាលដីកាស្ថាពរលេខ ២៣ ក្រV (វ) ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ចំនួន០២ (ពីរ)ឆ្នាំ បញ្ចូលមកក្នុងសាលដីកាស្ថាពរលេខ ៣១ ក្រVI "ប.ស" ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ ដូច្នេះទោសដែលត្រូវអនុវត្តគឺ ចំនួន១០ (ដប់) ឆ្នាំ។

៣.សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈ នាថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩។ បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់។

-បានឃើញ បណ្តឹងសាទុក្ខលេខ ២៥២ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៩ របស់ទណ្ឌិតឈ្មោះ [redacted] ប្តឹងមិនសុខចិត្តទៅនឹងសាលដីកាព្រហ្មទណ្ឌលេខ ០៥ ក្រVII (ធ) ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

**នាពេលសវនាការ**

-ចៅក្រមរបាយការណ៍បានអានរបាយការណ៍

-តំណាងមហាអយ្យការអមតុលាការកំពូលបានធ្វើសេចក្តីសន្និដ្ឋានថា ទណ្ឌិតឈ្មោះ បានប្តឹងសុំស្រូបទោសបញ្ចូលគ្នា លើសាលក្រមស្ថាពរចំនួន ២ ដែលមានទណ្ឌកម្ម សរុបមានចំនួន ១២ឆ្នាំ ហើយសាលាឧទ្ធរណ៍បានសម្រេចស្រូបទោសមកត្រឹម១០ឆ្នាំ ឃើញថាការសម្រេចនេះមានលក្ខណៈត្រឹម

ត្រូវហើយ ព្រោះថាបើយោងតាមមាត្រា ១៣៨ នៃក្រមព្រហ្មទណ្ឌ បានកំណត់ថា ទោសដែលត្រូវប្រកាសអនុវត្តគ្រួតគ្នា នៅក្នុងព្រំដែននៃអតិបរិមាស្របច្បាប់ខ្ពស់ជាងគេ។ ហើយការផ្ដន្ទាទោសលើទណ្ឌិតពីបទលួចមានស្ថានទម្ងន់ទោស ហេតុនេះ ទណ្ឌកម្មខ្ពស់ជាងគេគឺ ១០ឆ្នាំ ឃើញថាមានលក្ខណៈត្រឹមត្រូវហើយ។ តំណាងមហាអយ្យការស្នើសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេច តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ០៥ ក្រVII (ធ) ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល។

-លោកមេធាវី [redacted] បានធ្វើសេចក្ដីសន្និដ្ឋានការពារទណ្ឌិត [redacted] ថា យើងឃើញហើយថាបទល្មើសរបស់គាត់ គឺបទល្មើសដូចគ្នា ហើយនៅក្នុងអំឡុងឆ្នាំតែមួយ។ បើគិតពីការព្យសនកម្មវិញ គឺមានព្យសនកម្មតិចតួចទៅនឹងទំហំនៃការប្រព្រឹត្ត។ ទាក់ទងទៅនឹងការស្រូបទោស គឺ ដើម្បីស្រូបទោសឱ្យមានភាពយុត្តិធម៌សម្រាប់អ្នកសុំ យល់ឃើញថាគួរតែយកទោសតូចស្រូបចូលទោសធំ មានន័យថាទណ្ឌកម្មដែលធំ។ អ៊ីចឹងយើងឃើញថា សាលក្រមចំនួន២ និងសាលដីកាដែលចូលជាស្ថាពរ មានកម្រិតទណ្ឌកម្មស្មើគ្នា គឺ៦ឆ្នាំ ខ្លួនយល់ឃើញថាគួរស្រូបបញ្ចូលទៅសាលក្រម ឬ សាលដីកាណាមួយ មានន័យថាយកទោស ៦ ឆ្នាំ ស្រូបចូលទោស ៦ ឆ្នាំ។ ក្នុងនាមខ្លួនជាមេធាវីការពារឱ្យទណ្ឌិត [redacted] សូមសំណូមពរដល់ក្រុមប្រឹក្សាជំនុំជម្រះ តុលាការកំពូលដែលជាតុលាការសម្រេចចុងក្រោយ សុំមេត្តាស្រូបទោសទណ្ឌកម្ម នៅក្នុងសាលដីកាណាមួយចូលទៅក្នុងសាលដីកាណាមួយ ដើម្បីឱ្យត្រឹមត្រូវតាមគតិនៃច្បាប់ដែលចែងថា ការស្រូបទោសគឺ ពីតូច ទៅធំ។

- ទណ្ឌិត គង់ វិច្ឆិកា បានឆ្លើយថា ខ្លួនសុំស្រូបទោសចូលទៅក្នុងសាលដីកាតែមួយបានហើយ និងសុំស្រូបទោសត្រឹម ៦ឆ្នាំ។

## តុលាការកំពូល

- ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារទណ្ឌិត [redacted]
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

១-យល់ឃើញថា បណ្ដឹងសាទុក្ខលេខ ២៥២ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៩ របស់ទណ្ឌិត [redacted] ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបាន តាមមាត្រា ៦៤ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ មាត្រា ៥០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-យល់ឃើញថា ការដែលមេធាវីរបស់ទណ្ឌិត [redacted] សុំឱ្យតុលាការកំពូលទទួលស្រូបទោសទាំងមូលឱ្យកូនក្ដីរបស់ខ្លួន ដោយលើកឡើងថាករណីរបស់កូនក្ដីខ្លួន គួរតែតុលាការកំពូលស្រូបបញ្ចូលទោស

៦ឆ្នាំ ទៅក្នុងទោសមួយទៀត ៦ឆ្នាំដែរនោះ ទើបជាការសមស្រប។ តុលាការកំពូលពិនិត្យឃើញថា ទណ្ឌិត [redacted] ត្រូវបានតុលាការផ្តន្ទាទោសពីបទល្មើស លួចមានស្ថានទម្ងន់ទោសទាំងពីរសាលក្រម ជាបទល្មើសកំពុងកើតមានពេលបច្ចុប្បន្ន។ ដូច្នេះការដែលសាលាឧទ្ធរណ៍បានទទួលឱ្យស្រូបទោស ត្រឹមព្រំដែនអតិបរិមាស្របច្បាប់ លើទោសដែលកំណត់ក្នុងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ គឺទោសត្រូវអនុវត្ត ១០ឆ្នាំ នោះជាការត្រឹមត្រូវហើយ។

៣-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ០៥ "ក្រVII(ធ)" ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ ត្រឹមត្រូវនឹងគតិច្បាប់ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

**១**- បដិសេធបណ្តឹងសាទុក្ខលេខ ២៥២ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៩ របស់ទណ្ឌិត [redacted] ។

**២**- តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ០៥ ក្រVII (ធ) ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ទាំងមូល។

*សាលដីកានេះ បានជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០២០ និងប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០។*